# ប្រជុំរឿងព្រេងខ្មែរ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## ភាគ ៤

៣១៥.
៤៩៥

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
ភ្នំពេញ
ព.ស.២៥៤៥ គ.ស.២០០១

www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ស្រុង ចាន់ណា** ម្ចាស់គេហទំព័រ៥០០០ឆ្នាំ

សូមគោរពថ្លែងអំណរគុណចំពោះ

**លោកវេជ្ជបណ្ឌិត ខ្ញៅ ឃុនសំរ៉ែង** ជាប្រធាន

**មូលនិធិខ្មែរសម្រាប់ការសិក្សា** www.ceefoundation.org

និង **ករុណាខ្មែរ** www.karunacambodia.org

ដែលបានអនុញ្ញាតដល់គេហទំព័រ៥០០០ឆ្នាំ

យកសៀវភៅនេះមកដាក់ផ្សាយបន្តជាធម្មទាន

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ ។

បណ្ណាល័យអេឡិចត្រូនិចខ្មែរ
eLibrary of Cambodia
www.elibraryofcambodia.org

៣១៥.៤៩៥

# ប្រជុំរឿងព្រេងខ្មែរ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## ភាគ ៤

LIBRARY
BUDDHIST INSTITUTE
៦៣៩៧/០២

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
ភ្នំពេញ
ព.ស.២៥៤៥ គ.ស.២០០១

www.budinst.gov.kh www.elibraryofcambodia.org

# សេចក្ដីបញ្ជាក់
# ចំពោះការបោះពុម្ពឡើងវិញ

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានស្រាវជ្រាវរើសរកក្បួនខ្នាតទាក់ទង នឹងអក្សរសាស្ត្រសាសនា អក្សរសាស្ត្រទូទៅ មកបោះពុម្ពឡើងវិញ ដើម្បីរក្សាស្នាដៃរបស់បុព្វបុរសខ្មែរយើង ។

ក្នុងការបោះពុម្ព សៀវភៅប្រជុំរឿងព្រេងទាំងប្រាំបួនភាគឡើងវិញនេះ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានថតចម្លងតាមច្បាប់ដើមទាំងស្រុង និងសូមអភ័យទោសជាមុន ចំពោះកង្វះខាតផ្សេងៗដែលអាចនឹងកើតមាន ដោយអចេតនាទៅលើអក្ខរាវិរុទ្ធក្ដី កំហុសក្នុងការរៀបរៀងឃ្លាក្ដី នោះគឺ ជាលក្ខណៈដែលមានក្នុងច្បាប់ដើមពីមុនមក ។

ភ្នំពេញ, ខែ កញ្ញា ឆ្នាំ ២០០១
វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

www.budinst.gov.kh www.elibraryofcambodia.org

# បញ្ជីរឿង


| រឿង | ទំព័រ |
| --- | --- |
| អារម្ភកថា | ក |
| ១- រឿងដើមកំណើតសត្វកូនលោក | ១ |
| ២- រឿងដើមកំណើតសត្វក្ងោក | ១១ |
| ៣- រឿងកូន ៤ នាក់មិនបម្រើឪពុក | ២៣ |
| ៤- រឿងតាយើង | ៣១ |
| ៥- រឿងសង្គ្រាមរវាងតិត្តក់និងតាព្រហ្ម | ៦១ |
| ៦- រឿងដើមកំណើតសត្វមូស | ៦៦ |
| ៧- រឿងឱកញ៉ាយោមរាជនិងឱកញ៉ាពលទេព | ៧៣ |
| ៨ រឿងដើមកំណើតរខ្ទុះ | ៨៣ |
| ៩- រឿងប្រវត្តិសត្វសុនខ | ៨៧ |
| ១០- រឿងសត្វឥន្ទ្រីរបស់ព្រះឥសូរ | ៩៦ |
| ១១- រឿងចចក | ១០១ |
| ១២- រឿងបុរសថ្លក ៤ នាក់ | ១២៣ |


www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្ស៊ូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

# អារម្ភបទ

ប្រទេសកម្ពុជាយើង មានរឿងព្រេង ច្រើនជាអនេក មិនអាចគណនា គ្រាប់ចំនួន ថា ប៉ុណ្ណេះ ប៉ុណ្ណោះបាន ។ រឿងទាំងនោះ ចាត់ជាពួកៗ គឺ:

ក)- រឿងចាត់ចូលដោយប្រវត្តិសាស្រ្ត និងភូមិសាស្រ្ត ដូចរឿង ភ្នំប្រុសភ្នំស្រី នៅខេត្តកំពង់ចាម, ភ្នំទ្រងមាន់-ភ្នំបាណន់-ភ្នំសំពៅ នៅខេត្តបាត់ដំបង, ភ្នំសែនហាន នៅខេត្តកំពត, ភ្នំនាងកង្រី នៅខេត្តកំពង់ឆ្នាំង ជាដើម;

ខ)- រឿងចាត់ចូលដោយគុណាការកាត់ក្តី ដូចរឿង សុភាទន្សាយ និងរឿងផ្សេងៗ ដែលមានគុនសាស្រ្តាកឹងកន្ត្រៃ ជាដើម;

គ)- រឿងចាត់ចូលដោយការនេសាទ របៀបទាក់ ឬ បបាញ់ មានការទាក់ដំរីជាដើម;

ឃ)- រឿងចាត់ចូលដោយទំនៀមទម្លាប់ មានទំនៀមមង្គលការ ជាដើម ។

រឿងសាស្រ្តាល្បែង ក៏មានច្រើនលើសគណនា ដូចរឿង ព្រះជិនវង្ស, វរវង្សសូរវង្ស, ស័ង្ខសិល្បជ័យ, ជ័យទត្ត ជាដើម ។

www.budinst.gov.kh www.elibraryofcambodia.org

ទាំងរឿងព្រេង ទាំងរឿងសាស្ត្រាល្បែង ជារឿងពិរោះពិសា មានសារប្រយោជន៍ ខាងផ្លូវវណ្ណគតិអក្សរសាស្ត្រ ហើយជារឿងសម្រាប់ដឹកនាំអ្នកអាន អ្នកស្តាប់ ឲ្យកើតសតិបញ្ញាយល់ការខុសត្រូវជ្រៅកក់ច្រើន ឲ្យមានគតិខ្ពស់ ស្គាល់គុណទោស, រួមយ៉ាងខ្លី គឺឲ្យស្គាល់គតិលោក គតិធម៌

ចំពោះរឿងសាស្ត្រាល្បែង យើងបានសង្កេតដំណើររឿងនីមួយ ៗ ឃើញបានគតិពីរយ៉ាង គឺ ខាងដើមរឿង ច្រើននិយាយពីការកំសត់ក្រោក់ក្រាស, កណ្តាលរឿង ច្រើននិយាយពីការច្បាំងគ្នា ការប្រណាំងប្រជែងគ្នា ជាគតិលោក, ខាងចុងបំផុតរឿង ច្រើនតែនិយាយពីតួឯក ក្នុងរឿង ចេញបួសជាតាបសឬឥសី ដែលជាគតិធម៌, ដើម្បីទាញអារម្មណ៍អ្នកអាន អ្នកស្តាប់ ឲ្យសប្បាយរីករាយត្រេកត្រអាលក្នុងកាម តាមផ្លូវលោក ជាខាងដើម ឲ្យនឿយណាយចាកកាម តាមផ្លូវធម៌ជាខាងចុង. ហើយជាពិសេសបំផុត គឺ ច្រើនតែជារឿងឃោសនា ដើម្បីទាញចិត្តអ្នកអាន អ្នកស្តាប់ ឲ្យជឿកម្មផល តាមគតិពុទ្ធសាសនា ។

ឯរឿងព្រេង និងរឿងសាស្ត្រាល្បែងទាំងប៉ុន្មាន ដែលកើតមាន នៅប្រទេសកម្ពុជាយើងនេះ ចែកជាពីរផ្នែក :

១) លោកអ្នកប្រាជ្ញបុរាណ បាននិពន្ធទុក ហើយបន្តផង បាន ចារសរសេរតៗគ្នាដាក់ស្លឹករឹតខ្លះ ដាក់ក្រាំងខ្លះ ដាក់សៀវភៅខ្លះ ជា

ពាក្យរាយក៏មាន ពាក្យកាព្យក៏មាន ទុកនៅតាមវត្តអារាម ភូមិស្រុកនានា ពេញប្រទេសកម្ពុជាទាំងមូល ។

២) ចាស់បុរាណ បាននិពន្ធទុក ហើយបណ្ដាជន បានតំណាល ប្រាប់គ្នាតៗមក ដោយមាត់ទទេ ឥតបានចារសរសេរឡើយ ។

បើពុំប្រមូលកត់ត្រាទុកទេ រឿងទាំងនោះ នឹងកត់កាយរកកំណាត់ ចំនួនពុំបាន ហើយនឹងបាត់បង់ ឬនឹងប្រែក្លាយទៅជារឿងសម័យថ្មី អស់បាត់ពូជដើម ។ ព្រោះហេតុនេះ បានជាក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ បានខំស្រាវជ្រាវរក និងប្រមែប្រមូល ទាំងរឿងដែលចារជាសាស្ត្រា ទាំងរឿងដែលនិពន្ធមាត់ទទេ ដោយវិធីតាក់តែងតាំងសមាជិកឆ្លើយឆ្លងរបស់ក្រុមជំនុំនេះ ដែលមាននៅតាមស្រុក ខេត្តនានា ឲ្យកត់ត្រាតាមមាត់ចាស់ៗ ដែលចេះចាំស្ទាត់ មកតម្កល់ទុកក្នុងមន្ទីរក្រុមជំនុំទំនៀមទម្លាប់ និងដោយវិធីចារ សរសេរចម្លង អំពីវត្តអារាមទាំងឡាយ ក្នុងព្រះរាជាណាចក្រ មកតម្កល់ទុកក្នុងបណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងដោយពិធីចុះផ្សាយ ក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ជាយូរឆ្នាំមកហើយផង ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ បានស្រង់រឿងព្រេងទាំងប៉ុន្មាន ដែលមានក្នុងមន្ទីរក្រុមជំនុំទំនៀមទម្លាប់ ក្នុងបណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ និងក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ដែលបាន

www.budinst.gov.kh www.elibraryofcambodia.org

សន្សំទុកជាយូរឆ្នាំមកហើយនោះ មកប្រមូលរៀបចំ បោះពុម្ពជាសៀវភៅដោយឡែក ចែកជាភាគៗ ឲ្យឈ្មោះថា "ប្រជុំរឿងព្រេងខ្មែរ" ដើម្បីៈ

ក)   ឲ្យរឿងព្រេងខ្មែរតាំងពីបុរាណ បានមូលត្រកូលគ្នា ស្រួលដល់លោកអ្នកត្រូវការរក យកទៅអាន :

ខ)- រក្សាស្នាដៃកវីនិពន្ធខ្មែរសម័យបុរាណ ទុកជាកេរ្តិ៍ដំណែលតទៅ កុំឲ្យបាត់បង់ :

គ)- ឲ្យអ្នកអានបានឃើញច្បាស់ថា ជាតិខ្មែរយើង មានកេរ្តិ៍មត៌កវណ្ណគតិអក្សរសាស្ត្រ ច្រើនអនេក :

ឃ)- ឲ្យអ្នកអាន បានស្គាល់ព្រឹត្តិការណ៍វណ្ណគតិអក្សរសាស្ត្រខ្មែរសម័យបុរាណ :

ង)- ឲ្យអ្នកអានបានចេះចាំរឿងនិទាន ពាក្យពេចន៍បុរាណច្រើនបែបប្រាជ្ញា គាប់ធ្វើការបរបា ការនិពន្ធរបស់ខ្លួន ឲ្យមានសម្រស់ :

ច)- ឲ្យអ្នកនិពន្ធ ងាយប្រៀបធៀបពាក្យពេចន៍សម័យចាស់ សម័យថ្មី ហើយធ្វើសេចក្តីនិពន្ធរបស់ខ្លួន ឲ្យមានលំអ ឲ្យត្រូវគ្រប់សម័យ ។

ឯពាក្យពេចន៍ក្នុងប្រយោគរឿងនីមួយៗ យើងទុកឲ្យនៅតាមបុរាណជាច្រើន វៀរលែងតែរឿងណា ដែលគត់ត្រាតាមមាត់ចាស់ៗ និទាននោះ ទើបប្រើរបៀបសម័យថ្មី ។

www.budinst.gov.kh www.elibraryofcambodia.org

ចំណែកឯអក្ខរាវិរុទ្ធ យើងបានកែតម្រូវ តាមវចនានុក្រមខ្មែរសម័យបច្ចុប្បន្ន ។

ក្រុមជំនុំសង្ឃឹមថា "សៀវភៅប្រជុំរឿងព្រេងខ្មែរ" នេះ នឹងបានជាកម្លាំងមួយ អាចជួយពង្រីកអក្សរសាស្ត្រជាតិ ឲ្យមានវឌ្ឍនាការជាតិយោភាព ។

១ មករា ១៩៥៩

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## ១- រឿងដើមកំណើតសត្វក្ងូនលោក(១)

បក្សីម្យ៉ាង ហៅថា សត្វក្ងូនលោក រូបរាងស្រដៀងនិងសត្វត្រលីងត្រលោង តែមានមាឌធំជាងត្រលីងត្រលោងបន្តិច សម្បុរវាក្រហមទុំៗ ច្រើនអាស្រ័យនៅក្នុងព្រៃភ្នំ ឬព្រៃស្រោងស្រើង ។ សត្វនេះចាស់ៗខ្មែរយើង បាននិយាយតៗមកថា មានដើមកំណើតមកពីមនុស្ស ដូចមានរឿងដំណាលតទៅនេះ :

កាលពីព្រេងនាយ មានកសិករពីរនាក់ប្តីប្រពន្ធ ជាមនុស្សក្រលំបាក មានកូនស្រីតូចៗ ៣ នាក់ ។ កូនទី ១ ចេះដងទឹកដាំបាយ, កូនទី ២ ចេះនាំប្អូនដើរលេង, កូនទី ៣ ចេះរត់លេង ។

ក្រោយពីពេលដែលប្តីស្លាប់ចោលទៅ នាងប្រពន្ធនៅមេម៉ាយជាមួយនឹងកូនស្រី ៣ នាក់ តែងទៅកាប់ឧស បេះបន្លែ ទូលទៅលក់ឯផ្សាររាល់ថ្ងៃ ។

---

១- ឯកសារទំនៀមទម្លាប់លេខ ២៧.១៤០ រៀបរៀងដោយលោក ករ៉ុ-ឌ ណ្ហា ឆ: នៅឃុំត្រែវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ ចុះផ្សាយ ក្នុងកម្ពុជសុរិយា លេខ ២ ឆ្នាំ ១៩៦០ ។

www.budinst.gov.kh www.elibraryofcambodia.org

ថ្ងៃមួយ នាងបានទៅជួបនឹងអ្នកលេងស៊ីផឹកម្នាក់ ដែលតែងតែដើរលួច ឆក់ អ្នកដំណើរឆ្ងាយជិត បានលុយកាក់យកមកស៊ីផឹកហ៊ឺហា ។ អ្នកលេងនោះ កាលបើក្រឡេកឃើញនាងមេម៉ាយ ក៏សំដែងកាកប្ប-កិរិយា ជាអ្នកគួរសម សួរនាងថា "ចុះនាងនៅភូមិណា? ឆ្ងាយឬជិត? ហេតុអ្វីក៏មិនឲ្យប្ដីជួយរែក ប្រឹងផ្ទុកខ្លួនម្នាក់ឯងច្រើនម៉្លេះ?" ។

នាងក៏ប្រាប់ដោយត្រង់ថា "ខ្ញុំជាស្រីមេម៉ាយ ប្ដីស្លាប់ចោលទៅ សព្វថ្ងៃក្រលំបាកណាស់ ប្រឹងកាប់អុស បេះបន្លែលក់ គ្រាន់បានប្រាក់កាស បន្តិចបន្តួច យកទៅទិញអាហារចំណី ឲ្យកូនស្រី ៣ នាក់បរិភោគ" ។

ឮដូច្នោះ អ្នកលេងនឹកអរព្រួចក្នុងចិត្ត គិតថា "នាងនេះមេម៉ាយមែន ប៉ុន្តែ មានរូបស្អាតគ្រាន់បើ គួរអញតាមទៅសួរដល់ផ្ទះ យកជាប្រពន្ធឲ្យបាន" ហើយក៏និយាយថា "នាង! ខ្ញុំមានចិត្តអាណិតនាងណាស់ ខ្ញុំសូមជូននាង ១០ កហាបណៈ សម្រាប់ទិញឥវ៉ាន់ផ្ញើកូន" ។ នាងមេម៉ាយក៏ទទួលយកភ្លាម ដោយសេចក្ដីត្រេកអរ លុះលក់អុសនិងបន្លែអស់ហើយ នាងត្រឡប់ទៅផ្ទះវិញ ។ ឯអ្នកលេង ក៏លបដើរមកតាមក្រោយ ដើម្បីគន់មើលផ្ទះ លុះពេលព្រលប់ ក៏ទៅជួបនាងឯផ្ទះ និយាយគ្នាត្រូវរ៉ាត់ហើយ ក៏យកគ្នាជាប្ដីប្រពន្ធតទៅ ។

ចាប់តាំងពីថ្ងៃនោះមក អ្នកលេងតែងចេញទៅប្លន់អ្នកស្រុក ២-៣

www.budinst.gov.kh www.elibraryofcambodia.org

ថ្ងៃ មកផ្ទះម្តងក៏មាន កន្លះខែ មកម្តងក៏មាន ។ នាងនោះមានមាសប្រាក់ ហាយបរិបូណ៌ ស្លៀកពាក់សុទ្ធតែរបស់ល្អៗ ក៏កើតជាធំចិត្ត ឡើងហាន ដើរលេងស៊ីផឹកជាមួយប្តីនៅតាមផ្សារ ភ្លេចគិតដល់កូនកំសត់ទាំង៣នាក់, មានចិត្តក្តៅក្រហាយ ស្អប់កូនស្រីរបស់ខ្លួន ឃើញមុខកូនពេលណា ចង់តែយកកាំបិតមកកាប់ ឲ្យដាច់កទាំង ៣ នាក់ ពេលដាំស្ងួនហើយ នាំប្តីបរិភោគតែពីរនាក់ ៗ សល់បាយក្នុងឆ្នាំងបន្តិចបន្តួច កូនទាំង ៣ នាំបងប្អូនកេះកាយស៊ី ខ្លះដេកលក់ក្បែរជើងក្រាន ខ្លះដេកលក់នៅ ល្វែងផ្ទះខាងក្រៅ មូសសុបខាំពុរពេញខ្លួន ៗ ពេលព្រឹកៗ នាងនោះ កាត់តែងខ្លួនប្រាណ ទៅស៊ីផឹកនៅឯផ្សារ ជាមួយប្តីរាល់ថ្ងៃ ៗ

ថ្ងៃមួយ ប្តីបាននិយាយរំឭកថា « បងមានសេចក្តីអៀនខ្មាស មិត្តភក្តិខ្លាំងណាស់ ព្រោះប្អូនចេះតែតាមបង ទៅស៊ីផឹកឯផ្សារ ដូច្នេះបង សូមអង្វរចិត្តអូន សូមនៅផ្ទះថែទាំកូនស្រី ទាំង ៣ នាក់ចុះ" ៗ

ពួកប្តីនិយាយយ៉ាងនេះ នាងនោះគិតឃើញថា "ប្តីអញគាត់ហ៊ឺហាណាស់ ពួកស្រ្តីខូចក្នុងផ្សារ ស្គាល់គាត់ទាំងអស់ បើអញបណ្តោយ គេទៅថ្ងៃមុខ គាត់នឹងបោះបង់ចោលអញពុំខាន គួរអញរកឧបាយ សម្លាប់កូនស្រីទាំង ៣ នាក់ចោល កុំឲ្យគាត់មានពាក្យពាក់ដោត ថាឲ្យ អញនៅចាំផ្ទះ ព្រោះតែកូនឡើយ" ៗ

លុះដល់ខែពិសាខ មានភ្លៀងធ្លាក់ជោគជាំ នាងនោះ និយាយ

www.budinst.gov.kh www.elibraryofcambodia.org

បញ្ជោតកូនថា "កូនអើយ ! កាលឪពុកឯងរស់នៅ តែដល់វេរនេះហើយ គាត់តែងនាំម្ដាយ ទៅសាបព្រោះស្រូវ នៅត្រពាំងទឹកក្នុងព្រៃជិតដើងក្នំ មានខ្ទមលំហាដេកចាំស្រូវ ស្អែកនេះ ម្ដាយនឹងយកស្រូវពូជ ទៅសាបព្រោះ ចូរកូនទៅដេកចាំចាប ក្រាប លលក កុំឲ្យស៊ីស្រូវ" ។ លុះព្រឹកឡើង នាងនោះនាំកូន ចូលទៅក្នុងព្រៃរហោឋានជិតដើងក្នំ យកស្រូវទៅបាចសាចក្នុងត្រពាំង រួចផ្ដាំកូនថា "នែហងកល់គ្នា ! ត្រូវនៅចាំស្រូវ កុំទៅណាឆ្ងាយ កុំទៅផ្ទះ បើទៅ អញវាយសម្លាប់" ផ្ដាំហើយ នាងនោះទុកបាយឲ្យ ១ ចំអែតម្នាក់ អង្ករ ៣ ចានពោតបួនដប់ត្រាប់ កូនឆ្នាំងមួយ និងអំបិលប្រហុកបន្ដិចបន្តួច ដោយគិតថា "យប់នេះ ខ្លាវានឹងមកខាំស៊ី បើមិនស្លាប់ដោយខ្លាស៊ី ក៏គង់ស្លាប់ដោយអត់បាយពុំខាន" ។ លុះផ្ដាំកូនស្រេចហើយ ក៏ត្រឡប់មកផ្ទះវិញ ដេកចាំមើលផ្លូវប្ដីមកពីរកស៊ី ។ លុះប្ដីមកដល់ ក៏សួរថា "កូនស្រីទាំង ៣ នាក់ ទៅដើរលេងឯណា ពុំឃើញមកផ្ទះ ?" ។ ប្រពន្ធប្រាប់ថា "ខ្ញុំប្រើវាឲ្យទៅចាំស្រូវ ជាមួយចាស់ទុំជាច្រើន លុះស្រូវទុំ ទើបវាត្រឡប់មកវិញ" ។

ចំណែកកុមារីទាំង ៣ នាក់ នាំបងប្អូន យកត្រាប់ពោត ទៅគប់តាមមាត់ត្រពាំង ពេលយប់ នាំគ្នាឡើងទៅដេកលើខ្ទម ៗ ឮសូរតែមាត់ដំរី ចចក ស្វាន ស្វា ស្រែកទ្រហឹងអឹងកង ពេញព្រៃស្មសាន គាង

www.budinst.gov.kh www.elibraryofcambodia.org

បងមានសេចក្តីភិតភ័យ ញ័រខ្លួនដូចកូនសត្វ ស្មើគ្មានព្រលឹងនៅក្នុងខ្លួន លួងប្អូនៗ កុំឲ្យយំ ខ្លាចសត្វសាហាវទាំងនោះ វាមកខាំសម្លាប់ ។

គ្រានោះ អារក្ខទេវតា ដែលឋិតនៅក្នុងព្រៃស្មសាន គិតថា “នាងម្តាយហេតុអ្វី ក៏យកកូនតូចៗ មកប្រោសចោល ក្នុងព្រៃដូច្នេះ បើអញមិនជួយ កុមារីទាំង ៣ នេះផងទេ មុខជាម្រឹគពាឡយន់ឃ្នួនស៊ីពុំខាន គួរអញសង្គ្រោះកុមារីទាំងនេះ ទម្រាំផុតពេលរាត្រី ហើយអញនឹងក្រាបទូលសម្តេចឥន្ទ្រាធិរាជ” ។ គិតស្រេច អារក្ខទេវតាសម្តែងឫទ្ធិ ស្រែកគម្រាមពួកសត្វសាហាវ ឲ្យរត់ខ្ចាត់ខ្ចាយទៅ លុះព្រឹកឡើង ក៏ចូលទៅកាន់សំណាក់ទេវរាជឈ្មោះ វរុណា នៅទិសឦសាន ដើម្បីឲ្យទេវរាជនេះ នាំដំណឹងទៅក្រាបទូលព្រះឥន្ទ្រាធិរាជ ។

វរុណាទេវរាជរំពឹងឃើញថា “ការនេះមិនចាំបាច់ ទៅក្រាបទូលព្រះឥន្ទ្រាធិរាជទេ ព្រោះកុមារីទាំង ៣ នេះ ត្រូវក្លាយខ្លួនទៅជាសត្វបក្សី” ហើយបង្គាប់ថា “ត្រូវអ្នកឯងជួយការពារកុមារីទាំង ៣ ឲ្យមធ្យ័ត កុំឲ្យសត្វសាហាវបៀតបៀនបាន ទម្រាំវាក្លាយខ្លួនទៅជាសត្វ បើវាឃ្លានអាហារ ត្រូវនិម្មិតជាត្រីក្រិមខនក្ងាយ ខ្យង ខ្ចៅ ដាក់ក្នុងត្រពាំងមួយឲ្យវាស៊ីទៅ” ។ អារក្ខទេវតាត្រឡប់មកវិញ ក៏ធ្វើតាមបង្គាប់វរុណាទេវរាជ ។

ឯកុមារីទាំង ៣ នាក់នោះ នៅចាំស្រេបបាន ៣ យប់ ៣ ថ្ងៃ ក៏អស់

www.budinst.gov.kh www.elibraryofcambodia.org

អង្ករ ៣ ចានដែលម្ដាយទុកឲ្យស៊ី ប្អូនយំរកបាយស៊ី បងបានដើរទៅបេះស្លឹកថ្គឹង ចូលទៅក្នុងថ្លុកក្ដិបត្រួយត្រកួន និងដើមអំពៅជៀប យកមកបែកគ្នាស៊ី ប្អូនបង្អស់បេះតែស្រែកយំ បងក៏នាំគ្នាចុះទៅចាប់ត្រីក្រឹម ទន្សាយធំមួយ បានមកប្រុងដុតស៊ី តែភ្លើងដែលម្ដាយបង្កាត់ទុកឲ្យរលត់អស់ទៅ ក៏នាំបងប្អូនហែកស៊ីឆៅបន្តិចម្នាក់ ៗ ប្អូនបេះតែយំកន្ទក់កន្ទេញ បង់ទៅផ្ទះ បងថាមិនហ៊ានទៅទេ ខ្លាចម៉ែវាយ តែប្អូនតាំងពីស្រែកយំខ្លាំងពេក បងទ្រាំពុំបានក៏នាំទៅផ្ទះ ។

ឯម្ដាយ កាលបើឃើញកូនស្រី បណ្ដើរគ្នាមកដូច្នោះ ក៏មួម៉ៅស្រែកជេរពីលើផ្ទះថា "មេកូនចង្រៃ ! អញថាយកវាទៅប្រោសចោលឲ្យស្លាប់ព្រាត់ប្រាសអស់ទៅ ឥឡូវមិនស្លាប់បែរជានាំគ្នាត្រឡប់មកវិញ អញវាយសម្លាប់ឥឡូវហើយ កុំឲ្យឃើញមុខមាត់ អញមិនឲ្យហ៊ានឡើងផ្ទះសម្បែងទេ" ។ នាងបងអង្វរថា "សូមអ្នកម្ដាយករុណាកូនផងចុះ ព្រោះប្អូនបេះតែយំឃ្លានបាយ អត់ ២-៣ ថ្ងៃមកហើយ ស៊ីតែស្លឹកឈើជំនួសបាយ ភ្លើងក៏រលត់អស់ បើម៉ែមិនឲ្យនៅ កូនសូមតែអង្ករនិងភ្លើងត្រឡប់ទៅវិញ សូមម្ដាយកុំធ្វើបាបកូន កូនសូមទោស" ។

ឯកូនប្អូននិយាយប្រាប់ម្ដាយថា "ម៉ែ ! បងចាប់បានសាយស៊ីអែក" ។

ម្ដាយឮកូនប្រាប់ថា "ចាប់បានទន្សាយស៊ីឆ្អែត" ក៏រឹតតែមួម៉ៅខ្លាំងណាស់ទៅទៀត ជេរបញ្ចោរថា "មេកូនចង្រៃ ! វាបានទន្សាយ

www.budinst.gov.kh www.elibraryofcambodia.org

បែកគ្នាស៊ី ម្ដេចក៏មិនយកឲ្យអញស៊ីផង" ។ និយាយតែប៉ុណ្ណោះ ក៏ស្ទុះទៅវាយកូនទាំង ៧ នាក់ ដាក់ប្រំបណ្ដេញឲ្យទៅព្រៃវិញ របស់អ្វីបន្តិចបន្តួចក៏មិនឲ្យសោះ ចង់ឲ្យតែស្លាប់បាត់ទៅ ។

គួរឲ្យអាសូរកុមារីទាំង ៣ នាក់ នោះពន់ពេក ម្ដាយវាយបែកឈាមហូរសស្រាក់ ក៏នៅតែមិនបាត់វាចាថា "ម៉ែ ។ !" ឥតដឹងថាម្ដាយប្រុងសម្លាប់ខ្លួនពេលសោះ ។ ឯកុមារីប្អូននេះតែស្លូតប្រាប់ម្ដាយថា "បានសាយស៊ីតែត ។" ។ ម្ដាយឮដូច្នោះរឹតតែវាយខ្លាំងថែមទៀត ។

នាងបងប្រឹងអូសទាញប្អូនទាំងពីរនាក់ទៅ ដោយគិតឃើញថាបើត្រាំនៅ មុខតែម្ដាយសម្លាប់មិនខាន ហើយនាំគ្នាទៅនៅក្នុងខ្ទមផ្ដែល ដោយត្រាំត្រានឹងម្ដាយវាយសំពង ក៏សន្លប់បាត់ស្មារតីទាំង ៣ នាក់ ។

អារក្សទេវតា កាលបើឃើញដូច្នោះ ក៏យកទឹកមកប្រស់ព្រំកុមារីទាំង ៣ នាក់ ឲ្យមានស្មារតីឡើងវិញ ។

កុមារីទាំង ៣ នាក់ លុះដឹងស្មារតីឡើងហើយ ស្រែកទ្រហោយំទាំងអស់គ្នា ឯនាងបងក៏ចុះទៅចាប់ត្រីក្រមទន្លាយ និងដើររកខ្យងខ្លៅមកហែកចែកបងប្អូនស៊ីជំនួសបាយជានិច្ចរាល់ថ្ងៃ ត្រីនិងខ្យងខ្លៅនេះតែមានមិនអស់ ព្រោះទេពតានិម្មិតឲ្យ ។ កាលណាថ្ងៃក្ដៅល្អ ស្រង់មកហាលថ្ងៃឲ្យក្រៀមៗ វាយបំបែកហែកចែកគ្នាស៊ីទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

នាងចន្ទនិយាយកៀកកប្អូន លួងលោមថា: "អូនអើយ! យើងទាំង ៣ នាក់នេះ ពុំបានជួបមុខម៉ែទៀតទេ ព្រោះគាត់មានប្ដីថ្មីទៀត បានជាគាត់ស្អប់យើង ហើយរករឿងសម្លាប់យើងចោល យើងកុំសង្ឃឹមថាមានជីវិតរស់នៅតទៅមុខទៀត ណាមួយសំពត់អាវមានតែមួយម្នាក់សម្រាប់ស្លៀកដណ្ដប់ ឥឡូវនេះដាច់ដាចអស់ទៅហើយ តទៅមុខយើងរងាចុចឆ្អាលផ្គន់ ហើយទឹងគាក្រោកកាយនៅតែខ្លួនទទេ ដូចសត្វតិរច្ឆាន" ។

តាំងពីពេលដែលនាងបានដាំដុំវិញក្លីក្រពាំងនោះ បាន ៣ ខែ មានផ្លែចាស់ខ្ចី សត្វ ជ្រូក ក្ដាន់ ស្វា កំប្រុក ពុំហ៊ានទៅស៊ីឡើយ ព្រោះអារក្ខ-ទេវតាតែងថែរក្សា នាងចន្ទតែងទៅបេះយកមកបរិភោគ ជាមួយនឹងត្រីក្រឹមទន្សាយហើយនឹងរៀងទៅ ។ លុះបាន ៦ ខែ កុមារីទាំងបីនាក់ស្រាប់តែដុះរោមចេញពេញខ្លួន ដៃសនងាងដុះចេញទៅជាស្លាបទទះហើរទៅដល់ចុងឈើ ចាប់ប្រពោងបេះផ្លែឈើបានទាំងអស់គ្នា តែហើរទៅឆ្ងាយពុំរួច បបូរមាត់ដុះចេញទៅជាចំពុះ រីឯមាត់និយាយភាសាមនុស្សពុំកើត គ្រាន់តែដឹងខ្លួនថា ខ្លួននៅជាមនុស្ស តែដល់និយាយទៅជាសម្លេងសត្វតិរច្ឆាន យូរៗ ទៅកាន់តែហើរបានឆ្ងាយបន្តិចម្តងៗ ព្រោះតាំងពីបបូរមាត់ដុះចេញទៅជាចំពុះ មិនដែលនិយាយភាសាមនុស្សសោះ តែបើមនុស្សនិយាយទៅរក នៅស្តាប់បាន ។

www.budinst.gov.kh www.elibraryofcambodia.org

ឯប្តីចុងរបស់នាងជាម្តាយ នៃកុមារីទាំងនោះ តែងប្រព្រឹត្តអំពើចោរកម្មជានិច្ច ៗ ថ្ងៃមួយមានអ្នកជិតខាងគេប្តឹងដល់កផ្សា ១ ក៏ចាប់យកទៅដាក់គុកមួយជីវិតទៅ ៗ

ពេលនោះ នាងជាម្តាយដេកព្រួយចិត្ត នឹកអាណិតដល់កូនកំសត់ទាំង ៣ នាក់ ដែលខ្លួនបានធ្វើទុកបុកម្នេញ ហើយដើរទៅក្នុងព្រៃ ឃើញកូននៅរញ្ជន់ក្នុងខ្លួម ស្គាល់ច្បាស់ជាកូន ព្រោះមានទម្រង់ជាមនុស្សនៅឡើយ តែដុះស្លាបមានចំពុះដូចសត្វតិរច្ឆាន ក៏ស្រែកហៅថា "កូនអើយ ! ឥឡូវម្តាយមកទទួលកូនទៅវិញ ម្តាយលែងឲ្យកូននៅក្នុងព្រៃទៀតហើយ" ៗ

កូនទាំង ៣ នាក់ ឮមាត់ម្តាយហៅ ស្គាល់ជាក់ជាម្តាយ ក៏គិតគ្នាថា "ម៉ែយើងមករកសម្លាប់ទៀតហើយ ត្រូវយើងកុំទុកចិត្តគាត់ យើងនាំគ្នាហើរទៅល្អជាង" គិតដូច្នោះ ក៏នាំគ្នាហើរត្រសងទៅទំលើឈើខ្ពស់ ១ ដើម ស្រែកប្រាប់មកម្តាយ ដោយចំណាន់និយាយថា "យើងផុតនិស្ស័យជាកូនលោកហើយ យើងទៅជាសត្វតិរច្ឆានល្អជាង អ្នកកុំមកជិតយើង" ប៉ុន្តែសំដីដែលស្រែកប្រាប់មកម្តាយនោះ មិនច្បាស់លាស់ជាសំដីរបស់មនុស្សទេ ទៅជាស្រែកថា "កូនលោកៗ" ទៅវិញ កាលបើម្តាយចូលទៅជិត ក៏នាំគ្នាហើរទៅទំលើដើមឈើដទៃទៀត ស្រែកថា "កូនលោក ៗ" ៗ ម្តាយចេះតែដើរស្រែកហៅកូនទាល់តែអស់កម្លាំង

www.budinst.gov.kh www.elibraryofcambodia.org

ដើរពុំរួច ណាមួយអត់អាហារបរិភោគផង ក៏ដួលស្លាប់ទៅ ។

នៅប្រទេសកម្ពុជា សត្វនេះវាតែងតែហើរមក រើសខ្យងខ្ចៅស៊ី តាមវាលស្រែក្បែរដើមភ្នំ ឬព្រៃស្រោង កាលណាវាផ្អើលនឹងមនុស្ស ឬសត្វដូចគ្នា វាស្ទុះហើរ ស្រែកយំឮថា "កូនលោក កូនលោត!" ស្ទុះវាត្រីស្ទាត់វាជួបជួរមុខគ្នាឲ្យស្រែណោះពន់ពេក ។

---

## ២- រឿងដើមកំណើតសត្វផ្សោត(១)

កាលពីព្រេងនាយ ជាយូរអង្វែងណាស់មកហើយ មានដើមជ្រៃធំមួយ មានមែកគ្រស់គ្រសាយសាខា មហាផលនៅភូមិផិតខាង គេកប់គានគោគង្វាលបក្ខជាតនេះណាស់ ក្នុងសម័យនោះ ៗ គេធ្វើខួម មានរូបចម្លាក់ថ្ម ជាភេទប្រុស ១ ស្រី ១ ដាក់ឲ្យអង្គុយលើផែនថ្មក្នុងខួមនោះ គេតែងជូនសួងបន់ស្រន់ ថ្វាយក្រយាបូជាសុំសេចក្ដីសុខ ក៏ធ្លាប់បានសុខរៀងមក គេសន្មតថា អ្នកតាចាស់ស្រុក ។

មានរុក្ខទេវតាមួយ មានកាយវែង មិនដឹងជាប៉ុន្មានឆ្នាំមនុស្សឃើញទេ បិតនៅលើដើមជ្រៃធំនោះជាស្ដេចនៃឈើ ៗ យូរទៅ មានស្រីម្នាក់មកចាប់បដិសន្ធិ ជាកូនអ្នកស្រុកដែលកប់គានដើមរុក្ខជាតនោះ លុះធំពេញជំទង់ឡើង ផល់រដូវដែលត្រូវសែនព្រេនថ្វាយក្រយាបូជាអ្នកតាចាស់ស្រុក នាងនោះក៏ចូលជាសបាយចិត្ត នឹងបំណង ទៅសែនជួសឪពុក

---

១— ឯកសារទំនៀមទម្លាប់លេខ ២៧.០៤៩ រៀបរៀង ដោយលោកឥន ដ៉. ចណ្ហាឆៈ ឃុំគ្រូវៀនស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

ឆ្ងាយ ៗ រុក្ខទេវតាក្រឡេកឃើញ បេះតែមានចិត្តអាណិតអាសូរ ស្រឡាញ់នាងនោះ ហាក់ដូចជាព្រាត់គ្នាពីកាលណាមកហើយទើបនឹងបានជួបមុខគ្នាថ្មីៗ ។ រុក្ខទេវតានោះ កាន់តែវិតក្កចិត្តអាណិតនាងខ្លាំងណាស់ ទ្រាំពុំបាន ក៏ហោះទៅទូលសួរព្រះឥន្ទ្រតាមដំណើរ ៗ ព្រះឥន្ទ្រទ្រង់រំពឹងដោយញាណចក្ខុទៅ ឃើញថា នាងនោះកាលពីជាតិមុនជាប្រពន្ធរុក្ខទេវតានេះ បានកសាងប្រាថ្នាជាមួយគ្នាមកថា «ទោះបីទៅកើតជាតិណា ភពណា សុំឲ្យជួបបានជាប្ដី ប្រពន្ធនឹងគ្នាគ្រប់ៗជាតិ» លុះចាស់ទៀងខ្លួន រុក្ខទេវតានោះ សុំលាទៅបួសជាតាបស អស់ជីវិតដោយខ្លួនពីគ្នាទៅ ៗ តាបសមកកើតជារុក្ខទេវតានេះ ប្រពន្ធទៅកើតជានាងទេពធីតា បែកគ្នាទៅឆ្ងាយមិនជួបជុំ នាងប្រពន្ធច្យុតពីទេពធីតាមកកើត ជិតទឹកខ្ទិះដែលទេវតាជាប្ដីនៅ ៗ មកពីមាននិស្ស័យពីជាតិមុនយ៉ាងនេះ ទើបបណ្ដាលឲ្យរុក្ខទេវតា បេះតែស្រឡាញ់អាណិតអាសូរនាង ៗ តែមកពីរុក្ខទេវតានោះ មានពៀរដែលគេចទៅបួសចោលប្រពន្ធ ឲ្យព្រួយទុក្ខវេទនា លុះអស់សង្ខារទៅមិនឲ្យជួបមុខ បានជាច្យុតទៅកើតជាមនុស្សវិញ មិនជួបគ្នា ។ ព្រះឥន្ទ្រសំដែងប្រាប់រុក្ខទេវតាដូចរៀបរាប់មកនេះ ៗ រុក្ខទេវតាបានដឹងសព្វគ្រប់ហើយ ក៏លាព្រះឥន្ទ្រមកវិញ គិតពិចារណាថា «ឥឡូវ នឹងទៅថ្វាយបង្គំលាព្រះឥន្ទ្រាធិរាជ សុំច្យុតទៅកើតជាមនុស្សឃើញថាជាការមិនគួរ ព្រោះ

www.budinst.gov.kh www.elibraryofcambodia.org

ប្រពន្ធទៅកើត ធំពេញក្រមុំទៅហើយ ។ សង្ហាររបស់មនុស្សខ្ចីណាស់ មិនដូចទេវតាទេ" ។ ទេវតាគិតចុះគិតឡើង មិនធុះមិនធ្លាយត្រង់ណាសោះ ហេតុតែមានតៀរដែលគេបពោបួសជាតាបស មិនឲ្យឃើញមុខគ្រាតែសួនឲ្យសង្ហាររៀនខ្លួន ។ រុក្ខទេវតាព្រួយខ្លាំងណាស់ ក៏ប្រថុយប្រាណប្រថានព្រេងថា ល្ហើយចុះ អញទៅប្រាប់ប្រពន្ធឲ្យដឹង ថាខ្លួនអញជាប្ដីជាគូព្រេង ទៅចាប់ជាតិជារុក្ខទេវតា នាងឥតគូព្រេងទៀតទេ បើនាងបានដឹងថាខ្លួនអញជាប្ដីនាង មុខជានាងលែងយកប្ដីមួយជាតិនេះហើយ គិតស្រេច ពេលរាត្រីស្ងាត់ ក៏និម្មិតខ្លួនធ្វើជាពស់ថ្លាន់ចូលទៅឱបរិតនាង ។ ភ្ញាក់ឡើងបម្រះពុំរួច ពស់ថ្លាន់និយាយលួងលោមសព្វគ្រប់មិនជឿ ថាបើប្ដីជារុក្ខទេវតា ហេតុម្ដេចក៏មកជាពស់ថ្លាន់ដូច្នេះវិញ ។ រុក្ខទេវតាជាប្ដីថា បើនាងមិនជឿបង ។ នឹងប្រែរូបឲ្យនាងមើល ។ រុក្ខទេវតាក៏ផ្លាស់រូបជាទេវតាវិញភ្លាម ។ នាងក្រឡេកឃើញក៏ស្រឡាញ់ពេញចិត្ត ជឿជាក់ថាប្ដីខ្លួនជាទេវតាមែន ព្រោះរកមនុស្សណានឹងល្អដូចពុំបាន ។ រុក្ខទេវតានិយាយប្រាប់នាងថា ខ្លួនបង បើមិននិម្មិតខ្លួនជាសត្វថែបនេះទេ មិនអាចមកនៅជិតនាងបានឡើយ ត្រូវតែនិម្មិតរូបជាសត្វផ្ដេសផ្ដាស ទើបនៅជាមួយនាងបាន ។ និយាយរួចនិម្មិតខ្លួនជាពស់ថ្លាន់វិញ ។ ពស់ថ្លាន់នេះគ្រាន់តែនៅជាមួយនាងប៉ុណ្ណោះទេ ប៉ុន្តែមិនដែលរួមសំពាសជាមួយនឹងនាងនោះឡើយ ហើយហាមប្រពន្ធថា កុំ

www.budinst.gov.kh www.elibraryofcambodia.org

និយាយប្រាប់ម៉ែឪ បងប្អូន និងអ្នកស្រុកឲ្យដឹងថា ជាទេវតា ឲ្យថាតែពស់ថ្លាន់ ។ ពេលថ្ងៃ បងមិននៅជាមួយនាងទេ បងមកលេងតែយប់ៗ សឹមផ្លាស់រូបជាទេវតាឲ្យឃើញម្ដងៗ ។ ដឹងក្ដីហើយ ឮមាត់និយាយគ្នា ឪពុកម្ដាយចូលទៅមើល ឃើញពស់ថ្លាន់ពេនព្រេលពេញល្វែងផ្ទះ ក៏ភ្ញាក់ប្រឡោតស្រែក រុក្ខទេវតាភៀសខ្លួនបាត់ទៅ ។ ឪពុកម្ដាយហៅកូនស្រីមកសួរ កូននិយាយសាស័ព្ទប្រាប់តាមរឿង ពីដើមចប់ដល់ចុង ។ ឪពុកតាល់ប្រាជ្ញមិនដឹងធ្វើម្ដេចក៏ដកដង្ហើមធំ សួរកូនថា « ឥឡូវពស់ថ្លាន់ទេវតានោះ ទៅណាបាត់ទៅហើយ » ។ កូនប្រាប់ថា ពេលថ្ងៃមិនមកទេ យប់ទើបមក នាងប្រាប់ឪពុកម្ដាយថា « ទេវតាជាប្ដីហាមមិនឲ្យនិយាយប្រាប់គេថាទេវតាទេ ឲ្យថាតែពស់ថ្លាន់ហើយ » ។ លុះពេលរាត្រីស្ងាត់ រុក្ខទេវតាមកដល់ប្រពន្ធ និម្មិតរូបជាទេវតាឲ្យនាងមើលតាមសេចក្ដីសន្យា នាងក៏អុជភ្លើងភ្លឿងស្ទុះទៅឱបប្ដី ដោយសេចក្ដីមេត្រីស្នេហា ឮមាត់និយាយគ្នា ឪពុកម្ដាយចូលទៅលបមើល ឃើញទេវតាល្អណាស់ ក៏ស្រឡាញ់ពេញចិត្តនឹងរុក្ខទេវតានោះក្រៃលែង រុក្ខទេវតាដឹងថាឪពុកម្ដាយលបមើល ផ្លាស់រូបទៅជាពស់ថ្លាន់វិញភ្លាម ឃើញធំព្រេលពេញបន្ទប់ផ្ទះ ។ ទៀបភ្លឺ រុក្ខទេវតាប្រាប់ប្រពន្ធឲ្យនាំឪពុកម្ដាយ ទៅជីកយកកំណប់កន្លែងមួយ បានមាស ប្រាក់ ពេជ្រ កែវកង គុ ថាស ចាន ឥតពួនមកដាក់ពេញផ្ទះ ឡើងទៅជាអ្នកមានធំ ៗ

www.budinst.gov.kh www.elibraryofcambodia.org

យូរទៅ ដីនជ្រូកជ្រាបដល់អ្នកស្រុក ៗ មកមើលឈូនរ ឃើញពិតជា

ពស់ថ្លាន់ពេនព្រេល នៅជាមួយនិងនាង ។

និយាយពីបុរសប្តីប្រពន្ធ មានកូនក្រមុំមួយនៅភូមិផ្សេង ពីនាង

មានប្តីពស់ថ្លាន់ទេវតានោះ ចេះតែរំភើបក្នុងចិត្ត នាំប្តីប្រពន្ធសរសើរថា

"រាសនាអ្វីគេគឺល្អម្ល៉េះ ពីដើម ជាអ្នកក្រ ដូចគេឯងសោះ ឥឡូវ មាន

ផ្ទះធំខ្ពង់ខ្ពស់ក្រឡាក្រយ មានគោក្របីជំរំសេះ ខ្ញុំកំដរប្រើគ្រឹក-

គគ្រេង ល្បីឈ្មោះថា សេដ្ឋីសេដ្ឋី នេះមកពីកូនគេមានប្តីពស់ថ្លាន់

ថ្លាន់ឲ្យកំណាប់ព្រេង" ។ បុរសនោះគួបចិត្តមិនខ្ជុនឯងណាស់ ចេះតែ

ផកផង្ហើមធំ ចេះតែខ្នេញតាំងយប់តាំងថ្ងៃ ។ ប្រពន្ធឃើញប្តីកើតទុក្ខ

ដូច្នោះ ក៏និយាយប្រាប់ប្តីថា "ខ្ញុំបានឮចាស់ទុំនិយាយរៀង ៗ មកថា

សត្វពស់ថ្លាន់មិនដូចពស់តាំងតួនទេ តែមានដំបូកធំ ៗ ក្នុងព្រៃ ហើយ

ច្រើនមានពស់ថ្លាន់ទៅពំនួពេននៅទីនោះ គេថាពស់តេក្សកំណាប់ព្រេង" ។

ប្តីថា បើដូច្នោះ ព្រឹកស្អែកឯងដាំបាយឲ្យបងពីព្រឹក កុំឲ្យទាន់ណាដឹង

បងនឹងដើរស្វែងរកពស់ថ្លាន់ ពីដំបូកក្នុងព្រៃធំ ៗ បើឃើញ បងនឹង

ចាប់យកមក ធ្វើជាប្តីកូនយើង" ។ ប្រពន្ធពេញចិត្តក៏ព្រមព្រៀងគ្នា

ព្រឹកឡើងដាំបាយ វេចជាសំណុំព្រមទាំងទឹកបំពង់ ប្រគល់ឲ្យប្តី ៗ ក៏ដើរ

ស្វែងរកពស់ថ្លាន់ ។

បុរសនោះចូលក្នុងព្រៃធំ មិនយូរប៉ុន្មាន ក៏បានប្រទះដំបូកមួយធំ

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងព្រៃខ្ទួលមានបន្លាស្អិតឆ្អិនល្វើរវើមរវាម វារពាក់ព័ន្ធលើគ្នា ៗ បុរសចូលទៅអើតឈ្ងោកមើល ឃើញពស់ថ្លាន់ពេនព្រេល លើក្បាលដំបូក ៗ ពស់នោះ តាំងពីមកនៅក្នុងព្រៃដំបូកនោះ អស់កាលជាយូរអង្វែងណាស់មកហើយ វាមិនដែលវារទៅកាន់ទីណាសោះ ទោះបីអត់ឃ្លានយ៉ាងណាក៏ស៊ូតែព្រាំនៅក្នុងទីនោះ រូបពស់នោះក៏ទៅជាស្គាំងស្គម អស់កម្លាំងស្ទើរតែកំរើកខ្លួនមិនរួច ៗ បុរសយកឈើគោះមើល ក៏មិនតាំងកំរើកខ្លួនផង ៗ បុរសនោះ នឹកត្រេកអរក្នុងចិត្តណាស់ គិតថាពស់ថ្លាន់នេះច្បាស់ជាមានកំណប់ហើយ បានជាស្លូតម្ល៉េះ» ក៏បោចវល្លិចងតាំងខ្លួនស្រាក់ស្រូតជាប់ ៗ ពស់ក៏មិនរើប៉ុន្មាន ព្រោះវាស្គាំងស្គម ដោយអត់អាហារមកយូរហើយ ៗ បុរសលើកស្ពាយតាំងខ្លួនមក ដោយធ្ងន់ខ្លាំងពេក ក៏ចេះតែឈប់សម្រាកតាមផ្លូវ ពាល់ព្រលប់ទើបមកដល់ផ្ទះ ស្រែកហៅប្រពន្ធនិងកូនក្រមុំពីក្រៅរបង ឲ្យទៅជួយទទួល ៗ ប្រពន្ធនិងកូនក្រមុំ ក៏ចុះរត់ទៅទទួល ឃើញប្ដី- ឪពុកស្ពាយពស់ថ្លាន់តាំងខ្លួន ក៏ត្រេកអរផេតផុមា ៗ លុះយកមកដាក់ដល់លើផ្ទះ អ្នកប្រាប់ប្រពន្ធថា "ពស់នេះស្លូតណាស់ ត្រូវចិត្តបងហើយ បើភាគឯងមិនជឿ ទៅចាប់អង្អែលមើលចុះ ស្ទើរតែមិនកំរើកខ្លួនប្រាណផង" ៗ ប្រពន្ធលូកដៃទៅពាល់មើល ឃើញមិនកំរើកមែន ក៏ចេះតែបបោសអង្អែល សរសើរថា "កូនអើយពណ៌សម្បុរអ្នក អីក៏ល្អម្ល៉េះទេ ដូចជា

www.budinst.gov.kh www.elibraryofcambodia.org

គេទើបនឹងចិញ្ចឹមមាសថ្មីៗ ទុកជាហូលដែលជាន់បេះបង់គាត់យ៉ាងណា ក៏ល្អមិនដូចអ្នកដែរ" ។ ពស់ថ្លាន់ដោយជាប់ចំណងផង ហើយហៅកម្លាំងនឹងអត់អាហារយូរថ្ងៃផង ក៏ធ្វើតែក្អកក្អុះៗ លិទ្ធអណ្ដាតក្អែៗ ប្រហែលជា ក្នុងចិត្តដែលឃ្លាន ប្រុងតែលេបមនុស្ស ។

ប្ដីតាំងបង្គាប់ប្រពន្ធនិងកូនក្រមុំ ឲ្យកាប់មាន់ ស្ងោរដណ្ដាំបាយ ឲ្យគាប់ទិញរៀបសែនព្រេន ប្ដឹងដីដូនដីតារៀបផ្ដុំ ឲ្យកូនយកប្ដីពស់ថ្លាន់ ។ ប្ដីរត់ទៅទិញស្រាបានមក ប្រពន្ធដាំបាយស្ងោរឆ្អិន ដួសដាក់កុលាស ហៅបងប្អូនជិតខាង ឲ្យមកជួយសែនព្រេន បង្គាប់កូនក្រមុំឲ្យរៀបចំដំណេកបន្ទុយ អ្នកស្រុកជិតខាងដែលមានបញ្ញាវាងវៃ គេលាន់មាត់នឹងបុរសនោះជាឆ្កួត ជាព្រើល គ្រប់ៗគ្នា អ្នកខ្លះក៏រកតុទោ អ្នកខ្លះដែលត្រូវស្រា ករឲ្យតែគេហៅឲ្យចូលទៅជួយសែន នឹងបានស៊ីផឹកសប្បាយ ។

លុះទៅជួបជុំគ្នាហើយ ក៏លើកពស់ថ្លាន់ទៅដាក់លើកម្រាលសំពត់សស្រាយចំណង ឲ្យកូនក្រមុំទៅអង្គុយទន្ទឹម ពស់នោះក៏នៅតែស្ងៀមដោយគ្នាអត់អាហារមកយូរថ្ងៃហើយ ។ បុរសបង្គាប់គេឲ្យលើកបាសបាយសម្លទៅដាក់ អុជទៀនធូបសំបូងសង្រើង បួងដីដូនដីតា ប្រុបស្រា ៣ដង រួចតាប់សំណែន ខំចំណីបាយសម្លគ្រប់មុខ ដាក់ប្រឡូកចូលគ្នាមួយចាន យកទៅដាក់នៅមុខពស់ ហៅតួកតគ្រើនជើងសែន ឲ្យស៊ីព្រោះដីដូនដីតាពិសារួចហើយៗ លើកតុបាសចេញមកក្រៅ លត់ភ្លើង

www.budinst.gov.kh www.elibraryofcambodia.org

ទុកកូនក្រមុំឲ្យនៅជាមួយពស់ថ្លាន់ក្នុងបន្ទប់ ។ នាងនោះ ប្រហែលជា ខ្លាចពស់ដែរ ប៉ុន្តែ ទើងចេញមកក្រៅ ខ្លាចឪពុកម្តាយ ព្រោះគេផ្សំ ដំណេកឲ្យពស់ថ្លាន់ហើយ ក៏បេះតែអត់ទ្រាំទៅក៏មិនដឹង ឬ ក្រែកគរ ជាមួយនឹងពស់នោះដែរ ក៏មិនដឹង ។ ចំណែកឪពុកម្តាយ នាំញាតិ មិត្តស៊ីមាន់ ផឹកស្រាឯល្វែងខាងក្រៅ ។ ពស់នោះ កាលមនុស្សនៅ ស៊ីផឹក មាត់អ៊ូរអែ វានៅតែស្ងៀម ធ្វើហាក់ដូចជាមិនដឹងខ្លួន ។

លុះគេស៊ីផឹករួច ទៅស្ងាត់អស់ ប្រហែលជាពាក់កណ្តាលអាធ្រាត្រ វាហាខ្លួនឡូត វាផុតរឹតរួតនាងនោះទេ ព្រោះពស់នោះវាធំ ល្មមលេប នាងនោះបានតែម្តង វាគ្រាន់តែយកកន្ទុយ រុំកដៃនាងនោះជាប់ ឆក ក្បាលមកក្រោម កៀរជើងប្រមូលផ្តុំគ្នា វាហាមាត់លេបជើងនាង ទាំងពីរតែម្តង ។

ពីដំបូង នាងនោះស្មានថា ពស់ថ្លាន់ប្រុងរួមបវេណីនឹងខ្លួន បានជា នាងនៅស្ងៀម មិនមាត់ ព្រោះដេកជាមួយគ្នាតាំងពីល្ងាច មិនអីសោះ ថែបជាទុកចិត្តពស់បន្តិចទៅហើយ លុះវាលេបស្រើត ៗ ដល់ក្បាលជង្គង់ នាងនឹកសង្ស័យថា ពស់ថ្លាន់ច្បាស់ជាលេបអញពិតហើយ គិតនឹង ក្រោក ១ មិនរួច កន្ទុយពស់វារឹតដៃនាងជាប់ នាងភ័យណាស់ ស្រែក ហៅម្តាយថា "ពស់ថ្លាន់វាលេបខ្ញុំហើយ" ។ ម្តាយឮមាត់កូនស្រែក ហៅ ក៏ស្រែកសន្ធាប់ទៅវិញថា "ខ្មោចមេចំកួត ប្តីប្រពន្ធផង បាន

www.budinst.gov.kh www.elibraryofcambodia.org

តែត្រើល ៗ" ។ ផុតកស្រវឹងស្រាដេកសន្ធប់ ហៀរទឹកមាត់កខ្វាក់ ៗ លុះពស់លេបដល់ចង្កេះ នាងនោះស្រែកហៅម្ដាយថា "ម៉ែ ៗ ជួយកូនផង ពស់លេបដល់ចង្កេះហើយ" ។ ម្ដាយរឹតតែដេរបញ្ចោរពីក្រោមក ហើយស្ដីបន្ទោសថា "កូនអីក៏ចង្រៃ មិនចេះខ្មាសគេឯង មិនប្រឡំនឹងអ្នកស្រុក តិចអញចូលទៅវាយក្បាល ក្នុងដំណេកបែកឥឡូវ" ។ នាងនោះចេះតែស្រែកថា "ម៉ែអើយជួយកូនផង ! ពស់លេបដល់ចុងដង្ហើមហើយ, បន្តិចស្រែកថា "លេបដល់កហើយ" ។ ម្ដាយឮកូនស្រែកញយ ៗ ពេក មិនទ្រាំទាំងមាត់កតបផង គិតតែពីសម្ងំដេក លុះលេបដល់បបូរមាត់ ក៏ស្រែកលាផុតកម្ដាយថា "បើម៉ែមិនជួយកូនទេ កូនសុំលាស្លាប់ហើយ" ។ ម្ដាយស្ដាប់ទៅ ឮមាត់កូនដ៏ល ៗ ក្នុងមាត់ពស់ថ្លាន់ដែលកលេប គ្របបបូរមាត់ហើយនោះ ។ លុះបាត់ឮមាត់កូន ម្ដាយសង្ស័យ ក៏អុជភ្លើងចូលទៅមើល បាត់កូន ឃើញតែពស់ពោះធំកំពឹង តាំងពីក្រោមរហូត ដល់ជិតពាក់កណ្ដាលខ្លួន ។ នាងម្ដាយនោះ ក៏ស្រែកខ្ញូញអ៊ឹង ផ្អើលតោខ្ញោដល់អ្នកស្រុក អ្នកភូមិ ផ្ទះជិតខាង តាំងពាក់កណ្ដាលអធ្រាត្រ ។ ផុតកភ្ញាក់ឡើង ហៅអ្នកស្រុកមកជួបជុំ ពោមចាប់ពស់ថ្លាន់ ចាក់កបង់សន្ទឹង យកកាំបិតព្រាវះ យកកូនបានមក សន្លប់ស្មូន្យឈឹង ដូចជាស្លាប់ តែខ្លួននៅក្ដៅ ប្រឡាក់សុទ្ធតែរំអិលពស់ ពេញទាំងខ្លួន ទាំងក្បាល ទាំងដៃជើង ផ្កាប

www.budinst.gov.kh www.elibraryofcambodia.org

កខ្វក់ នាំគ្នាដងទឹកមកលាង ៗ មិនជ្រះ ដាំទឹកក្ដៅយកមកលាង ក៏មិនជ្រះ លុះគេស្រោចទឹកក្ដៅឧណ្ហ ៗ លាងឲ្យមួយស្របក់ នាងក៏ដឹងខ្លួនឡើងវិញ មើលឃើញបងប្អូនមាមីង មកជួបជុំគ្រៀបគ្រា មើលមកខ្លួនឯងសុទ្ធតែរំអិលពស់ ឆ្អាបគគ្រុក ទឹកតូចចិត្តខ្មាសគេណាស់ ក្រោកឡើងកន្ត្រាក់បានផ្តិលទឹកមួយ លើកគ្របក្បាល ដើរទៅមាត់កំពង់ ដងទឹកងូតលាងដូចម្ដេច ក៏មិនជ្រះរំអិលពស់នោះ, គិតថា ឱ ខ្លួនអញអើយ ! ម្ល៉េះទៅហើយ នឹងនៅជាមនុស្សក៏ខ្មាសគេ បើស្លាប់ទៅវិញប្រសើរជាង ក៏យកផ្តិលទទូរក្បាលដើរ ទៅត្រង់មាត់ប្រាំងអន្លង់ជ្រៅ នឹកបន់ក្នុងចិត្តថា "អញនឹងលោតទឹក សម្លាប់ខ្លួនឯងហោង" ៗ គិតដូច្នោះហើយ ក៏លោតប្រុងទៅ ក្លាយខ្លួនទៅកើតជាផ្សោតញីក្លាម មុជក្នុងទឹក ហែលចាប់ត្រីស៊ីព្រងើយ ៗ ឪពុកម្ដាយរត់តាមទៅមើលកូន ឯមាត់កំពង់ទឹករកពុំឃើញ ក៏នាំគ្នាយំសោកការខ្សោះកាល័យ រៀបរាប់រឿងផ្សេង ៗ នៅមាត់ទឹក ៗ

លុះត្រឡប់មកផ្ទះវិញ បបួលប្ដីប្រពន្ធអ្នកសូសពស់ថ្លាន់ យកទៅបោលក្នុងព្រៃធំមួយ ដោយស្មានថា ពស់ថ្លាន់ក៏ស្លាប់ព្រោះគេវះពោះ រយះជាពីរទៅហើយ, តែធម្មតាពស់ថ្លាន់ តែងមានប្រមាត់រស់ គ្រាន់តែវះពោះប៉ុណ្ណោះ មិនស្លាប់ទេ លុះតែកាប់ដាច់ជាពីរ ជាបីកំណាត់ទើបស្លាប់ ។ យូរ ៗ ទៅពស់ថ្លាន់នោះសះជារស់ឡើងវិញ ហើយតាំងចិត្តលែងស៊ី-

www.budinst.gov.kh www.elibraryofcambodia.org

មនុស្ស និងសត្វណាដែលគ្មានរោម គ្មានមមីស ។ ការដែលពស់ថ្លាន់ វែងស៊ីមនុស្សនិងសត្វគ្មានរោម ក៏ជាប់ជាទំនៀមពីគ្រឹមនោះ រហូតមក ដល់ឥឡូវនេះ ។

ឯសត្វផ្កាត់ក៏កើតមាន ពីគ្រឹមនាងប្រពន្ធពស់ថ្លាន់ រហូតមកដល់ សព្វថ្ងៃនេះ ក្បាលផ្កាត់ក៏គ្រងោលរបៀបដូចជាទទូរផ្ចិល សរីរាវយវៈ របស់ផ្កាត់ មិនខុសគ្នាពីមនុស្សប៉ុន្មានទេ ដូចជាដោះ ដូចជាប្រដាប់ ភេទស្ត្រី និងសរីរាវយវៈឯទៀតខ្លះ សឹងតែដូចមនុស្សទាំងអស់ គ្នាន តែដៃជើងប៉ុណ្ណោះទេ ។

www.budinst.gov.kh www.elibraryofcambodia.org

## ៣- រឿងកូន៤នាក់មិនបំរើឪពុក

ក្នុងកាលកន្លងទៅហើយ មានបុរសម្នាក់ជាអ្នករកស៊ីលក់ដូរ មានធនធានគ្រាន់បើ គាត់មានកូនប្រុស ៤ នាក់ មានអាយុគ្រប់ការទាំងអស់ ។

ក្រោយពីពេលដែលប្រពន្ធអនិច្ចកម្មទៅ គាត់ត្រាំនៅជាពោះម៉ាយ ពុំយកប្រពន្ធទៀតទេ នៅជាមួយនឹងកូនប្រុស ៗ អស់ ១ ឆ្នាំ មានការលំបាក ដោយខ្វះស្រីមេផ្ទះ ជាអ្នកចំអិនអាហារ និងជួយមើលថែទាំរបស់ទ្រព្យ កំប៉ុកកំប៉ុកក្នុងផ្ទះ គាត់ក៏រៀបការប្រពន្ធឲ្យកូនច្បង ហើយយកកូនប្រសាស្រីមកនៅជាមួយ ចែកទ្រព្យអស់មួយចំណែក ឲ្យដាច់ស្រឡះទៅកូនច្បងរួចទៅ ។

លុះវិលនឹងមួយឆ្នាំក្រោយមកទៀត គាត់រកប្រពន្ធឲ្យកូនទី ២ ចែកទ្រព្យ ១ ចំណែកឲ្យ ដូចគ្នា ។

តមក, គាត់រៀបការកូនទី ៣ ចែកទ្រព្យ ១ ចំណែកឲ្យទៀត ។

ដល់ឆ្នាំជាគំរប់ ៤ ក៏រៀបការឲ្យកូនទី ៤ ចែកទ្រព្យ ១ ចំណែកទៀតដែរ ។ នៅសល់តែផ្ទះ ១ ខ្នង ពុំបានចែក គាត់ទុកនៅទាំងអស់គ្នា ។

www.budinst.gov.kh www.elibraryofcambodia.org

ដែលគាត់ចែកទ្រព្យរបស់ឲ្យ ពាល់តែអស់រលីងពីខ្លួនដូច្នេះ មកពីគិតថា «ឲ្យស្រួលខ្លួនគាត់ ហើយនៅទំនេរស្ងៀម ចាំឲ្យកូនរកស៊ី ចិញ្ចឹមវិញ រហូតដល់ស្លាប់» ប៉ុន្តែគំនិតគាត់គិតនេះ ខុសស្រឡះ ។

កាលដែលគាត់នៅជាមួយកូនប្រុស ៤ នាក់ កូនទាំងនោះ ស្រឡាញ់បងប្អូនណាស់ ពុំដែលបែកចិត្តគំនិតពីឪពុក និងបងប្អូនឡើយ ។

លុះបានប្រពន្ធមករៀងខ្លួនហើយ ក៏បែកចិត្តគំនិតផ្សេង ៗ ពីគ្នា នៅរួមជាមួយគ្នា ពុំសូវបានសុខ ព្រោះតែស្ដៀបមាស់ បន្តិចពាស់នេះ បន្តិចពាស់នោះ ក៏នាំគ្នាចុះចេញ ពីផ្ទះកំណើត ទៅរកសង់ផ្ទះនៅទីទៃពីគ្នា ទាំងអស់ ចោលតាឪពុកពោះម៉ាយ ឲ្យនៅតែឯកោអនាថា ។

កាលកូនទាំង ៤ នាក់ ទើបនឹងចុះចេញ ពីផ្ទះឪពុកទៅថ្មី ៗ នៅហុចបាយ ហុចបំណី តាឪពុកបន្តិចបន្តួចរាល់ៗថ្ងៃ លុះមានកូនខ្ចីគ្រប់គ្នា ជួនប្ដីរវល់ ដើរទៅជួញស្រុកឆ្ងាយ ភរិយានៅផ្ទះ គាន់តែប្ដីមិននៅ និងគាន់មានកូនខ្ចីផង ក៏បង្អង់ជូនបាយទឹកឪពុកក្មេក ដោយខ្លះគិតថា ប្រហែលប្អូនគេឲ្យហើយ ខ្លះគិតថា បងឯណោះគេឲ្យហើយ កូនប្រសាទាំងគ្នាគិតដូច្នេះតែរៀងខ្លួន យូរៗថ្ងៃទៅ តានោះអត់បាយ ១ ពេល ក៏មាន ២ ពេលក៏មាន ។

វេលាប្ដីមកពីរកស៊ីវិញ ដឹងរឿងនេះ បានស្ដីបន្ទោសប្រពន្ធ នាងភរិយាខ្លះដោះសាថា កូនឈឺ ខ្លះថា ខ្លួនពុំនៅ រវល់ទៅជួយញាតិជិតខាង ស្រេចតែមេប្រពន្ធ រកដីកមុខយ៉ាងណា ប្ដីតាមទាំងអស់ ។

www.budinst.gov.kh www.elibraryofcambodia.org

ចំណែកតាពោះម៉ោយ អត់បាយ គ្មានសំពត់អាវស្លៀកពាក់ដល់ថ្នាក់ដើរសុំទានគេបរិភោគ រងទុក្ខវេទនាពន់ពេក នឹងលក់ផ្ទះ ១ ចាស់ទ្រាំទ្រា ពុំបានថ្លៃប៉ុន្មានផង ហើយគ្មានអ្វីនឹងជ្រកនៅផង ។

កាលនោះ មានបុរសម្នាក់ នៅកម្លោះ មានចិត្តសប្បុរស ហើយជាអ្នករៀនសូត្រ ចេះដឹងច្បាស់ទម្លាប់ ស្គាល់គុណទោសច្រើន ផ្ទះនៅភូមិជិតគ្នា ដើរមកឃើញតាពោះវេទនាដូច្នោះ មានចិត្តករុណាក្រៃពេក ក៏សាកសួរថា «លោកតា! ខ្ញុំធ្លាប់ឃើញលោកតា ពីដើម ជាអ្នកមានគ្រាន់បើ ឪពុកម្ដាយខ្ញុំ ក៏ធ្លាប់ទីពឹងលោកតាខ្លះដែរ ម្ដេចក៏ឥឡូវនេះលោកតាវេទនាពីព្រោះអ្វីម្ល៉េះ ក្រែងលោកតា មានកូនប្រុស ១ ដល់ទៅ ៤ នាក់ដែរឬ ? ម្ដេចក៏កូននោះ វាមើលចំណាំ មិនថែទាំលោកតាសោះ? ក្រែងទ្រព្យរបស់លោកតា មានសល់ទុកខ្លះដែរឬ ម្ដេចបានជាលោកតា មិនយកទៅទិញគ្រឿងបរិភោគ ប្រើប្រាស់ ?» ។

តាចាស់ប្រាប់ទៅវិញថា "ឱហ៊ឺ! លោកចៅអើយ! លោកថាពីដើមតាមានទ្រព្យគ្រាន់បើ ពិតមែន ប៉ុន្តែ តាការពារស្រឡាញ់កូនពេក ក៏ចែកឲ្យវាគ្រប់គ្នា អស់រលីងពីខ្លួនទៅ គិតថា ឲ្យវាចិញ្ចឹមតាវិញ ឥឡូវពួកវាមានប្រពន្ធហើយ ថែមទាំងមានកូនទៀត វាឃើញឯងអស់ទ្រព្យរលីងពីខ្លួន វាឥតគិតនឹកតាសោះ វាតាមតែប្រពន្ធ ទាញទៅចូលខ្ទេក្ដាម ក៏វាចូលដែរ ខ្លួនតាសព្វថ្ងៃឈឺផង នៅតែម្នាក់ឯងម៉ង ១ វេទនាថា

បំផុត ដេកតែសម្រក់ទឹកភ្នែក ដោកខ្សឹយអស់ហើយ បាយព្រឹកជាបាយល្ងាច ប្អូនកាល ឥតមួយពេលក៏មាន ទឹងធ្វើការរកស៊ីក្ដី ក៏មិនកើត ពីព្រោះចាស់ជរា គ្រាន់តែដើរ ស្ទើរតែមិនរួចទៅហើយ ដូចលោកទៅឃើញស្រាប់ តាដេកចាំតែដល់ថ្ងៃស្លាប់ទេ ។

ទៅកម្លោះលាន់មាត់ថា «យីអើ! កូនតា មានចិត្តតាក្រក់ដល់ម្ល៉ឹងហ្ន៎! បើអីចឹងលោកតាកុំភ័យ ខ្ញុំមានឧបាយមួយ ធ្វើឲ្យលោកតាបានសុខកាយ សប្បាយចិត្ត ដូចពីដើមវិញ; លោកតាធ្វើតាមខ្ញុំ លោកតារកពាង មានមាត់តូចល្មមមួយ ដុះកាបម៌ខិង៌ះឆាមឲ្យពេញ ហើយរកកំណាត់សំពត់រុំចងភ្ជាប់ ឲ្យជិត ដីកកប់ក្នុងដីជិតៈជើងបសរគ្រែងផ្ទះ ហើយបើមានអ្នកណាៈដើរមក ត្រូវលោកតានិយាយប្រាប់គេ ថា «ខ្ញុំនៅសល់កំណប់ប្រាក់១ពាង កប់ទុក ពុំទាន់ចែកឲ្យកូនណាទៅឡើយ ចាំមើល កូនណាចិត្តបាន ដឹងគុណ បើខ្ញុំទៀបស្លាប់ ទើបប្រគល់ឲ្យទៅកូននោះ លោកតានិយាយប្រាប់មនុស្សដែលជួបកុំខាន, ក្នុងរវាងបុំន្មានថ្ងៃ-ខែខាងមុខនេះ លោកតាកុំដើរសុំទានគេទៀត ចាំខ្ញុំយកបាយទឹកមកជូនពិសា កុំព្រួយ» ។

តាចាស់ ក៏តាំងធ្វើតាមចៅចិត្តសប្បុរសទាំងអស់ ។ លុះបានប្រហែល៥ថ្ងៃ សំដីតានោះ បានដឹងដល់កូនប្រុស និងកូនស្រីទាំង ៨នាក់ វាមានចិត្តលោភចង់បានកំណប់តែរៀងខ្លួន, ក៏នាំគ្នាយកបាយ

www.budinst.gov.kh www.elibraryofcambodia.org

ទឹក ម្ហូបចំណី ផ្លែឈើទុំខ្ចី គ្រប់មុខនិងភោគាហារក្រមា មកផ្គាប់ផ្គុន ជូនគាត់ពុំគរៀងរាល់ថ្ងៃ ពុំមានខានថ្ងៃណាមួយឡើយ គាត់ចាស់បានសះជារោគ មានសាច់ឈាមស្រស់បស់ មានកំឡាំងពលំ សុខកាយសប្បាយចិត្ត តាំងពីថ្ងៃនោះមក រហូតដល់អស់អាយុ ។ លុះគាស្លាប់ហើយ កូនគឺនាំគ្នាធ្វើបុណ្យឥតធិកឥតថយ តាមទំនៀមរួចស្រេច ។

កូនទាំង ៤ នាក់និងកូនប្រសា គិតនាំគ្នាគាស់ពាងកំណប់ចែកគ្នា ប៉ុន្តែក្រងចែកមិនស្មើភាគ នាំឈ្លោះប្រកែកគ្នា ក៏ទៅរកគ្រូម្នាក់ឲ្យមកជួយចែក លោកគ្រូនោះទទួលព្រម ប៉ុន្តែគាត់ឮថា កំណប់មាសប្រាក់ច្រើនដល់ទៅ ១ ពាង គាត់បង់បាន ១ ចំណែកដែរ ហើយគាត់គិតក្នុងចិត្តថា «គាត់ធ្វើមេចំណែក ត្រូវបានច្រើនជាងកូនបំណែកផង» គាត់ក៏ដើររូតរះមកដល់ផ្ទះកំណប់ភ្លាម តាំងយកក្អមធំមួយមកកុំ ជួតក្បាលធំទើងទើង ធ្វើឲ្យខ្ទង់កណ្តាល ដូចគេទូលជើងឆ្នាំងផ្សារ ក៏តាំងអង្គុយតែងខ្លួន លើផ្ទឹកបរលើង ធ្វើក្អែកសង្រ្គមស្នើនស្នាដ៏ ឈមមុខត្រង់ទៅទិសខាងកើត ហើយគាត់ប្រាប់កូនទាំង ៤ នាក់ ឲ្យទៅគាស់យកពាងកំណប់មក ប៉ុន្តែគាត់ហាមថា កុំអាលស្រាយមាត់ពាង ក្រែងខុសត្រណម ចាំគាត់បន្លាច់សិន លុះយកពាងមកដល់ផ្ទះហើយ គាត់ឲ្យកូនទាំង ៤ នាក់ឈរ គ្រប់ទិសទាំង ៤ ធ្វើក្អែក យកដៃទាំងអស់គ្នាចាប់លើកពាង ទ្រស្ពុយបិទទូលលើក្បាល ហើយសិមស្រាយចំណងមាត់ពាង

www.budinst.gov.kh www.elibraryofcambodia.org

នាំគ្នាផ្ទៀងមាត់ពាង ស្រោចកំណាច់មកលើក្បាលគាត់ បើកំណាច់ជ្រុះធ្លាក់ទៅទិសណាប៉ុន្មាន ។ ត្រូវបានទៅអ្នកឈរកំណាន់ទិសនោះ ។ កំណាច់ណាទៅសល់ ទើរលើឈ្មួតក្បាលគាត់ ត្រូវបានជារង្វាន់លោកគ្រូទាំងអស់ ។

កូនទាំង ៤ នាក់ ក៏ចាប់ធ្វើតាមបង្គាប់លោកគ្រូ មិនហ៊ានឲ្យល្អៀង ។ ភរិយាទាំង ៤ នាក់ ឈរកាន់កញ្ច្រែងខ្លួន ចាំកើប ។

កុំពេលដែលចែកកំណាច់នោះ មានអ្នកស្រុកជិតខាងទៅចាំមើលដែរ ។

និមិត្តតែគេលើកពាងចំទូលរួច ស្រាយមាត់ពាងផ្ទៀង ចាក់ឈូរមក ទឹកម៉ាំត្រាំណាមកច្រើនខ្លួច ហូរធ្វេរ ស្រោចលើក្បាលលោកគ្រូពេញគំពុង ហើយខ្ទាតផ្កាចសាចចេញទៅគ្រប់ទិស ប្រឡាក់ប្រឡូសពាសពេញមុខមាត់ទាំងសំពត់អាវ ហូតដល់នាងប្រពន្ធទាំង ៤ នាក់ទៀត លោកគ្រូបានចំណែកច្រើនជាងគេ ព្រុកិ្ខទោះ ជាទិចត្រូវ គេឃើញលោកគ្រូស្រមូវ ។ ប្រាក់មុខមាត់រូបកាន់អស់ ទាំក្រោកឡើងសោះកក្រោរ ខ្លាសអស់គួកបរិស័ទ ដែលឈរចាំមើល គួកបរិស័ទក៏ផ្អើល ទាំរត់ប្រញាប់ចេញ ប្រជេញគ្នាទៅផ្ទះរៀងៗខ្លួន ទើបលោកគ្រូស្រែកជេរ កែសំនួនទៅកូនទាំង ៤ នាក់និងកូនប្រសា ថា " ខ្លាចមេដែង កាដែនទាំងអស់គ្នា-មេគសំនេះ បានធ្វើបាបខ្លាចផុតកក្រើនណាស់ហើយមើលទៅ

www.budinst.gov.kh www.elibraryofcambodia.org

បានជាកំណាច់មាសប្រាក់ឥន្ទ្រពយ ក្លាយទៅជាគាថម៌ នោម ប្រឡាក់ខ្លួន អញ្ជូអស់ផូបេះ ឃើ! ភ្នោបគាថែះ មេគំផែះអស់នេះខូបមែន ” ។

លោកគ្រូមិនកូនសិស្សនាំគ្នាតែហើស លោកខម្ចាក់ខ្លួនទៅក្នុងទន្លេ ប្រេង ទំត្រាំទឹកលាងបាបអស់ ១ មោងម្នាក់ ១ រូបនាំគ្នាឡើងទៅលើផ្ទះ រៀង១ខ្លួន បានសេចក្ដីក្ដៅក្រហាយ ស្ដាយក្រោយ ភ្នាសគេតកូនតទៅ ។

---

www.budinst.gov.kh www.elibraryofcambodia.org

# រឿងមារយើង (១)

## បទកាកគតិ

អញខ្ញុំក្រួញក្រាប សិរសាស្របផ្ទាប់ លុតលើមហាគ្គា ទសន្តលី អភិវន្ទា នៃព្រះពុទ្ធជា ឥស្សរគតត្រៃ ។ ព្រះអង្គឧត្តម លើសលើឥន្ទព្រហ្ម មូលមគភក្តី ប្រកបប្រការ សម្ភារវិទ្ធិ បរិបូណ៌បារមី ពិសេសថ្កើនថ្កាន ។ បង្គំព្រះធម៌ ពិសេសមានគាថ ជ្រៅពន់ប្រមាណ ស្មោះស្មើកេត្រា ថ្ងៃថ្លាមែនមាន បវរចិត្តញ្ញាណ ផ្ដុំផ្គុំសព្វសត្វ ។ បង្គំព្រះសង្ឃ ប្រសើរឧត្តុង្គ ឧត្តមពេកក្ដាត់ គាប់នាំសត្វធ្ងន់ រំលងភពវដ្ត ផល់ឋាន អមតៈ(២) បុរីនាយណា ។ ទើបខ្ញុំបង្គំ ទិព្វទេពឧត្តម សោឡសសួគ៌ា សូមសុខសួស្តី សិរីទីឃា- យុយឺនសុខា- ប្រាយបរិបូណ៌បុណ្យ ។

ស្រេចខ្ញុំនឹងថ្លែង ដំណើរតំណែង ដំណាលពីមុន មានក្សត្រ មួយថ្ងៃ ប្រពៃលើសលន់ គ្រប់គ្រងមហាជន ក្រុងពារាណសី ។ ព្រះនាមព្រះបាទ ព្រហ្មទត្តនរនាថ លើសលើលោកិយ ប្រកបដោយ

---

១– ច្បាប់សាស្ត្រាស្លឹករឹត តំកល់នៅបណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ លេខ ១.៤៥៨ ។

២– ឋានមិនស្លាប់ គឺព្រះនិព្វាន ។

www.budinst.gov.kh www.elibraryofcambodia.org

ភរិយអគ្គមហេសី កបគលក្សណី រូបវន្តសោភា ៗ ព្រះស្នំសាវ៉ៃផ
ពិសេសច្រើនក្រៃ សម្រាប់ក្សត្រា គង់គាល់សព្វថ្ងៃ ក្រាសក្រៃគណនា
ប្រជុំពាក- ករវៀបវៀងកាយ ៗ មន្ត្រីយោធា ស្រមណ៍ព្រាហ្មណ៍-
គណា- តាវ្យបេះព្រាជព្រាយ សម្រាប់មហាក្សត្រ ព្រហ្មទត្តរិទ្ធិសាយ
ពលពាលតាំងព្យាយ អនេកសំខ្យា(១) ៗ ស្តេចសោយកព្យស្តុល់
ឥតកោលាហល វឌ្ឍកស្រួប្រជា ទ្រង់ទសពិធរាជ អង់គាចកាសា
គាស្សុរករុណា ចំញុំមវៀនវង ៗ ក្សត្រក្សត្តុសោយកព្យ ថ្កើនព្រះ
អំណាច ឥតបីផ្ទឹមផង ស្តេចផ្ចាញ់សត្រូវ គាស្រូវយន់យ៉ន ពុំអាច
ប្រឡង សុខសល់លើសលន់ ៗ កាលនោះមានមា- ណពនៅភាគ
ក្សត្រថ្ងៃមានបុណ្យ ជាអ្នកទុគត ក្សីណក្សត់ទ្រព្យធន តែប្តីប្រពន្ធ
និត្យនៅសព្វថ្ងៃ ៗ ភរិយានោះណា មានរូបសោភា ស័ក្តិសមល្មមលួ
តែចិត្តនោះមិញ កំណាញ់ក្រៀតក្រៃ ព្រៀនលានទីទែ គេពុំចូលចិត្ត ៗ
មានកាលមួយថ្ងៃ ហៅមាណពនៃ ទៅរកជញ្ជូត ខឹងភរិយាប្រាណ
ដោយដានកំសត់ ពិបាកពេកក្តាត់ ទុគ៌តក្រៃក្រៃ ៗ ភរញ្ញសោកច្ចុះ
ដាចដាច់វល្លុះ ដោយមុខនោះនៃ រឯភរិយា ឥតអញ្ញាស្រ័យ ពុំគន់វិតែ
ថៃចាំឡើយហោង ៗ ព្តីតែឥងញ្ញាក់ ដាក់ទៅជ្រុះបាត់ តាមមុខនោះផង
ឥតស័ព្ទឥតសារ ឥតការជាម្ពង់ ហេតុឥតចិត្តបង់ រំពឹងនាំពា ៗ

១– អនេកសំខ្យា ច្រើនរាប់ពុំបាន, រាប់ពុំអស់ ។

www.budinst.gov.kh www.elibraryofcambodia.org

ផញ្ញាក់រៀនទៅ ដួចដល់សំពៅ នាវមហិមា រីនាយសំពៅ និទ្រានៅ

ភរិយា មើលពីគ្រោ យល់កញ្ជើផ្ទុះ ។ នាងនាយគ្រោ ស្រដីទៅថា

នាងផញ្ញាក់នោះ ម្តេចពុំដឹងគ្មើ កញ្ជើនាងផ្ទុះ យកស្ទុចកចុះ សោះក៏

លេចបាន ។ ក្សិណនាយសំពៅ ក្រោធស្រែកថាទៅ ឯងភរិយាប្រាណ

បើបេះផ្ទោះ មិនចុះទៅថ្កាន កាន់កញ្ជើបាន ជាប្រពន្ធក៏ ។ ឥឡូវឯង

ចូរយក ប្រពន្ធក៏មក នៅលើគ្រោ ជាប្រពន្ធឥឡូវ វិលវិញហោងណា៎

ក្សិតទៅជានឹក បង្គាប់ខ្លួនថៃ ។ នាងស្តាប់ប្តីថា ឯងផ្ទូរភរិយា ឯងឲ្យ

ទៅគេ ដោយពាក្យពុំស្រួល ពុំគួរបើផេរ ខ្លួនគ្មានទោសទេ ម្តេចបង

ទោសា ។ ទើបនាងឆ្លើយទៅ កាន់នាយសំពៅ ជាប្តីភគ្នា ពាក្យខ្ញុំ

ប្រគោះ លើសលស់ត្រង់ណា ក៏ដល់អ្នកជា ប្តីពុំយល់គិត ។ ឯងយក

ខ្ញុំទៅ ជួរមាណពនៅ កាន់ឈ្មោះផញ្ញាក់ បើអ្នកផ្ទូរទៅ ខ្ញុំនៅឯងគាត់

ខ្ញុំសោកគ្មានមាត់ ប្រកែកថាអ្វី ។ ទើបនាយសំពៅ ស្រែបស្រែក

ហៅទៅ ពុរសនោះខ្វី ៥.ហៅហឹនផ្ទូរ ប្រពន្ធប្តី មកកាយស្រដី

ឲ្យដាក់ឧបត្ថ ។ មាណពផញ្ញាក់ ឮនាយនោះគាត់ សុំដូរភរិយា

ភ្ញាចខ្លួនពុំហ៊ាន ទៅថ្កានគ្រោ នាយនោះរៃងថា ហៅខ្លាំងៗទៅ ។

ទើបមាណពនោះ ទន្ទុចចូលស្មោះ ឡើងលើសំពៅ ពាំងប្តីប្រពន្ធ

គន្លុយនិទ្រានៅ ទៀបនាយសំពៅ ស្រដីទៀតថា ។ ហៅអើយកុំយូរ

មកយើងឯងផ្ទូរ ប្រពន្ធឥឡូវ ឥឡូវប្រពន្ធ ឥឡូវទៅហៅណា៎ ហៅឲ្យ

www.budinst.gov.kh www.elibraryofcambodia.org

ភរិយា ទៅមកអញហោង ។ មាណពកំសត់ ស្ដាប់យល់ពាក្យបទ ពុំហ៊ានសាសង នាយនោះវង្វេង ផ្ទួនៗ ច្រើនផង ថាហើយថាផង ជាច្រើនភាសា ។ ទើបមាណពនោះ ថាតាមចំពោះ ចិត្តអ្នកទោនណ៎ា ខ្ញុំជាអ្នកហោច ក្រមោចកំព្រា ឥតបើនឹងថា ពាស់វែងសេចក្ដី ។ នាយសំពៅស្ដាប់ អស់អធិសាស័ក្តិ ត្រេកអរពេក ក្សេមក្សាន្តក្នុង ដណ្ដឹងឃ្លាតខ្លី ថាថៃហប្អូនស្រី ឯណាះសោកហោង ។ ថានាងប្អូនស្ងួន ស្នេហ៍ស្មាលចូលចិត្ត ព្រមមូលទឹកចង ប្ដូរយកពុំបូល ពុំចូលចិត្តបង ចូរទៅសាសង ផ្ទៀវនេះណ៎ា ។ ឯមកពេញ្ញ. ចុះអស់លោលើ ចង់នាយ នាក់ សើចហើយញញឹម មើលចុងខ្មៅ ទុនហើយទើបថា ក្ដី ព្រានហោង ។ ឯនាងភរិយា ទៅនាយកំត្រា ស្ដែងស្ដាប់សាសង ប្ដីប្ដូរ ផ្ដែផ្ដាច់ ពាក្យពេចន៍ជាម្ដង នាងចរចុះផ្គង ពីលើកំត្រា ។ តែស្បៃនៅក នាងដើរចុះមក កាន់ប្ដីកំព្រា ទ្រព្យធនពុំយក ដិតមកតាក្នា នាងឈោង ប្រាក់ កញ្ចើកាន់ទៅ ។ ពោចឲ្យានសម្រោម មកចុកដងក្ដាម ពិតពុំ ខ្សែសៅ នាងកាន់តាមប្ដី ផញ្ញើកតាមស្នៅ ភានស្រែចទើបទៅ ហានប្ដី នោះណ៎ា ។ លុះដល់លំនៅ នាងផណ្ដឹងទៅ កាន់ប្ដីនាងថា អ្នកអើយ អស់ផ្ទះ ទៀតនាងនេះណ៎ា ជាញាតិកា សន្ដានពៅណា(១) ។ ប្ដូជា ព្រៀនសាន ឥតខ្ញុំពុំមាន ពីនញាតិមិល បើអ្នកឯណា ជាញាតិចាវ

---

១- គួរតែជាសន្ដានពៅព័ន្ធ, តែទាស់នឹងប្អូនខាងមុខ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រៀងលានស្មោះសរ អ្នកប្រាប់ខ្ញុំក៏ ។ ប្ដីឆ្លើយវិលទៅ នាងភ័យ
ញាតិផៅ បងគ្មានទេណា៎ ស៊ឹងតែព្រៀងលាន នៅឋានទៀបគ្នា សត្វ
ថ្ងៃកំព្រា គ្មានបងប្អូនឡើយ ។ នាងឮប្ដីថា ផងញាតិវង្ស កំព្រា
ហ្នោះហើយ ហេតុនាងសប្បុរស យកគេជាត្រើយ នាងពុំគិតឡើយ
កំសត់កាគ្នា ។ នាងយកត្រីនោះ ឲ្យប្ដីនាងស្មោះ ជូនចែកគ្រប់គ្នា
មិត្រគ្រប់មុខ អ្នកស្រុកនៅនា ព្រៀងលានស្គាល់គ្នា ទេត្តាឯលំនៅ ។
ប្ដីសោកទៅស្មោះ ដោយប្រពន្ធនោះ បណ្ដាប់ប្រផៅ កាលនោះព្រៀង
លាន នាងឋានលំនៅ ស៊ឹងគិតថាចៅ នេះផែលឯណា ។ សប្បុរស
ផ្ទះនេះ ផ្ញើលគ័ម្ដងនេះ ជូនយើងគ្រប់គ្នា សត្វជនកំណាញ់ កន្ទ្រើស
ម្សា ឥឡូវម្ដេចជា សប្បុរសពេកក្រៃ ។ អ្នកផងគិតហើយ ពិតពុំ
លង់ឡើយ មានកាលមួយថ្ងៃ គេដើរទៅលេង ទឹងមាណពតែង យល់
នាងប្រែត មានរូបសោភា ។ ទើបគេគិតថ្ងៃ ថាចៅនេះនែ គាត់បាន
ករិយា ទៀតទើបសប្បុរស ពុំដូចសត្វគ្រា នាងនេះលក្ខណា មារយាទ
ហ្មត់ហ្មង ។ មានកាលមួយថ្ងៃ មាណពទៅព្រៃ រកកាប់ឧសបង បាច់
បានរែកមក ដូចកាលសត្វផង រីឈើនោះផង ពុំឈើទ្ឈា ។ ស៊ឹង
ឈើប្រៃត មែនមានតម្លៃ គ្រាំពាក់ក្រស្នា នាងយល់ឧសប្ដី បានពីព្រៃក្សា
ស៊ឹងឈើជា ។ មាន ។ តម្លៃ ។ នាងគិតឯងថា ប្ដីអញនេះណា៎ បាន
ឈើប្រៃត ពុំស្គាល់ជាឈើ នោះមានតម្លៃ យកមកសត្វថ្ងៃ ដុតផ្ទះ

www.budinst.gov.kh www.elibraryofcambodia.org

ណា៎ ។ សមះឈើនេះមាន ក្រាស់ក្រៃនាហ្ន កាយឯងទើបជា–
ទោសអស់អ្នកផង ពុំស្គាល់ក្រស្នា ក្លាំពាក់យកជា ទោសឥតគិតឡើយ ។
ទើបនាងនារី ផណ្តឹងទៅប្តី ថាហៃអ្នកអើយ ទោសនាព្រៃកាយ អស់ខែ
ម្ល៉េះហើយ ចុះមួយនៅឡើយ អ្នកប្រាប់ខ្ញុំភ៏ ។ ប្តីឆ្លើយវិញទៅ មាន
ប្រើនក្តាត់នៅ នាព្រៃព្រឹក្ស យកបានជាយេ របេះក្តីណា ពុំអស់ចូនក្ប
នាងនឹងគិតថ្មី ។ នាងពុំឈ្នះណា៎ អរកែកណានា សំណេះនឹងប្តី
ឈ្មោះអ្នកទៅរក យកមកទៀតខ្ញី ឲ្យអស់អំពី ព្រៃនោះឯងហោង ។
មិនដូចរះ ញាតិជិតនៅនេះ ជីកទុកជាមួន ប្តីថានាងនឹង យកទោស
ថ្វីផង បើអស់សឹមបន់ រកមកទៀតណា៎ ។ ទើបនាងតួស់ឆ្លើយ
ថាអ្នកប្តីអើយ ឈើនេះឈើជា សិនមានកន្ទ្វ ក្លាំពាក់ក្រស្នា អស់អ្នក
កេត្រា គេទិញយកទៅ ។ ឈើនេះខ្ញុំស្គាល់ ជាតិឥតពិការ អស់
អ្នកសំពៅ គេទិញមិនលែង ខ្ញុំឯងឃើញទៅ គេទិញនាំទៅ ស្រុកចិន
នាយណា៎ ។ បើយើងបានហើយ យើងគិតឡើយ លក់តែក្រស្នា
ក្លាំពាក់ប្រៃព យកថ្វីមកណា៎ ទិញព្រៃកាសាយ៍ សំពត់ជាតិ ។
តាមតែចិត្តជ្រើស ចិត្តទីនស្រឡាញ់រើស យកប្រាក់មាបក្តី ហោះបចិត្ត
ស្រឡាញ់ ចន់ទិញអ្វី ៗ អ្នកទៅវិញខ្ញី តាមពាក្យខ្ញុំថា ។ ប្តីព្រះឈ្មោះនៃ
អរឯងពេកក្រៃ ក្រទីក្រតា បានអម្រែកសារ្ទែក វៃគរឡើយម្នា ដីង
កាំចិតព្រា ចូលទៅក្នុងព្រៃ ។ កាត់នរទុកស្រេច ចង់ទៅលជាបាច់

www.budinst.gov.kh www.elibraryofcambodia.org

រែកមកពីថ្ងៃ ហើយប្រាប់ភរិយា ប្អូនអើយៗសថ្ងៃ កាត់គរនៅព្រៃ ច្រើនក្រៃក្តាត់ណាស់ ៗ រែកមកនេះហោង តាមកម្លាំងបង ទើបនាង ភរិយា រកជួលរកេះ ដឹកនាំក្រស្នា ក្អាំពាក់ផា១ ពីព្រៃនោះនែ ៗ គរទុកតាស្ពាន នោះហើយទើបនាង ពាណិជទិន មកទិញក្រស្នា ក្អាំពាក់ប្រពៃ នាងកូនកាត់ថ្លៃ ឥតល្មៀងឡើយណា ៗ ហេតុនាង នារី ដឹងឥសំអំពី កាលនាងនៅជា ប្រពន្ធនៃពៅ មាយាភារកេត្រា ឥតឈ្មួញណា១ បញ្ឆោតបានឡើយ ៗ លុះឈ្មួញទិញបាន ពីនាង កល្យាណ គេយកទៅហើយ នាងរៀបទុកទ្រព្យ ផ្គូផ្គាប់ជាត្រើយ ពិតពុំលស់ឡើយ រណ្តាប់ត្រឹះហាន ៗ ចាយចាស់រៀបរក៍ លោះខ្ញុំកំដរ ប្រកបធនធាន អ្នកផងចេញចូល នាងសោកថ្កើងថ្កាន សម្បត្តិមូល មាន អនេកទ្រព្យ ៗ ប្តីនាងនេះនែ បានស្គាល់ទៅទៃ ស្គាល់ព្រះ ស្គាល់ពញា អ្នកផងរាប់អាន តៀតបានទ្រព្យ គបនូវលក្ខណា នាង នោះប្រពៃ ៗ ទើបនាងនារី ស្រដីនឹងប្តី ថាអ្នកសព្វថ្ងៃ ខ្ញុំចង់ឲ្យអ្នក រៀនរត់ឲ្យវៃ ឲ្យរួសរាប់ក្រៃ ដូចចិត្តចិន្តា ៗ ប្តីសោកថ្លាស់ថ្លើយ ថាហៃនាងអើយ បងឥតបើថា តាមចិត្តប្អូនហោង គញ្ញបងបានជា ម៉ែះតៀតនរណា មិនតៀតប្អូនស្រី ៗ លុះថ្ងៃមួយណាស់ នាងរៀប ក្រយា សំណុំវេចខ្ចី ទឹកមួយបំពង់ នាងជូនឲ្យប្តី ពុនរែករត់ខ្ចី សព្វ១ វេលា ៗ ដើរឡើយរត់ហាត់ ជន្ហើមផុត១ ស្ទើរដាច់ខ្យល់ណាស់

www.budinst.gov.kh www.elibraryofcambodia.org

រត់វិលមកវិញ ប្រាប់ប្រពន្ធថា ក៏ហត់ក្អាត់ណាស់ ដូចនឹងស្លាប់ហោង ។ លុះដល់ពីរថ្ងៃ ទើបរត់ទៀតវៃ ដោយចិត្តបំណង នឹងបង់ឲ្យបាន ដូចក្តីប៉ុនប៉ង ប្រាថ្នានោះហោង ចិត្តបងសង្កាត ។ រត់ទៀតដល់ទី ដើមកាលរត់ទ្វី ដោយចិត្តខ្វីឃ្លាត ត្បិតប្រពន្ធថា បងចាំតុំឃ្លាត វេទនំសង្កាត ដូចក្តីប្រាថ្នា ។ លុះប្តីនាងរត់ រត់រួចពុំហត់ ដោយចិត្តសោះសា ឯនាងនារី យល់ប្តីមាត្រា បរិបូណ៌ហើយណាស់ ទើបនាងនាប់ពៃក្រ ។ ទៅបានមន្ត្រី ឲ្យគេថ្វាយប្តី ជាខ្ញុំក្សត្រថៃ មន្ត្រីនាំថ្វាយ ដូចចិត្តនាងវៃ បម្រើសព្វថ្ងៃ ជាខ្ញុំរាជា ។

## បទភុជង្គលីលា

នឹងថ្លែងសម្តែងបទពា ឯមហាក្សត្រា ព្រហ្មទត្តធិបតី ។ សម័យ ១ ថ្ងៃចក្រី ឲ្យប្រាប់សេនីយ សេនាពលផង ។ ត្បិតក្សត្រព្រហ្មទត្ត ជាប្សង មានព្រះបំណង ប្រពាតព្រឹក្សា ។ ឲ្យរៀបប្រុងប្រៀបបណ្ណា ការកបយសា – ធិកដស្តេចស្តង ។ ភ្នាក់ងារខ្មាន់ការតាក់តែង រៀបគ្រប់តំណែង ដំណើរក្សត្រា ។ ឯទៅនោះនៅគ្រឹហា ប្រាយប្រាប់ករិយា នាងកើយផ្សូវ ។ ព្រះបាទនរនាថឥតតូ ស្តេចតែងពលព្យុហ៍ ប្រពាតព្រឹក្សា ។ ចូរទៅជូនទៅពុំងា ប្រដាប់ប្រដា ឲ្យបងតាប់ថ្វាត់ ។ នឹងទៅហែហមចក្រវត្តិ ព្រះបាទព្រហ្មទត្ត ឥស្សរសិរសា ។ នាងស្តាប់

www.budinst.gov.kh www.elibraryofcambodia.org

សាសត្តថា នាងរៀបក្រយា ឲ្យប្ដីស្នេហ៍ស្នាល ។ អង្ករសោតល្អក្រអាល
អប់ផ្កាក្រអាល ប្រហើរឈ្ងុយឈ្ងប់ ។ អាហារគ្រាលសាយសព្វ
រណ្ដាប់គ្រាន់គ្រប់ ឲ្យប្ដីស្នេហា ។ រុំផាសំណុំហើយណា ជូនផាក្រយា
ស្ងោយមហាក្សត្រថ្លៃ ។ នាងផឹងជំណឹងនោះវៃ ថាក្សត្រទៅព្រៃ នឹង
ព្រាត់គ្នានី ។ ខឹងឃាតកាមាត្យមន្ត្រី មានប៉ុន្មានប្ដី នាងនឹងតុនទៅ ។
ឯមហាក្សត្រាចមទៅ ព្រឹកព្រានព្រាលព្លៅ ប្រដាប់ព្រះអង្គ ។ ទ្រង់
គ្រឿងរុងរឿងបញ្ចង់ ព្រះពស្ត្រទិព្វទ្រង់ ប៉ាក់ផ្កាក់មាលា ។ ទ្រង់
ស្រេចសម្ដេចកជា ស្ដែងស្ដេចយាត្រា ឡើងលើអស្សតរ ។ ចេញ
ទៅដល់ក្រៅនគរ ព្រះមន្ត្របើកបរ រមកផងអស្សពាហ៍ ។ កុំកុសខ្ពង់
ខ្ពស់សោភា ឆត្ររួតជួរចា- មរមាសរៀងកាយ ។ អភិរម្យត្រសុំក្រសាយ
ក្រសែតរកាយ រំភើយសាត់សែង ។ សេនា យាធាខ្វះខ្វែង ករកាន់
លំពែង វែហ ៗ ប្រូងប្រាង ។ ដាវខែលស្រោស់ក្រែលសន្ធាង សេនា
កាន់កាង ខ្លួនតាំងតាមវី ។ មហាក្សត្រព្រហ្មទត្តបក្រី ឯកឯងពីសី
ពាលពេញតលា ។ ដល់គុងកំឡុងព្រឹក្សា ស្ដេចបរអស្សពាហ៍ លឿន
លន់កន្ទង ។ សេនាហោធាពលផង វែងទំក្កាត់ហោង ពុំទាន់ក្សត្រា ។
ផិតដោយតាមក្រោយអស្សពាហ៍ ប៉ុន្តែទៅខា- ណាតនោះឯងហោង ។
ក្សិតតាត់តែស្ទាត់កន្ទង ទាន់ក្សត្របញ្ហាស់ច្បង បមបក្រកដា ។

www.budinst.gov.kh www.elibraryofcambodia.org

# បទកាកគតិ

ព្រះបាទក្សត្រថៃ ផល់ដើមព្រះវៃ្រ បញ្ជប់អស្សពាហ៍ ព្រាត់ មុខមន្ត្រី សេនីយសេនា យល់តែចៅមា- ណពនោះឯងហោង ៗ ទើបក្សត្រចមចៅ ឈប់នៅយូរទៅ ពុំយល់មនុស្សផង ស្តេចឃ្លាន ក្រយា- ស្មោយមហាក្សត្រហោង គ្រមោបកខ្វន តែមិនមាណព ៗ ទើបព្រះព្រហ្មទត្ត- ធិកជបមក្សត្រ លើសសើលោកា សន្តតនាមនៃ មាណពនោះណា ឲ្យហៅចៅមា- យើងយសពណ្ណកយ ៗ ស្តេច សព្វហម្ចយ ក្រសាលនៅនៃ កំឡុងព្រៃនាយ ស្តេចលីលាលេង ព្រឹក្សពណ្ណកយ សាន្តសុខសប្បាយ ទតព្រៃព្រឹក្ស ៗ ស្តេចត្រាច់ ក្នុងព្រៃ ឥតអ្នកណានៃ ទឹនពាន់ក្សត្រា សីនរកក្សត្រថៃ សព្វព្រៃ ព្រឹក្ស ខ្លាបខ្វនក្លាក់ណា រកមិនឃើញឡើយ ៗ រីឯព្រះបាទ ព្រហ្មទត្តនរនាថ លីលាឡើងហើយ បន្ទូលនឹងមា- យើងថាចៅអើយ ថ្ងៃពន់ពេកហើយ អញឃ្លានបាយ ៗ ខ្លួនអស់គ្នា មន្ត្រីយោធា បក្សត្តិចាំងឡាយ សីនតែពុំយល់ រហ័តលព្រាត់ព្រាយ បែកផ្លូវ ភ្លាត់ភ្លាយ អស់ពុំយល់ណា ៗ មាយើងទូលទៅ បពិត្រចមចៅ លើសលើលោកា បាយអញខ្ញុំមាន គឺមោះខ្ជា ពុំខ្វះក្សត្រា- ធិកជ សោយសល់ ៗ ស្តេចស្តាប់ហើយណា ថាយកមកក៏ កុំគិតសល់វល់ ពោះល្អមិនល្អ ឡើសតាមកល អញឃ្លានណាស់សល់ អត់ឯណាបាន ៗ

www.budinst.gov.kh www.elibraryofcambodia.org

ទឹកតើញាំងទេ៍ ធ្លាក់សំរិបទៅ ប្តូរមួយពុំបាន មាយើងខ្វល់ទៅ
បពិត្រក្សត្រក្សាត្ត វីទឹកសោកមាន តែមោះតែថា ៗ ដាក់ទឹងបំពង់
ពុំស្ងួព្រះអង្គ ស្តេចសោយទៀយណា ស្តេចស្តាប់ថាទៅ យេទៅ
កុំថា ឈ្មោះបៅម្ចាស មកបកធាប់ ១ ៗ ក្សិណទៅមាយើង
ម្ចាដោះឡើង ទៅយកប្រដាប់ ដាក់ទឹកបំពង់ សំណុំបាយស្រាប់
ស្រេបស្រាយផ្គត់ផ្គង់ ថ្វាយមហាក្សត្រា ៗ ស្តេចសោយអាហារ
មាយើងត្រកាល មានសេពិសា បាយបរិសុទ្ធ អង្គនោះណា
ដូចព្រះក្រយា ស្តេចសោយប្រក្រតី ៗ អាហារពិសា តាមព្រះ
ឧស្សាហា ក្សត្រក្សត្របក្រី បន្ទូលសរសើរ ថានេះមែនស្រី ប្រដាប់
ចំណី ពិះសសពិសា ៗ ប្រពន្ធមាយើង រេះរៀបថ្កុំថ្កើង ម៉ុទទៅ
មែនណា ទៅមើលអាហារ ត្រកាលពិសា សឹងជាតិឧត្តម- រស
ត្រកាលក្រៃ ៗ ដូនលើគម្ពាន ឯណាមកមាន អាហារក្នុងព្រៃ
ខឹងថាក្សិតឃ្លាន ក្នុងពិសាក្រៃ មិនឈ្មោះឡើយនៃ បំណាំនេះជា ៗ
មាយើងបង្គំ មហាក្សត្រឧត្តម ឥស្សរសិរសា លុះស្តេចសោយសល់
ស្តុលមហាក្សត្រា ស្តេចសោយឥន្ទ្រា បំពង់នោះនៃ ៗ ទឹកសោត
ពិសា គប់អស់ក្តុនក្តា ពិដោរប្រពៃ ស្តេចថាទឹកទៅ រសពិសាក្រៃ
ឧត្តមតាមថៃ រេះរៀបខ្សែប្ត ៗ មាយើងនោះណា បង្គំក្សត្រា
លើកផែលមកឆ្វៃ ធ្មប់ស្កប់ស្កល់ បរិបូណ៌អស់ក្តី ទើបព្រះបក្រី

www.budinst.gov.kh www.elibraryofcambodia.org

បន្ទូលទៅថា ៗ ចៅមាយើងអើយ អញហូបបាយហើយ មិនះបះ
អត់ស្លា ចៅឡើងទៅ មកឯណាយកំ អញនឹងស៊ីស្លា ឥឡូវនេះនែ ៗ
ចៅមាយើងថ្វាយ ក្សត្រថ្វៃពណ្ណកាយ ដោយព្រះហ្ឫទ័យ ស្ដេចសោយ
ស្លាទៅ ចាំយើងនោះនែ មានសត្វគ្រប់ក្រែ ឥតខ្វះឡើយណា ៗ
តាំងទេពតារូ ក្រវាញកាំភ្លូ ស្លាខ្ចីសោតណា ក្រមួនមាត់ផង ព្រះអង្គ
សោយស្លា ហើយទើបត្រាស់ថា ស្លាទៅនេះនែ ៗ សត្វគ្រប់
មានមិញ ដូចកលស្លាអញ តែងធីសត្វថ្ងៃ ភ័ព្វអញឯងហើយ ចៅអើយ
តាប់បែ អញបានអាស្រ័យ ចៅសត្វគ្រប់ហោង ៗ បើអញបានដល់
ទីឋានមណ្ឌល ឯនាយហើយហោង អញឲ្យយសទៅ ជាធំក្នុង
ចៅកំសត់ផង អញតាសូរទៅ ៗ បន្ទូលហ្នឹះហើយ ក្សត្រា
ត្រាណាត្រើយ ប្រះផ្ទុំលើគ្នៅ មាៈយើងហើយថា ចៅអើយនែទៅ
ស្ដាប់អញនឹងនៅ និយាយមួយហោង ៗ ស្ដាប់ណាំចៅគាយ ដំណើរ
និយាយ ព្រេងព្រឹទ្ធក្នុង អញនៅថ្វាថ្វង សំដែងទំនង និតាន
មួយហោង តាំព្រេងអតីត ៗ ពុំតាន់និយាយ ដំណើរអតិត្រាយ
សណ្ដាប់ផលមា- យើងស្ដេចផ្ដុំលក់ សាន្តសុខមហិមា ក្រោមដើម
នៃមហា- និគ្រោធនោះនែ ៗ វេលានោះណា មែនមានទេវតា
រក្សាព្រះដៃ ឮព្រះព្រហ្មទត្ត មហាក្សត្រដៀសួស៊័យ ស្ដេចបន្ទូលរៃ
នឹងមាយើងថា ៗ ស្ដេចនឹងនិយាយ ទេពតាតាំងឡាយ បបួលគ្នា

www.budinst.gov.kh www.elibraryofcambodia.org

មកមីរលើព្រៃ ស្ដាប់ស័ព្ទក្រៀត យល់ស្ដេចនិទ្រា ពុំបន្ទូលទៅ ។
ទេវតាទឹងក្តាក់ ខឹងព្រះព្រហ្មទត្ត- ធិកជបមហៅ ថាក្រៀតនេះណា
មុសាក្រៃក្រៅ ពោលពាក្យអាសៅ ពុំកាន់ពាក្យសត្យ ។ ឈ្មោះយើង
អក់ធ្មី ស្ដេចកាលអស្រ័យ កាប់មែកព្រៃថ្នាក់ ទំលាក់ទៅលើ សង្កត់
មហាក្រៀត ឲ្យស្ដេចបង់ផុត ព្រះជន្មជីវី ។ ថាបើពុំមាន នៅនេះ
ព្រៃនិមាន ស្ដេចទៅបុរី យើងកាប់ខ្មោងតារ សង្កត់បត្រី ព្រហ្មទត្ត-
តិរ្យយ ឲ្យក្ស័យជន្មា ។ ថាបើបាននៅ លុះស្ដេចចូលទៅ ដល់លើ
ក្រឡា បន្ទំមន្ទីរកែវ កែស្ងាត់និទ្រា យើងប្រែកាឡា ជាពស់ទៅខាំ ។
ស្លាប់ស្ដេចក្ស័យកក ថាហើយដេកលក់ ឲ្យតែយើងចាំ មាយើងនឹងឲ្យ
អន្ទុយតែចាំ ឮពាក្យផ្តាំ ៗ ដាំ ៗនោះណា ។ មាយើងជាស់ស្ដេច
ធាប់មួយរំពេច ទើបទូលទៅថា បពិត្រស្ដេចឡើង ដរនេះសុក្រ ធាប់ៗ
មិត្តា ឥឡូវនេះនៃ ។ ក្រៀតមានទេវតា និត្យនៅរក្សា លើដើមព្រះព្រៃ
ទីនេះស្ដេចដឹង និយាយហើយនៃ ផ្ដុំលក់រីនីវ សៀមស្ងាត់កាសា ។
ខ្ញុំចាំស្ដេចផ្ទំ រលើវទៅខ្ញុំ ឮពាក្យទេវតា ស្ដេចស្ដាប់មាយើង ស្ទុះឡើង
អស្សោពាហ៍ បំបាយមិត្តា មាយើងដោយដិត ។ ក្រៀតណាមែកព្រះព្រៃ
ធ្លាក់ផុតក្រៀតថ្ងៃ ព្រះបាទព្រហ្មទត្ត ស្ដេចទៅរមូន ពីភ័យមរណ៍ថ្នាក់
ទើបមាយើងគិត ទូលទៅទៀតថា ។ បពិត្រព្រះគុ- ណរាជឥស្សូរ
នេះឯងមួយគ្រា មួយទៀតខ្ញុំឮ ពាក្យអស់ទេវតា ថាផល់សីមា

www.budinst.gov.kh www.elibraryofcambodia.org

ព្រះឥន្ទ្រាយនោះ ។ ខឹងកាច់ខ្នានទ្វារ សន្ធឹកក្ដុកក្ដាល វិលវិញ
ទៀតស្មោះ ថាបើកខ្លួន ឡើងពីនោះ លុះព្រះឥន្ទ្រនោះ ចូលក្នុងបន្ទំ ។
ខឹងប្រែកាយា ជាពស់មហិមា ទាំងក្រេវក្រោធ បពិត្រក្សត្រា គេពគាជំខ្ញុំ
ដូច្នោះនេះខ្ញុំ ឮដាក់ដាម្ទូន ។

## បទពំនោល

មហាក្សត្រព្រហ្មទត្តបព្វាស់ចង្អៀន ស្តេចស្តាប់ទំនង ទំនួលនៃចៅមា-
យើង ។ ទើបមហាក្សត្រាផ្តល់ថ្កើង ថាចោរមាយើង ប្រយ័ត្ននៅខ្នានទ្វារ
នោះ ។ ចៅការរំពាត់ពត់នោះ បៀសដួយគៀនស្មោះ ឲ្យរួចពីភ័យទ្វារ
ធំ ។ ស្តេចមានព្រះទ័យបារម្ភ បារសេរទៃនាំ លុះទៀបនៃខ្នានទ្វារនោះ ។
ក្សត្រថ្កើងមាយើងពត់នោះ សេះសោកលោកស្ដោះ ប្រៀបប្រួចគ្រលួច
មហិមា ។ បាក់ខ្នានទ្វារពេជសីមា ដុតមហាក្សត្រា កំរួចរម្ងន់ពីភ័យ ។
លុះផល់មណ្ឌលទិព្វថ្ងៃ ចៅមាយើងវៃ ក្រោមលាទៅក្តានគ្រេះហ៊ន ។
ព្រះបាទព្រហ្មទត្តទ្រង់មាន បន្ទូលត្រាំក្តាន ថាចូរចៅទៅហានណាំ ។
ហើយចៅវិលវិញយាត្រា មកគាប់មិត្តា ចៅចាំជួបចៅឮហោន ។
មាយើងក្រញាក្រាបទូលស្នង បពិត្រនរោត្ដម កុំព្រួយព្រះរាជហឫទ័យ ។
បានទៅនៅវិលវិញវៃ ទាំងក្សត្រជៀសផ្ទើយ ដឹងជាមកុជសិរសា ។
ទូលប្រេបមាយើងមិត្តា មកផ្ទះអាត្មា ព្រួយព្រាប់ករិយាគស់ក្ដី ។
ផំណាលប្រាប់កាលចក្រី ព្រាត់មុខមន្ត្រី ទៅផ្ទុំក្រោមដើមព្រឹក្សា ។

www.budinst.gov.kh www.elibraryofcambodia.org

ក្រាប់ពីស្តេចសោយក្រយា សរសើរនាងថា កិរិយាបានបេះសួនគ្រង ។
ក្រាប់អស់ដំណើរទំនង នាងត្រេកអរផង គឿតបានដួចចិត្តចិន្តា ។
មាយើងនោះនឹងកិរិយា ហួចបាយហើយណា ក៏កាន់ដាវឡើងទៅចាំ ។
អន្ទុយផិតនៅតយយ៉ាំ គន្ធមុំនកេងកំ ព្រះបាទសម្តេចព្រហ្មទត្ត ។
មន្ត្រីក្រាស់ត្រែប្រើនក្តាត់ ប្រុងក្រុណប្រយ័ត្ន ធំពេញនៅកងកេងមៀ ។
លុះដល់កាត្រាគ្រជាសុំ ដេកស្ងាត់ជ្រងំ ពុំភ្ញាក់ដល់ម្នាក់ឡើយណា ។
កាលនោះឯងទេវតា ក្រុណប្រែកាយា គិតជាពស់ពារទៅហោង ។
ទំពាំពស់ធំអន្លង់ ប៉ុនដើមត្នោតផង ក៏លើកពពារន្ធូរខ្ទាច ។
មាននៃកនោះចំគ្រជាប បន្ទួសស្ងាច នឹងខាំព្រះមហាក្សត្រា ។
មាយើងដោះឡើងម្ចាញ លើកនាងបុតថ្វា កិរិត្ត្រូវសិរសាសល់ ។
ឈាមពស់ខ្ចាត់ខ្ចាយទៅដល់ ទេពីនិមិល ក៏ពេញនាព្រះឋនា ។
ទើបហៅមាយើងគិតថា ពស់នេះមរណា អសារសោះស្ងួនឲ្យជីវិ ។
ឈាមជួបដល់ព្រះទេពី វរវ័តនក្សត្រី ឃ្វោះតើឯងធ្វើម្តេចបាន ។
ជ្រះឈាមពីនាងគលព្ភាណ នឹងជាស់ក្សត្រក្សាន្ត យល់ក្តីពុំគួរក្តាត់ណា ។
ខឹងយកថៃជូតឲក សោតសំងពុំជា កើតក្តីពុំគួរពេកក្រៃ ។
ទើបមានទាញពស់នោះរៃ ដាក់នៅក្រោមៗ ក្រឡាបន្ទំវៀវ័តន ។
ស្រេចហើយទើបតាត់ហាមាត់ លិទ្ធឈាមដែលផិត នៅនាព្រះស្តនក្សត្រ ។
នាងនាថភ្ញាក់ភ្ញាក់ឥន្ទ្រិយ ទើបជាស់គ្រូមី ធំជាតម្តែងក្រឡា ។

www.budinst.gov.kh www.elibraryofcambodia.org

នាងឡើបប្រាយប្រាប់ថាមា. យើងយកដីភ្លូ មកលិទ្ធខ្លួរដោះខ្ញុំហោង ។
ស្តេចស្តាប់ក្រោធក្រៃកន្លង ត្រាស់ច្រើគលផង ថាម្នាលពេជ្យឃាដម្នីម្នា ។
ចូរចាប់ចាប់ចងយកក កំណាចមហិមា នេះនាំយកទៅសម្លាប់ ។
ក្សិណនោះពេជ្យឃាដចូលចាប់ ចងមាយើងខ្ជាប់ ក៏នាំយកទៅម្នីម្នា ។
ហេតុស្តេចឥតពិចារណា ពុំគិតគុណមា. យើងយកតែពាក្យទេវី ។
ពេជឃាដនាំតាំងកក្រើ ទៅបូព៌ទិសទី ក៏ជាទីងអ្នកនាយតួ ។
ឲ្យបើកត្បៀតព្រះកូបាល មានព្រះទុក្ខារ ឲ្យនាំអ្នកទោសទៅកាប់ ។
ក្សិណនោះនាយតួរស្តែងស្តាប់ យល់ខុសនឹងច្បាប់ សម្លាប់អ្នកទោស
តាំងយប់ ។ ជាទោសនេះម្តេចអ្នកឈប់ ប្រាយប្រាប់សព្វគ្រប់ ដំណើរ
ដំណាលសេចក្តី ។ នាំអ្នកទោសតាំងកក្រើ ពុំត្រូវច្បាប់តី បុកណាគន្លង
ទៀយណា ។ ពេជ្យឃាដទូលស់ឆ្លើយថា អញដឹងឯណា ជាទោស
ធ្ងន់ស្រាលអ្វីៗ ។ ស្តេចប្រើអញតាំងកក្រើ ទៅមគរកក្តី លើព្រះបរើ
ម្តេចបាន ។ អំណាចអ្វីៗឯងមាន ក៏អញនឹងហ៊ាន នាំគេមកសម្លាប់
លេង ។ អម្បាលទៅមាយើងឯង ម្តេចពុំកោតក្រែង ក៏តាស់ព្រះរាជ
អាជ្ញា ។ នាយតួរសោកឆ្លើយថា បើព្រះអាជ្ញា លុះត្រូវនឹងច្បាប់
ទើបបាន ។ បើខុសនឹងច្បាប់បុកណា យើងឃាត់ខាំងខាន បានត្បៀត
យើងជានាយតួរ ។ បើយើងក្រាបទូលនាកាល នោះព្រះកូបាល
នឹងធ្វើម្តេចៗ តាមកល ។

www.budinst.gov.kh www.elibraryofcambodia.org

# បទកាកគតិ

នាយទ្វារនោះណា បង្កាំកញ្ជា ឈរឈប់របស់ ទើបនាំនិទាន ថែមមានមនុស្សរស់ ប្រាយប្រាប់អស់គល និងគេផ្សាយផងហោង ។ ទៅអើយនិយាយ កាលពីព្រេងនាយ ទុកជាទំនង មុនមានស្រីម្នាក់ មានកូនមួយហោង ចិញ្ចឹមស្វាផង ស្រឡាញ់ពេក ។ ស្រីនោះទៅផ្សារ ទុកនៅតែស្វា និងកូននោះណា ផ្ដេកក្នុងអង្រឹង ទើបបរយាត្រា ក្រោយនោះពស់កា- សិរពិសយង់ឃ្នង ។ ក្បែណាពស់លលាំ វារមក ចឹកទាំ កូននោះមរណ៍ហោង ស្វាឃើញពស់ពិស ក្រស្ដក្រស្ដកន្ទួង ស្វាប្រហារផង ទីងពស់នោះណា ។ កាលនោះពស់ពាល ប្រវាំនឹងស្វា ស្វាទាំមរណា ម្ចាស់មកពីផ្សារ ក្បែណាស្វានោះរត់ តែដោយមាតា ទៅទទួលហោង ។ ស្រីម្ចាស់ស្វា ឃើញឈាមក្ដោល ទៅទូននោះផង ប្រមាណគិតថា ស្វាកាចកន្ទង ទាំកូនជាម្ចង មិនឈាមគួរឡើយ ។ ទីងធ្លុលគៀបធាប់ វាយស្វាស្លាប់ ហោះបង់សៀតហើយ ចូលទៅ មើលកូន ឃើញសូន្យ[1] ឥតត្រើយ ពិតពុំទេឡើយ ឃើញពស់មរណា ។ ទើបគិតឯងឃើញ ថាពស់កាចសល់ ទីងទាំបុត្រា ស្វាការបុត្រនោះ ប្រទាំងសោះសា ឃើញស្លាបជាក់ជា បន្ទាល់ទៀងពិត ។ ទើបគិតស្ដាយ

១– ច្បាប់ខ្វះថាមិនសូន្យ ។

ស្ការ ស្តាយកូនសង្សារ សោះសូន្យជីវិត សោកឯងផ្សាឯង ស្តាយអស់គំនិត អញខ្លាចមហាក្សត្រ ទើងស្តាយពោះហោង ៗ ហេតុនេះអញពុំបើកបើទឹងទំ ខុសច្បាប់កន្លង ហៅទៅទ្វារទៀត រីអញនេះម្តង មិនបើកឡើយហោង និយាយសោកមាន ៗ

ពេជ្ឈឃាដស្តាប់ហើយ ទំពុំបានឡើយ ទើបនាំទៅក្តាន នាយទ្វារទក្សិណ ឲ្យបើកត្បិតមាន ព្រះបន្ទូលក្តាន ប្រើយើងនេះណា ៗ នាំមនុស្សទៅកាប់ ហៅបើកឆាប់ៗ ដូចព្រះអាជ្ញា នាយទ្វារទក្សិណ នោះសោកឆ្លើយថា លោកផែលឯណា នាំនាំងកក្រើ ៗ ពេជ្ឈឃាដឆ្លើយថា ព្រះអើយអញណា ប្រកែកថាអ្វី បើកទៅឆាប់ៗ ទឹងកាប់ម្នី នៅនាស់សេចក្តី លើព្រះអាជ្ញា ៗ យើងនេះមិនព្រាង កុំហៅស្អួតអាង ឃាត់ទាំងកំងក បើះហៅមិនជឿ ទៅទូលក្សត្រា យើងពុំមុសា-កាទទៀចឡើយហោង ៗ នាយទ្វារឆ្លើយថា ជឿជាក្សត្រា ប្រើផាក់មែនហោង នាំទៅសម្លាប់ តែច្បាប់សត្វផង សម្លាប់មនុស្សផង សើងនាំទៅថៃ ៗ នេះនាំតាំងយប់ យើងខឹងឲ្យឈប់ លុះស្រាង ៗ ទ័យបើហៅទឹងទំ យើងពុំបើកអែ ច្បាប់យើងទីទៃ បេះហាំស្ទាត់ទៅ ៗ ហើយមាននិយាយ ពិតាព្រងនាយ អញនឹងប្រាប់ហៅ ហៅស្តាប់អញថ្លែង សំផែងសំដៅ ដោយនិតានទៅ ដំណើរអតីតា ៗ មុនមានសេដ្ឋីមានទ្រព្យប្រាំបី កោដិឃ្លាំងសោះសា បំពុំមន្តហាំ ន្តប្រាំរយណា

www.budinst.gov.kh www.elibraryofcambodia.org

សឹងតែជាៗ បានជួបនូវចិត្ត ។ ពោះមនុស្សចោរ ឃើញតែស្រមោល បណ្ដោញៈដោយជិត ព្រួសព្រមទំនិញ ប្រចាំគ្នាស្ទាក់ រក្សាសម្បត្តិ នៃមហាសេដ្ឋី ។ សេដ្ឋីនោះណា សឹងឲ្យគេ តែជាប្រក្រតី មានខ្ញុំ ដណ្ដាំ បាយឲ្យតែដី សព្វទិនក្រត្រី ពុំសោះឡើយណា ។

មានកាលមួយថ្ងៃ ចោរប្រាំរយនៃ គប់គិតនិងគ្នា វាជីកឧមង្គ ឡើងលួចទ្រព្យមហា- សេដ្ឋីនោះណា អស់ពីឃ្លាំងហោង ។ តែប្រាំ រយយល់ ក្រដូវដេញផល់ ព្រមត្រួសវឹងទាំង ដេញក្នុងឧមង្គ ក្នុងឋាន កំបាំង ទាំងចោរស្លាប់តាំង ប្រាំរយអស់នៃ ។ លុះព្រឹកសេដ្ឋី យល់ព្រាយ បាតតី មណ្ឌលឃ្លាំងដ៏យ ប្រាំមួយកោដិគត់ អស់ឥតសង្ស័យ សេដ្ឋី ក្រោធក្រៃ ជាអគ្គសារ ។ បំពុំមតែថ្វី ឲ្យបាយរាធី វាដេកឥតការ ចោរលួចទ្រព្យអស់ តែពេញតាំងពល ឥតសព្វឥតសារ ទឹងទុកថ្មីរា ។ សេដ្ឋីឲ្យចាប់ តែទៅសម្លាប់ ឥតសំណល់ណា លង់លុះខ្មោចចោរ ពុំក្បែងដល់មហា- សេដ្ឋីនោះណា ដ៏ជាម្ចាស់ទ្រព្យ ។ សេដ្ឋីថាយើ អស់ក្មេងនេះតើ យកតែទៅកាប់ គ្រប់ឋានឯណា វាសួយសើរស្លាប់ ទៅមកតាប់ៗ ឥតសរបេញឲ្យឆ្ងាយ ។ ខ្ញុំមហាសេដ្ឋី ប្ដីប្រាប់រឹងខ្ញុំ ជាតែតាំងឆ្ងាយ យើងខ្ញុំសម្លាប់ កណ្ដាលព្រៃឆ្ងាយ មិនទំដល់កាយ នេះឡើយម្ចាស់ថ្លៃ ។ ទើបមហាសេដ្ឋី ថាប្លោះខ្មោចអ៊ី ទុំស្អុយពេក ក្រៃ គារកហិតមើល ប្ដូកក្រវិស័យ ខ្ញុំនោះវៃ ។ ហិតគេហោងណា ។

ដល់មាត់រណ្ដៅ នោះធំស្លុយក្រៅ វិស័យសោះសា ខ្ញុំនោះវិលមក
ប្រាប់សេដ្ឋីថា រណ្ដៅមួយណា ធំស្លុយពេកសល់ ៗ ទើបសេដ្ឋីថា
បើពោះគស់គ្នា ទៅជីកឲ្យយល់ ក្បែរណាខ្ញុំសេដ្ឋី កាន់ចបរបស់ ជីកទៅ
យន់យល់ ត្នោចទោះមរណា ៗ រមួសទៀតទេ សឹងចង្កូមក្រែ នោះ
គស់គ្រប់គ្នា ទ្រព្យគ្រឿងធ្ងន់ សឹងគង់នៅជា គស់ខ្ញុំនោះក៏ មកប្រាប់
សេដ្ឋី ៗ សេដ្ឋីនន់គិត តែកុងតំនិត ជឹងជើមសេចក្ដី ថាគេអញត្បាយ
ឯងឲ្យសម្លាប់ ក្នុងនោះពុំគាប់ ខុសទេហានណា ៗ

ទៅអើយមហាក្សត្រ ព្រះបាទព្រហ្មទត្ត លើសលើលោកា អញ
ថាទឹកត្នោយ ស្ដាប់ក្រោយដូចមហា សេដ្ឋីនោះណា មិនបែបន៏ឡើយ
ហាន ៗ អញពុំបើកទៅ ទៅនាំយកនៅ ក្នុងឯទៀតផង ក្នុងគេញ
មានច្បាប់ ចេះប្រាប់គន្ធន៍ អញពុំបើកហាន កុំបន្ទំអញ ៗ

ពេជ្ឈឃាដនោះស្ដាប់ គស់គាថាសាសត្ង នោះទើបនាំបញ្ជូ នៅ
ក្នុងបស្ទឹម កាលគ្រានោះវិញ អ្នកក្នុងនោះមិញ ពុំបើកឡើយនៈហាន ៗ
ពេជ្ឈឃាដថាបើ ទៅពុំបើកតើ មានច្បាប់ចំនួន ជាំណើរនេះនាំម្ដេច
ចូរទៅសាសន៍ ប្រាយប្រាប់អញហាន គស់គាថាសាសត្ង ៗ ទើបអ្នក
ក្នុងថា លោកដែលឯណា នាំមនុស្សទៅកាប់ តាំងយប់ក្រើ ខុសពី
ក្បួនច្បាប់ ទៅអើយចូរស្ដាប់ និយាយអញមាន ៗ មុនមានមហាក្សត្រ
សោយរាជសម្បត្តិ សម្បូរធនធាន បរិក្ខ័មសោតសេត្ង សេករីតទ័កលក្ខណ

www.budinst.gov.kh www.elibraryofcambodia.org

ហើយទៅហិមពាន្ត រកភក្សចំណី ។ សេកមានសម្បុរ នោះល្អមិនល
កបបញ្ចិត្រឆ្មើយ កាលនោះស្ដេចឃើញ សម្បុរបក្សី សេកស្អិតសោភ័
ល្អល្អះប្រពៃ ។ ស្ដេចមានឱង្ការ បន្ទូលទៅផង សេកស្អិតនោះថា
សេកអើយសម្បុរ អ្នកឃើញល្អក្រៃ ហេតុម្ដេចឡើងឡៃ លាក់ប្រាប់
អញកុំ ។ សេកសោកទៀនទូល បពិត្រឥស្សរ តាមគុណសរសោ
សម្បុរខ្ញុំល្អ ក្បិតខ្ញុំភោក្តា ផ្លែស្វាយនៅនា ព្រៃព្រះហិមពាន្ត ។
រីស្វាយនោះណា បើបាសផល សាក្រក់ប៉ុន្មាន បានបរិភោគ្កា ផលា
នោះផ្ចុន្ត ក្បិណនោះប្រែប្រាណ កម្ចោះរីងរៃ ។ ស្ដេចស្ដាប់
សាស័ក្ស សេកសូត្រទូលថ្វាត់ បន្ទូលថាហៃ សេកអើយបើបោះ
អ្នកទៅធាប់រៃ ពាំនាំពីព្រៃ ផ្ញើយើងផងផង ។ សេកសោកទទួល
ព្រះបន្ទូលស្រួល ស្រុះស្រោបកសំគុំ ហើយហើរផ្លេកផ្លុះ ទៅស្ទុះ
ឃ្លាតខ្ញុំ រកភក្សចំណី ចំណង់ភោក្តា ។ លុះឱទីវាលថ្ងាន ទើបសេក
ពាំបាន ស្វាយមួយនោះណា មកផ្ញើមហាក្សត្រ ស្ដេចអរក្តាត់ណោ
ទទួលផលា ពីបក្សីសេក ។ ស្ដេចគិតថាស្វាយ នេះគិតអម្បាយ
បានតែៈបីគាត់ បើកញ្ញទីនដី ឲ្យល្អទូតថ្វាត់ តែអញឯងក្សត្រ នូវបុត្រ
ករិយា ។ នឹងញាតិពាំងខ្ញាយ បើបោះផុតស្វាយ នេះទៅដាំនា
ឋានមួយបើផល បានផលត្រឹមក្រ សមយើងនាំគ្នា ឲ្យគ្រប់ហោង ។
ឱនមានរូបរ័ត្ន ប្រែតែល្អគាត់ ពេកពន់កន្ទុង ទើបស្ដេចបណ្ដុះ

www.budinst.gov.kh www.elibraryofcambodia.org

ស្វាយនោះជាម្ដង ផុះដូចស្ដេចបិន បំណាន់ប្រាថ្នា ។ ស្ដេចឲ្យទៅដាំ មានអ្នកផងចាំ ពិតក្ដិរក្សា លុះស្វាយនោះធំ មានផលផ្កា ហេតុដាំ នោះណា ស៊ើវខ្មោះគៃ ។ ពិសធាតុសត្វហោះ ផ្តក់ផ្ទាបផ្លែស្វាយ ពិបពស់វិស័យ លុះស្វាយនោះធំ ទើបក្សត្រទៀតសួយ ឲ្យបេះច្រើនក្រៃ យកឧកៈហាធំណា ។ ស្ដេចឲ្យអមាត្យ ជំនិតព្រះបាទ នីមុនក្សត្រា អមាត្យនោះធី ពុលពិសមរណា នៅព្រះកន្ត្រមហា- ក្សត្រកក្ខនោះហ៊ ។ ស្ដេចយល់អមាត្យ ពុលពិសស្លាប់ខ្លួន ទ្រង់ព្រះក្រោធក្រៃ ពុំពិចារណា ទៀយមហាក្សត្រថ្ងៃ ជាសោកចង្រៃ ធីងសម្លាប់គញ ។ ក៏ពួកគញាឧស្មូន គញទៀតលង មើលមុខមែនមិញ បើគញធីឯង ឥតក្រែនសមគញ អស់ជីវិតវិញ មិនលែងទៀយណា ។ ស្ដេចភ្លល់ផ្តុំនាប់ កាយសោក សម្លាប់ ឥតពិចារណា ដំណាក់នោះ ស្វាយនោះផ្លែផ្កា ឥតនរណា ធីងហ៊ានបេះធី ។ លុះបំណោរទៅ តាគនោះឱត្យទៅ ពុំបានថយតី លំនៅនោះចេញ ពិសពេញធរណី ប្រែជាសាបត្ដី ពុំពុលទៀយណា ។ អន្ទ្រនទៅណាស់ តាចាស់ជូនចាស់ ពិបាករក្សា ជីវមហាក្សត្រ មកគិត ខ្លាថា យើងនេះជក ចាស់ណាស់ទៅហើយ ។ ទន្ទឹងតែស្លាប់ ក៏មិន ទាន់ស្លាប់ ដូចចិត្តសោះទៀយ បើទោះយើងរស់ ជាមនុស្សថ្មីសោយ ពិបាកឥតត្រើយ មកយើងទៅធី ។ ស្វាយផ្លែស្ដេចដាំ ឲ្យស្លាប់ ទៅចាំ រស់រូបតើជី ពិបាកកាត្តា គ្រោងវីរ តាត់គិតព្រមថ្គី ប្រពន្ធ

www.budinst.gov.kh www.elibraryofcambodia.org

ហើយទៅ ។ បេះបាយមកធី ក្បែរណោះឯថ្ដី ប្រែសក់ជាខ្មៅ សម្បុរ

ជាក្លោះ(១) ឥតខ្ចោះហ្មងសៅ ក្រឡេកមើលទៅ ប្រពន្ធនោះណា ។

ប្រែជាក្រមុំ សម្បុរខ្លួសេម ដោះដូចបទុមា ប្ដីថានាងល្អ នាងមកពីណា

ប្រពន្ធឆ្លើយថា យើងប្ដូរអញហើយ ។ ប្ដីឮភរិយា ចាំតែពាក្យថា

មុខមិនស្គាល់ឡើយ ទើបឆ្លើយទៅថា ខ្លួនភកអញនើយ ពាក្យ

ប្រហែលហើយ រូបកងទៃ ។ ប្រពន្ធឆ្លើយថា ព្រះអើយគុណណាំ

ខ្ញាវឡើងព្រៃ ក្រតើឡើង- ចឹងឯងសព្វថ្ងៃ នរណាឡើយនៃ អញឯង

ដូចចាស់ ។ ទៅឯងសក់ស ខ្លួនគោងមិនល្អ ឥឡូវប្រែផ្លាស់ ជាសក់

ខ្មៅញាប់ ចំណាប់ចំណាស់ មុខមិញសោកចាស់ ឥឡូវកំឡោះ ។

ប្ដីថាយើអើ ឲ្យស្ដាប់មិញគេ មកធីស្វាយនោះ ម្ដេចអញនឹងមេ ប្រែខ្លួ

ជាក្លោះ មេះអើយបើញោះ ជាភ័ព្វយើងឯង ។ ដូចគាប្រែប្រាលេ

ស្រេចរិលទីថ្កាន លំនៅឥតក្រែង ភក្រដំរី ដូចពីមុនព្រេង ពោយជា

អញឯង ពិតពុំឃ្លាតឃ្លា ។ កាលនោះស្ដេចយល់ កម្លោះទំមិល

រូបពងសោភា ស្ដេចត្រាស់ផណ្ដឹង ថាមនុស្សពីណា មកនៅភក្រ

ដំរីអញហោង ។ ទើបតាកំឡោះ ទូលទៅតាមស្មោះ បពិត្រពួកសព្វ

ខ្ញុំគឺតាចាស់ នៅនេះឯងហោង គង់គធីស្វាយផង ប្រែប្រាណបេះណាំ ។

ស្ដេចស្ដាប់ថាយើ ស្វាយពុលមិញគេ ម្ដេចប្រែជាជា ម្នេះប្ដូរអ្នកផង

---

១– ពាក្យបុរាណ គឺកម្លោះ ។

ទៅបេះផ្កា យកមកតាប់ក៏ អញចង់ឲ្យដី ។ អាមាត្យក្រាបពល ទៅ
បេះផល មកថ្វាយភូមី ទើបស្តេចឲ្យអា- មាត្យមុខមន្ត្រី ធមុនបក្រី
ចន់ជីឥតក្នុក ។ អាមាត្យមួយជី ល្អសសំផ្ទែរ ប្រពៃសោភា ស្តេច
យល់ហោះវៃ ព្រះទ័យសង្កា ត្រាស់ប្រើឲ្យមហា- មាត្យមួយធីទៀត ។
វែងល្អនិមិល ស្ងួតសាមសម្បូរ ឡើងដូចរបៀត ស្តេចត្រាស់ឲ្យអា-
មាត្យមួយធីទៀត ទើបស្តេចបានបៀក ច្រង់ចងព្រះហស្ត ។ ឯងឲ្យ
បុត្រី បុត្រាមហេសី ច្រង់សោយចាំងសស់ សឹងមានព្រះអង្គ គោះប្រែ
ប្រាណផ្ទាស់ ហាកហោលឯហាស់ ក្រឡះជាកាល(១) ។ ស្តេចយល់
ហោះហើយ ទើបត្រូតត្រាណក្រើយ សោយផលអាហារ ក្នុងស់
ព្រះអង្គ រុងរឿងត្រកាល សម្តេចភូបាល ប្ញកធនសត្រា ។ ទើប
ត្រូតជៀសួឥយ គិតក្នុងព្រះទ័យ អត្ថីក្តីណា ហេតុអ្វីស្វាយតុល បាន
ប្រែជាជា ស្តេចត្រាស់ឲ្យអា- មាត្យមើលអស់ត្តី ។ អាមាត្យទៅមើល
រណ្តៅនោះឃើញ នាគនៅគតី មុខមានដូះហោះ ទើបទូលបក្រី ស្តេច
មានព្រះតី- ហាណារបង់យល់ ។ នាគស់នាគា ជ្រួតជ្រាបព្រឹក្សា
ពិសតស់អស់កល់ គឺមុខនាគមិញ ពិសពេញបក្សល់ អញឯងជាល
ផល់ សម្លាប់សេកសត្វ ។ ស្តេចសែនខឹកស្តាយ សេកស្ទួតិពណ្ណកយ
អសារបង់ចុក នៃហៅពេជ្ឈឃាដ ព្រះបាទព្រហ្មទត្ត អញ្ជាចមបកត្រូ

---
១– ក្មេង ។

ទើបស្ដាយក្រោយក្រៃ ។ ហេតុនោះឯងអញ ពុំបើកទៅចេញ ទៅតាំងយប់វែ. បើទោសទាំងសល់ ទៅចាំដល់ថ្ងៃ ច្បាប់មានក្សត្រថ្ងៃ ខឹងខ្វល់ពុំបាន ។

តេជ្យឃាដស្ដាប់ស្ដែង នាយទ្វារសំដែង ដំណាលទំពាន ទើបទៅឯទ្វារ ចុត្តទើបាន តេជ្យឃាដហៅមាន- ស្រែកប្រាប់ទៅថា ។ រួយអស់នាយទ្វារ កេក្សសព្វកាល បើកអញម្ដង ត្រាស់ប្រើអញនាំ អ្នកទោសរនះណា(១) ទៅកាប់សោះសា ចៅបើកអញឆាប់ ។ នាយទ្វារឆ្លើយទៅ ថាចៅរួយចៅ មិនដែលមានច្បាប់ នាំអ្នកទោសទៅ តាំងយប់សម្លាប់ អញយល់ពុំគាប់ ខុសព្រះមាត្រា ។ តេជ្យឃាដទ្រង់ទុំ ថាម្ដេចក៏ពុំ បើកព្រះកាឡា ឃាត់អញអើការ ឯងមានច្បាប់ណា ឲ្យឯងពំនឹក លើព្រះបំរើ ។ នាយទ្វារឆ្លើយទៅ ថាតេជ្យឃាដចៅ ការអញឯងបើ អញឃាត់ម្ដេះខុស ច្បាប់ដូច្នោះតើ ចៅទ្រង់ទំប្រើ ឲ្យបើកទៅបាន ។ អញជានាយទ្វារ គាមេតិបា រៀនពីបុរាណ មិនដែលឮថា ដូច្នោះនឹងមាន បើទោសប៉ុន្មាន ក្សត្រាមានបុណ្យថ្កើង ។ ប្រើនាំទៅផ្ដង ចៅទៅនេះហោង ចាំព្រឹកឡើង សឹមនាំចេញផ្ទាត់ យើងឃាត់តាមរឿង បើផ្គង់ទោសយើង សឹងមានគ្រប់គ្នា ។ យល់តែស្ដេចប្រើ យើងបើកហើយតើ មិនខុសមាត្រា ដំណាចនឹងឃ្យើង សំគៀងច្បាប់ទ្រា- កងកើតអនា- ទរ(២) ផ្លូវក្រោម(៣)ក្រៃ ។

---

១- ច្បាប់ខ្វះជា សន្តិយោ ។ ២- ការមិនអើពើ ។ ៣- តែងនឹ ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រដឹកដការ ដោយមេមុខភ្នាក់ងារ កាន់ខ្ពប់ទីនៃ យល់តែអំណាច ល្មមខ្លាចៗក្រៃ បើពុំល្មមនៃ គាស់សិនដោយច្បាប់ ៖ មុខមន្ត្រីធំ បើបាត់ផែនដី ព្រមប្រើសម្លាប់ ឲ្យតែក្សត្រា ពុះពារប្រើកាប់ ក្រោធក្រៃ ទុរទាប់ ឧិនព្រះអំណាច ៗ ទៅអើយច្បាប់មាន ក្សត្រពីបុរាណ បរមរៀនកដ បើពុំទ្រង់ធម៌ សម្មាងនគាច កាន់ព្រះអំណាច ខុសច្បាប់ ហើយណា ៗ មុខមន្ត្រីធំ អ្នកក្រោមផែនដី គិតព្រមគ្នា បណ្ដេញ ស្ដេចមេធំ ពីត្រូនគរ ក្បែរស្ដេចពុះពារ បំពាក់បំពាន ៗ បើកស្ដេចមន្ត្រី ពុំដោយច្បាប់ពី បរមបុរាណ ល្មមលក់ល្មមថ្លៃ ល្មមឲ្យក្សយបាន ទៅទំប៉ុន្មាន អញពុំបើកឡើយ ៗ

## បទព្រហ្មគីតិ

កាលនោះឯមហាក្សត្រ ព្រហ្មទត្តកើតឡើងហើយ ហ្វូយសោក ពុំស្បើយ គិតទៅដល់មាណពថា ៗ មាណពមានគុណក្រៃ កាលនៅ ក្រៃមានតែមា- ណពឯងឥតខានណា ក្រៅអំពីមាណពឡើយ ៗ ឥឡូវ នេះអញប្រើ ឲ្យគេធ្វើគត់គាត់ហើយ គេកាប់ឬនៅឡើយ អះអញស្ដាយ ពេកណាស់ណា ៗ ស្ដេចត្រាស់ឲ្យអាមាត្យ រត់ទ្រហោតស្រម៉ុម៉ា ទៅ តាមយកទៅមា- ណពមកវិញកុំពិឃាត ៗ កាលនោះអមាត្យ ក្រញូ ក្រាបលាតស់ស្វាត ភាយតាន់ពេជ្ឈឃាដ នៅទ្វារទក្ខិណនោះ ៗ ទើបនាំមាណពមក វិលវិញមកថ្វាយក្សត្រស្មោះ ទើបស្ដេចបន្ទូលត្រាស់

www.budinst.gov.kh www.elibraryofcambodia.org

ផណ្ដឹងនេះហៅមាយើងថា ។ ហៃមាយើងអើយទៅ កាលអញទៅលេង ព្រៃក្រូ អញយល់មាងផង មានគំនិតគំនូរក្រៃ ។ ឥឡូវម្ដេចហៅគិត ប្រាណប្រែចិត្តទៅទីទៃ ចូរទៅបែងសម័យ បរកាមកឥឡូវក៏ ៗ មាយើងទូលពិពិត្យ ថាបពិត្រព្រះពជា ក្នុងកាលយប់មិញណា ពស់ក៏ មកចាំក្បែរគ្រែថ្ងៃ ។ ខ្ញុំកាប់ពស់អន្តរាយ លោហិតខ្ចាយពីក្រោមគ្រែ ពេញព្រះបន្ទំ វរទេវីពិសេសសល់ ៗ ខ្ញុំពុំហ៊ានប្រមាថ ផាស់ ព្រះបាទទៀតពាល់ នឹងយកដៃជិតផល់ សោតពុំគួរទើបខ្ញុំ ៗ យកអណ្ដាតលិទ្ធឈាម គួរកើយក្លាមពិតពុំសម ជ្រាបដល់ព្រះអង្គអ-ម្ចាស់ឲ្យបងយកទៅកាប់ ៗ ខ្ញុំនឹងទូលក្បែរគ្រែក្បួន ពាស់ពុំហ៊ានក្រែង ខុសគាប់ គំពល់បើនឹងស្លាប់ កាមវេកអំពើខ្ញុំ ៗ ផែះហេតុអំពើ គ្រន់ពុំធ្វើវេកខ្ញុំ ទើបមានដោយសារធ្ងំ· ទ្វារដំពាស់ពុំឲ្យទៅ ៗ បើពុំពិចារណា គឺសាសោះសូន្យសៅ ក្បៀសក្បែយជីវិតទៅ គាថរណី តាយផុតការ ៗ ស្ដេចស្ដាប់ផណ្ដឹងនោះ ជាប់ប្រោះខ្មោចពស់ពាល ទៅទុកឯណាកាល ឥឡូវទៅប្រាប់អញុះហាន ៗ មាយើងទូលទៅថា ខ្ញុំទុកជាបន្ទាល់ផង ពាំង៣កំណាត់ហោង ក្រោមមន្ទីរទិព្វក្បាល ៗ ទើបស្ដេចឲ្យទៅយក ខ្មោចពស់មកមែនដូចសា- សព្វហៅមាយើងកាល-នោះព្រះអង្គជឿជាក់ស្ដែង ។ ក្សត្រៃបុណ្យខ្ពង់ខ្ពស់ យល់ខ្មោចពស់ ទ្រង់ស្ញប់ស្ញែង ព្រឹក្រួបប្រឹងគ្រៃញួន ព្រះសិរស៊ើបខ្ទួលថា ៗ

ភ័ព្វជាមាយើងហើយ កុំគិតឡើយលុះមរណា ទុកមាយើងនេះមហា. គុណអនេកអនន្តក្រៃ ៗ អ្នកផងសឹងស្ញប់ស្ញែង ត្រើត្រៀញ្ញនខ្លួនចំពែ យល់គុណមាយើងក្រៃ ក្រាស់ឥតទីផ្ទឹមផ្ទឹងថ្លែង ៗ ស្តេចឲ្យស្រាយចំណងមាយើងយោងគ្រោះសាលវែង ទោសទុក្ខបង់វ៉ៃង ហើយចង្អុលដោះសាថា ៗ ទៅហើយហេតុអញទៅ ធ្វើទោសទៅឥតករុណា កុំទៅយកទោសា អញទទួលថាខុសហើយ ៗ ទើបស្តេចគិតគុណក្រៃ ឲ្យយសផ្តួតឥតស្មើឡើយ ដល់មាយើងជាត្រើយ ជាមន្ត្រីអគ្គទូន ៗ នរអ្នកសឹងចុះឡើង ទៅមាយើងឥតផ្ទឹមផង ហេតុបានករិយាគ្រង គាប់លក្ខណាសុគតិសល់ស្រី

## បទកាកគតិ

និទានមាយើង បានឆេះកុក្កុដ សាន្តសម្រេច ឈ្មោះទុកទើបថ្លែង សំដែងស្រដី ដំណាលអំពី អ្នកនាយកេត្រ ៗ បានមកញ្ជើ- ជុះអរលលើ ទៅជាករិយា ដោយកពុំមាន ធនធានទ្រព្យា លុះបានហើយកធ្វើធ្វើសំក្រៃ ៗ ស្បៀកខោនស្បៀកក្រោះ ស្អាតខ្លួនបន្ទ ផ្លិតផ្លូវសព្វថ្ងៃ អាងប្តីមានទ្រព្យ ប្រដាប់ប្រើក្រៃ ថាខ្លួនរាំថ្ងៃ ឥតគេផ្ទឹមផង ៗ វាពុំស្រដី ទ្រព្យធនអ្វីៗ ពុំបានសន្សំគ្រង ស៊ីតាក់ស៊ីតោល បាបសាបជាមួន មានកូនមួយផង ឈ្មោះនាយនោះនៃ ៗ បើកូននោះផុះ មកញ្ជើផុះ

www.budinst.gov.kh www.elibraryofcambodia.org

តុំលានវិស័យ ដូចអ្នកតាំងគ្រប់ គានទ្រព្យច្រើនក្រៃ រីហកព្រៃថ្ងៃ ដូតគាបម៉ហោលទៅ ។ លង់លុះវែងឆ្ងាយ ក្បៀណាខ្សត់អន្តរាយ ទ្រព្យតាំងសំពៅ ប្រែជាអ្នកខ្សត់ ទុគ៌តកាសៅ លក់តាំងសំពៅ ស៊ីហាយគស់ហោង ។ ហេតុស្រីកាគលក្ខណ៍ តុំបេះទុកដាក់ រក្សាស្គន្ធគ្រង ឲ្យគាប់យសប្តី អប្រិយកន្ទុំ សត្វថ្ងៃនេះហោង សុំទានគេស៊ី ។ កំសោយកំសត់ ហិនហោចទុគ៌ត ដើរដោយប្រឹថពី ស្វែងរកសុំទាន សត្វហានទិសទី បញ្ចឹមជីវី ជីវិតសត្វថ្ងៃ ។ សុំទានរៀនទៅ ដូចផល់លំនៅ ផ្ទះមាយើងអើ នាងយល់អ្នកខ្សត់ ទុគ៌តក្រក្រៃ ស្មានអ្នកដទៃ ហើយឲ្យទានទៅ ។ លុះគន់ជាក់លោក នាងស្គាល់ជាអ្នក ចៅនាយសំពៅ ប្តីដើមនៃនាង ទើបនាងថាទៅ ចៅនាយសំពៅ ម្តេចដើរសុំទាន ។ ប្តូរផ្តាច់ចោះបង់ អញឥតមានស- ង្ស័យអញស្មោះស្មាន ទឹងកើតរបស់ស័ក្តិយសធនធាន ឥឡូវម្តេចប្រាណ ប្រែខ្លួនទទេ ។ ល្អតពុំទោ ចៅនាយសំពៅ ដើរសុំទានគេ ស្រឡាញ់ប្រពន្ធ ល្អលន់មុខមេ កញ្ចើផ្ទះទេ ល្អគេកប្រាកដ ។ នេះហេតុលក្ខណ៍ស្រី គេចរើនប្តី បរិបូណ៌បានបទ ស្រីឃើញចង្រៃ គេកក្រៃប្រាកដ នៅនឹងអ្នកខ្សត់ ប្រែជាអ្នកមាន ។ ។

មនុស្សខ្សត់តាំងពីរ ព្រះហើយមើល មើលនាងកលក្ខណ ស្គាល់ជាក់ហើយគ្នាស គាស្រូវកាសគាង រៀសចេញទៅហាន លំនៅគាគ្នា ។

មារយើងមានយស ឧត្តមខ្ពង់ខ្ពស់ ក្បៀតបានកិរិយា យសយើង

ពណ្ណកយ គេក្ដីថ្វាយសោះសា ប្រាកដប្រុះប្រា- កថាស្ដើរវែងឆ្ងាយ ។

រីឯសភាព ដំណើរគិរគាត្យ មានតែព្រេងនាយ បរមបុរាណ

និទាននិយាយ តស់តាមបរិយាយ ថែងចប់ម៉្លោះហោង ។

---

www.budinst.gov.kh www.elibraryofcambodia.org

## ៥- រឿងសង្គ្រាមរវាងគីង្គក់និងតាព្រហ្ម(១)

សម័យព្រេងនាយ វេលាមួយ ពិភពលោកកើតទុរ្ភិក្ស ក្តៅហួតហែង គ្រប់ទិសទី ព្រោះព្រះពិរុណមិនបង្អុរភ្លៀងសោះ ស្ទឹង ត្រពាំង ថ្លុក បឹង ព្រែក ទន្លេ រីងទឹកអស់ ៗ សត្វទាំងឡាយស្លាប់គរត្រួតលើគ្នា រុក្ខជាតិនានា ស្វិតក្រៀមក្រញង់ ។ ពួកមណ្ឌុកសត្វមានគីង្គក់ ហ៊ីង កង្កែបជាដើម ដែលជាសត្វប៉ិនគត់ផងក៏ស្គមនៅតែស្បែកនិងឆ្អឹង ។ ថ្ងៃមួយ គីង្គក់ជាមេប្រកាសដល់ក្រុមញាតិ និងហ៊ីងកង្កែបជាមិត្តថា ហៃមិត្តទាំងអស់គ្នា ! មើលទៅតាព្រហ្មមិនបង្អុរភ្លៀងមកឲ្យយើងទេ បើយើងនៅស្ងៀមមុខជាដាច់ពោះស្លាប់ មកវ៉ឺយមិត្តយើងកេណ្ឌគ្នាទៅតយុទ្ធនឹងតាព្រហ្មយកភ្លៀងឲ្យបាន, តាសខ្ទល់ហើយស្ងៀមក៏ស្លាប់ ច្បាំងក៏ស្លាប់ បើមិននឹងស្លាប់ ៗ ត្រូវច្បាំង យកជ័យឲ្យក្រុមញាតិនិងមិត្តប្រសើរជាង មក! មក!

---

១- ស្រង់ពីទស្សនាវដ្ដីកម្ពុជសុរិយា លេខ ១១ ឆ្នាំ ១៩៦០ រៀបរៀងដោយលោក លាង-ហាប់អាន សាស្ត្រាចារ្យ នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ភ្នំពេញ ។

www.budinst.gov.kh www.elibraryofcambodia.org

ទៅប្រយុទ្ធ !” ។ ក្រោយដែលបានប្រកាសយ៉ាងនេះ ពលគីង្គក់និងមិត្រទាំងអស់ ក៏លើកព្យុហយាត្រាទៅតយុទ្ធនឹងតាព្រហ្ម ក្នុងវិមានលោកឰដ៏អាកាស ។ កងទ័ពមណ្ឌុកសត្វហើរកាត់ពពក បន្តិចមកស្រាប់តែប្រទះនូវទ័ពមួយហ្វូងធំទៀត ។ មេបញ្ជាការធំនៃទ័ពគីង្គក់ ឃើញហ្វូងពលត្រីអណ្តែងធំៗ ភ្នាន់ភ្នាប់ ខ្លួនប្រឡាក់ស្រមក ដោយកំទេចម្លូលនិងផែះនៃភលស្រែ ។ មេគីង្គក់សួរថា “ នែវីរយោធា តើឯងទៅណាបានជាប្រទៀលខ្លួនហុយដីទ្រលោម កាត់មុខឲ្យវិនាសដល់កងទ័ពអញនេះ ” ។ ត្រីអណ្តែងជាមេទ័ពតបថា “ ភ្លៀងអើយ ! ពួកមច្ឆាបានបញ្ជូនយើងឲ្យមកជាមួយបងក្រាញ់ ដ៏ប៉ិនប្រសប់ខាងរត់ឆ្លងគោក នឹងធុរកាយណ៍ ដើម្បីច្បាំងនឹងតាព្រហ្ម យកភ្លៀងមកបំពេញបឹង ស្ទឹងយើង ទៅ ! ទៅ ! ភ្លៀង ” ។ គីង្គក់ឮដូច្នោះអរណាស់ ក៏ប្រាប់កងទ័ពខ្លួន ។ មួយរំពេចនោះ សត្វផ្សោតបានកកន់ឮចេញពីទ័ពទាំងពីរក្រុម ហើយទ័ពទាំងនោះក៏ច្របូលគ្នាជាទ័ពមួយយាត្រាទៅតាមពលក្តៅហួតហែង ។ ទៅបន្តិចទៅ ស្រាប់តែឃើញបាណកជាតមួយហ្វូងធំ ហើរទៅភ្នាប់ឮសូរឆ្វូង ៗ លើអាកាស ហើយឮយំនិងទូមាល់ជាមេទ័ពបន្ទូមកថា “ នែ ! បងគីង្គក់ ហ៊ុង កន្ទ្រប ត្រីអណ្តែង ត្រីក្រាញ់ ឯងទៅណាខ្លួនស្រមកយ៉ាងនេះ ? ” ។ គីង្គក់តបថា “ មករុយ ! បងឃ្មុំ ! យើងដឹងហើយថា ក្រុមបងលើកទ័ពទៅច្បាំង ព្រោះអត់ភ្លៀង ខ្វះឈើព្រៃផ្កាធ្វើសំបុកផល់ក្រុមបង មកកុំ

www.budinst.gov.kh www.elibraryofcambodia.org

បង្អន់ យើងត្រូវគ្នាទៅតយុទ្ធនឹងតាព្រហ្មកុំខ្លាចស្លាប់ ! ទៅ ! ទៅ !” ។ ទ័ពគោកកទិនសាកាស ហោរិយកជ័យ ហើយក៏លើកគេទៅទៀត ។ លុះដល់ជិតប៉ការសត្តមួយ ស្រាប់តែទ័ពនេះប្រទះនឹងផ្លូវត្រសក់ស្រូវ ផ្លូក វណ្ណលលើផែនដី ដាច់បេះពាកពន់គួរឲ្យគាស្ញូវ ។ ត្រសក់មួយផ្លែស្រែកដោយមានសន្ធឹមថា “ កៀនអើយ ! ឲ្យគ្នាយើងដោយសារទៅផង ផែរយើងសុគស្លាប់អស់ហើយ កៀនទៅបាំង យើងក៏ស៊ូស្លាប់ជំនួសត្រូសារយើងដែរ មិនឲ្យដៅវេទនាទេ ។ មេទ័ពតាំងបី ក៏យល់ព្រមឲ្យត្រសក់ស្រូវប្រមៀលខ្លួនទៅតាមក្បួន ។ លុះផុតពីពល ក៏បានដល់ព្រៃមួយដែលរុក្ខជាតិតាំងឡាយក្រៀមរញ៉ុមស្លាប់ជិតអស់ ។ កងទ័ពបានទៅដល់ឃើញល្វើងផ្កាធំៗ ពីរដើមនៅនឹងគល់ឈើឆាប់មួយដើម ។ ផ្កាសួរថា “ នែកៀន ! ទៅណាហ្នឹងក៏សង្ខឹកម្ល៉េះ កៀនមិនគាស្ញូវមិត្តរុក្ខជាតិគ្នាយើងទេឬ ? ឃើញទេ ស្លាប់ដេកតគ្នាដោយដៃតាព្រហ្មអស់ហើយ ឲ្យយើងទៅបាំងផង យើងនៅយ៉ាងនេះក៏វេទនាណាស់ យើងស៊ូទៅស្លាប់ក្នុងសង្គ្រាម ដើម្បីជាណ្ដើមយកជ័យ មកផ្ដល់ជីវិតសត្វលោក ។ ទ័ពតាំងអស់ក៏យល់ព្រមឲ្យផ្កាតោបទៅតាមផង ។

ក្រោយមក ទ័ពតាំងអស់ក៏បានដល់ឋានតាព្រហ្ម ។ គង្គក់បានបញ្ជាឲ្យឃុំប្រុងរាយសម្រុក នៅខាងត្បូងខាងមុខនិងខាងក្រោយ ត្រីអណ្ដែងនិងត្រីក្រាញ់ ដែលខ្លួនប្រហ្យាក់នៅដោយក្បួននិងផែះ ឲ្យចូល

www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងពាងទិនផើងទឹកនៅមាត់ទ្វារក្រោយ និងពាងផ្សេងៗ ឲ្យតែមានទឹក ៗ ផ្តៅពាំងពីរធំៗ ឲ្យឈរប្រុងនៅមាត់ទ្វារប្រាសាទ ត្រសក់ស្រូវឲ្យប្រមៀលតោះទៀបជើងក្រោមអាសនៈតាព្រហ្មគង់ ។ ឯក្រុមគន្ធក់ហ៊ីន កន្តែប ជាទ័ពស្រួចអ្នកចូលលុក ។ លុះចាត់ស្រេចហើយ ទ័ពមណ្ឌុកសត្វកំប្លុកប្រែ តម្រង់អាសនៈតាព្រហ្មអាស្រ័យនៅ ដោយស្រែកហោសន្ធាប់យ៉ាំងខ្លាំង ធ្វើឲ្យពលរោទ៍សព្ទពាំងៈទេវតា មេឃ មេគាងទៅជិត ទៅបម ម៉ឺម ខ្នុខណាង ផុតរ រត់ចេញពីប្រាសាទស្ទុះស្ទៅទៅត្រូវទឹកផែះ ទឹកក្បែង ដែលត្រីអណ្តែង ត្រីក្រាញ់ ប្រាចមកលើភ្នកផ្កាស្រាំងរកទិសតំបន់ពុំឃើញ ថែមពាំងត្រូវពួកឃ្មុំ ខុមាលទិប ចុកឈឺមួយ ស្រែកយំរពឹង ។ តាព្រហ្មរកប្រែកចេញពុំបាន ស្រែកសួរថា "ខែទុំយេ! តាពួកគន្ធក់ ហ៊ីន តន្តែបទៅឯង ឯងទៅណា?" ។ ពួកមណ្ឌុកសត្វតបថា "យើងមកចាំង១" ។ តាព្រហ្មចុះចាកអាសនៈឥតមើលក្រោយ គឺជាន់លើត្រសក់ស្រូវរអិលដួលផ្ងារស្រេតាង ត្រូវផ្តៅពាំងពីរបន្ទន់ខ្នងប្រេញាប់បន្តក់តតជាប់ យ៉ូគំទិបឈើផ្កា ស្រែកចុះញ៉មពួកសត្វខឹងរុកផ្ទាត់ថា "ចាញ់ហើយ!១" ។ ពួរជូះព្រោះ មេបញ្ជាការតន្ត្រីកំឃាត់ទ័ពឲ្យឈប់ ដើម្បីដោះស្រាយបញ្ហាចុះចាញ់ ។ តន្ត្រីកសួរទៅតាព្រហ្មបកស័យថា "ម៉េចក៏លោកបង្អត់ភ្លៀងដល់សត្វលោក ធ្វើឲ្យស្លាប់ត្រប់កន្លែងដូច្នេះ! គាយើងមិនសុខចិត្តទេ បើលោកមិនបង្អុរភ្លៀង

www.budinst.gov.kh www.elibraryofcambodia.org

ចុះទៅ នោះយើងនឹងដឹកទេវវិមាននេះលោក សម្រាប់តាំងពលតាំងលោក កុំបាន" ។ តាព្រហ្មទឹកក៏យកនិយាយអង្វររបស់ពលសត្វនិងរុក្ខជាតិថា "សូមពួកព្រះស្តែងកុំខឹង យើងខ្លាចហើយ យើងនឹងផ្តល់ទឹកភ្លៀងឲ្យ ឥឡូវនេះហើយ សូមអស់អ្នកអញ្ជើញទៅវិញចុះ កុំខឹងអី" ។ តង្គក់តបថា "ទេ! គង់យើងមិនព្រមទេ បើយើងទៅ នោះលោកនឹងផ្តល់ភ្លៀងឲ្យយើងតែមួយមេ ហើយព្រងើយកន្តើយទៅ នាំឲ្យពិបាកយើងលើកទ័ពឡើងមកទៀត, ដូច្នេះ សូមលោកសន្យាឲ្យពរពិសេសដល់យើងសិន ទើបគេយើងសុខចិត្ត" ។ លុះសញ្ជឹងមួយសន្ទុះ តាព្រហ្មក៏ពោលថា "អើ! យើងព្រមឲ្យពរដល់អ្នកកល់គ្នាហើយ, បើដូច្នេះពេលណាអ្នកត្រូវការភ្លៀង ចំណែកតង្គក់ ហ៊ឹង កង្កែបត្រូវសង្កៀតធ្មេញបន្លឺសំឡេងពីក្រោមមក ពេលនោះយើងបង្អុរឲ្យអ្នកភ្លាម ។ កាលសន្យារួចស្រេច ទ័ពមណ្ឌុកសត្វ បាណកសត្វ និងរុក្ខជាតិក៏ថយមកលំនៅរៀងៗខ្លួន ។ តាំងពីនោះមក ពេលណាតង្គក់ ហ៊ឹង កង្កែបត្រូវការភ្លៀង ក៏សង្កៀតធ្មេញបន្លឺសំឡេងក្រែតៗ! អែបៗ! គោកៗ! ហ៊ឹងហ៊ឹងៗ! ភ្លៀងក៏ធ្លាក់មក ។

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# ៦- រឿងដើមកំណើតសត្វមូស(១)

នៅក្នុងបឋមកប្ប, ព្រះឥសូរជាអ្នកបង្កើតលោក មានបង្កើតពាំងសត្វគ្រប់យ៉ាងនៅលើផែនដីជាដើម តែទ្រង់បានបង្កើតសត្វមូសមុនគេបង្អស់ ។

សម័យនោះ សត្វមូសមានខ្លួនធំៗ ជាងសត្វត្មាតទៅទៀត ហើយវាតែងហើរជាច្រើនឥតឈប់ឈរ ស្វែងរកស៊ីមនុស្សលោកជាអាហារ, មនុស្សណាដែលត្រូវជាចំណីសត្វមូស គេឃើញនៅសល់តែឆ្អឹង គ្មានសាច់ឈាមឡើយ ។

មនុស្សម្នាមហាជន មានសេចក្តីតក់ស្លុតជាក្រៃលែង តែគ្មាននរណាម្នាក់ រកមធ្យោបាយការពារសត្វមូសបានឡើយ ក៏ដាក់វេនគ្នាឲ្យ

---

១- ដកស្រង់ពីក្នុងសៀវភៅ ប្រតិទិនកម្ពុជា, បោះពុម្ពផ្សាយដោយក្រុមសមាគមសុនារស កាលពីឆ្នាំ ១៩៤៦, រៀបរៀងដោយលោក សក៉ា - ខាត់ តំកល់នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ។ លេខ ម ១៤៨១ ទំព័រ ១១៥ ។ មានការកែសម្រួលពីច្បាប់ដើមខ្លះ ។

www.budinst.gov.kh www.elibraryofcambodia.org

មូសស៊ីរៀងរាល់យប់ ។ ចាប់តាំងពីថ្ងៃនោះមក, ជនដែលដឹងថា វេនខ្លួនជិតមកដល់ហើយក៏យំសោកហេតុខ្លួនបាត់ប្រាណ ។

គាប់ជួនជាពេលនោះ មានកូនក្រមុំសេដ្ឋីម្នាក់ ប្រកបដោយបញ្ញាក្លៃ នាងកាលណាឮការសួរអ្នកស្រុកដែលបានដាក់វេនគ្នាទៅឲ្យសត្វមូសស៊ីនោះក្រោយគេ នាងគិតក្នុងចិត្តថា បើអញមិនជួយរកមធ្យោបាយស្រោចស្រង់មនុស្សទាំងអស់ដោយឥតរើសមុខទេ, អ្នកទាំងអស់នោះប្រាកដជាគេចពីចំណីមូសពុំបាន, ហើយគេទៅប្រាកដជាគ្មានមនុស្សរស់នៅទៀតឡើយ" ។ កាលបើបានគិតឃើញយ៉ាងនេះ នាងក៏ចូលទៅជួបនឹងឪពុកម្ដាយហើយនិយាយថា "ខ្ញុំចង់ទៅឲ្យមូសស៊ីជាមួយនឹងគេឯទៀតដែរ" ។

កាលបើឮសេចក្ដីដូច្នេះ, ឪពុកម្ដាយរបស់យុវតីក៏កើតទោសៈជាខ្លាំង, គាត់ឆ្លើយមកកាន់យុវតីវិញថា "ហេតុម្ដេចបានជាកូនឯងគិតដូច្នេះ? មនុស្សក្នុងនគរនេះ គេមានតែពឹងគេចរត់ឲ្យផុតពីសេចក្ដីស្លាប់, ចុះកូនឯង, ម្ដេចក៏ល្ងើតកថាសទៅជាចង់ទៅស្លាប់វិញ" ។ ទោះបីឪពុកម្ដាយថាដូច្នោះ ក៏យុវតីមិនព្រមឈប់អង្វរឪពុកម្ដាយទៅឲ្យមូសស៊ីនោះឡើយ ។ ឪពុកម្ដាយកាលបើឃើញកូនស្រីខ្លួន នៅតែរឹងចចេស មិនព្រមស្ដាប់ពាក្យទូន្មានគាត់សោះដូច្នោះ ក៏កើតទោសៈធ្ងួលធេះឥតឧបមា ទើបនិយាយថា "អើឥឡូវបើឯងចង់ស្លាប់ មិនព្រម

www.budinst.gov.kh www.elibraryofcambodia.org

ស្លាប់អញ ទៅ, ទៅឲ្យបាត់ពីមុខមាត់អញទៅ ។

នាងកញ្ញាកូនសេដ្ឋីឮដូច្នោះ ក៏ពោរពេញទៅដោយសេចក្ដីសប្បាយ; ហើយដើរសំដៅទៅកន្លែងដែលមនុស្សត្រូវទៅនៅឲ្យមួសស៊ី ។ នាងបានទៅជួបនឹងអ្នកស្រុក ដែលត្រូវវេនទៅឲ្យមួសស៊ី ហើយនិយាយថា "បើអ្នកកាប់គ្នាចង់គេចឲ្យរួចពីសេចក្ដីស្លាប់ ចូរអ្នកធ្វើតាមខ្ញុំ ។ នឹងបង្គាប់ឲ្យធ្វើ, នោះអ្នកប្រាកដជាគេចរួចពីសេចក្ដីស្លាប់ពុំខាន គឺត្រូវអ្នកទាំងអស់គ្នាទៅកេប្រមូលស្លឹកឈើស្ងួតៗ ស្ងួតៗ ឲ្យបានច្រើនយកមកទីនេះ ហើយកាលបើសត្វមួសភក់ហើរមកជិតយើង ។ ត្រូវដុតភ្លើងឲ្យឆេះហុយផ្សែងទៅជុំវិញយើង ហើយយើងចូលគ្នាទៅកន្លែងកណ្ដាលភ្លើងនោះ, ធ្វើដូច្នេះ សត្វមួសមិនហ៊ានហើរចូលភ្លើងផ្សែងមកស៊ីយើងទេ" ។

មនុស្សទាំងឡាយយល់នូវបំណាច់នៃនាងកញ្ញា ហើយក៏ត្រូវធ្វើតាមនាងទាំងអស់ ។ លុះវេលាយប់, ពួកសត្វមួសក៏មកដល់តាមទម្លាប់ស៊ីមនុស្ស ។ នៅពេលនោះ, ពួកអ្នកស្រុកក៏ដុតភ្លើងឆេះសន្ធោសន្ធៅឡើង មិនឲ្យលេច តាមបង្គាប់បុត្រីសេដ្ឋី ។ សត្វមួសឃើញដូច្នោះ ពុំហ៊ានហើរចូលកាត់ភ្លើងផ្សែងទៅខាំស៊ីមនុស្សឡើយ ហើយក៏ប្រមូលគ្នាមកកកុញជុំគ្នាថា "បើយើងនៅតែមានខ្លួនតដូច្នេះតទៅទៀត នោះយើងត្រូវតែអត់ខាំមនុស្សលោកស៊ីពុំបាន ពីព្រោះកាលណាគេដុតភ្លើងឲ្យឆេះឡើងដូច្នេះ យើងពុំអាចចូលទៅជិតគេបានឡើយ អាស្រ័យ

ហេតុនេះ ចូរយើងចូលទៅទូលព្រះឥសូរ ដែលជាអ្នកបង្កើតយើងមក សូមឲ្យព្រះអង្គធ្វើខ្លួនយើងឲ្យទៅជាតូចៗវិញ ប្រយោជន៍យើងនឹងស្រួលលបចូកខាំមនុស្សបាន កុំឲ្យមនុស្សលោកមើលឃើញ, បើធ្វើដូច្នេះឃើញថាស្រួលជាង" ។

បន្ទាប់មក ពួកមូសក៏មូលមតិគ្នា ប្រមូលគ្នាហើរទៅកាន់ស្ថានសួគ៌ គោរពវន្ទាព្រះឥសូររួចហើយ, ក៏សុំព្រះឥសូរឲ្យធ្វើខ្លួនវាទៅជាតូចៗ ល្អិតៗ សមទៅតាមបំណងរបស់វា ។ នៅពេលនោះ ព្រះឥសូរក៏ធ្វើខ្លួនសត្វមូសឲ្យតូចៗ ដូចជាសត្វមូសសព្វថ្ងៃនេះ ។ កាលបើបានខ្លួនតូចដូចបំណងហើយ សត្វមូសក៏ថ្លែងអំណរគុណព្រះឥសូរ រួចលាព្រះអង្គត្រឡប់មកស្ថានមនុស្សលោកវិញ, ហើយក៏ហើរត្រាច់ពីភូមិមួយទៅភូមិមួយស្វែងរកខាំមនុស្សលោក ។ ប៉ុន្តែ មនុស្សលោកបេះដៃយកដៃទះវាស្លាប់អស់ ខ្លះក៏នៅរស់តែធ្លាក់ស្លាបបាក់ជើង ។ ដូច្នេះ មនុស្សលោកក៏បានធូរចិត្តហើយមានសេចក្ដីសប្បាយច្រើនលើសមុន ។

ពួកមូសក៏ប្រជុំផ្តុំគ្នាសាជាថ្មីទៀតថា "ឥឡូវមនុស្សលោកគេធ្វើបាបយើងខ្លាំងណាស់ គេទះ គេវាយយើង ហើយគេនឹងសម្លាប់យើងឲ្យអស់ពូជ យើងពុំអាចខាំមនុស្សលោកបានទៀតឡើយ, ហេតុដូច្នេះត្រូវយើងនាំគ្នាទៅរកព្រះឥសូរម្តងទៀត ដើម្បីសុំព្រះអង្គធ្វើមាត់យើងឲ្យស្រួចៗដូចម្ជុល ដើម្បីយើងអាចខាំមនុស្សលោកបានងាយរហ័ស កុំឲ្យ

www.budinst.gov.kh www.elibraryofcambodia.org

មនុស្សលោកដឹងថាយើងខាំគេ" ។

កាលដំឌុំបានមូលមតិជាឯកច្ឆន្ទ, ទើបសត្វមូសបបួលគ្នាហើរទៅកាន់ស្ថានសួគ៌, លុះទៅដល់ ក្រោយពីបានគំនាប់គាប់គួរព្រះឥសូរហើយ, សត្វមូសក៏ទូលសុំព្រះឥសូរឲ្យធ្វើមាត់ខ្លួនឲ្យតូច ៗ ដើម្បីស្រួលខាំមនុស្សលោក ។ ព្រះឥសូរក៏ទ្រង់ឆ្លើយតបមកវិញថា "នែមូស! មាត់ដែលយើងបានធ្វើឲ្យអ្នកឯងនេះវាស្រួលល្មមណាស់ទៅហើយ ប៉ុន្តែបើអ្នកឯងចង់ខាំមនុស្សលោកឲ្យបានរហ័សហើយមុតទៀត, នោះ ចូរអ្នកឯងទៅរកព្រួនមួយ ៗ ម្នាក់ ដើម្បីជួយសំពងពីលើថែមទៀត, ប៉ុន្តែចូរអ្នកដឹងថាមនុស្សលោកគេមានព្រួននេះស្រេចហើយ ដូច្នេះចូរអ្នកត្រឡប់ទៅវិញចុះ" ។

ពួកមូសក៏ហើរត្រឡប់មកស្ថានមនុស្សលោកវិញ ហើយវាហើរត្រាច់រកខាំមនុស្សលោកទាំងយប់ទាំងថ្ងៃ នៅគ្រប់ចន្លោះកៀនគោះគ្រប់នគរ ដោយយកស្លាបធ្វើជាអន្ទូងក្បាលស្នា, ហើយវាយមនុស្សលោកដោយហើរទាំងយ៉ាងរហ័សបំផុត ដូចព្រះឥសូរបានបង្គាប់វា ។

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

## ៧- រឿងឧកញ៉ាយោមរាជនិងឧកញ៉ាពលទេព(១)

កាលពីព្រេងនាយ មាននាម៉ឺន ២ នាក់ ម្នាក់ជាឧកញ៉ាយោមរាជ ម្នាក់ទៀតជាឧកញ៉ាពលទេព ។ ឯឧកញ៉ាពលទេពជាមនុស្សលោភបុណ្យសក្តិ ចង់បានទីយោមរាជ កើតគំនិតស្នួចឧកញ៉ាយោមរាជ គិតស្វែងរកទោសដាក់ទីងក្រាបទូលស្តេចទំលាក់ចាកទីយោមរាជ គាត់ឯងចង់បានស័ក្តិយោមរាជនោះតទៅ ។ ឧកញ៉ាពលទេពស្វែងរកទោសលោកយោមរាជនោះជាយូរខែមក ។ ថ្ងៃមួយមានអ្នកទោសម្នាក់ជាប់ទោសធ្ងន់ត្រូវជំនុំកាត់ទោសដល់ប្រហារជីវិត ។ ឯអ្នកនោះដឹងថាថ្ងៃព្រឹកស្អែកនេះគេនឹងនាំគាត់ទៅសម្លាប់ជាប្រាកដ ក៏តាំងសៅសោកវិយោគស្តាយជីវិតមហិមា យំគណនាថា "ឱ ! ជីវិតអញអើយ ! ព្រឹកស្អែកនេះហើយនឹងបង់ចាកប្រាណ អើត្រង់ក្តីស្លាប់ ១ នេះនរណាទៀតនឹងវៀរចង់បាន តែកើតឡើងហើយ រមែងតែងស្លាប់ជាធម្មតា តែថាត្រង់ជីវិត ១ នេះសោះមិនបាត់ទៅក្តី ក៏មិនសូវជាសោកស្តាយអ្វីប៉ុន្មាន មកសោកស្តាយតែវិជ្ជា១

---

១— ដកស្រង់ពីក្នុងសៀវភៅគតិលោកភាគ ៦ រៀបរៀងដោយលោកឧកញ៉ា សុត្តន្តប្រីជាឥន្ទ។

www.budinst.gov.kh www.elibraryofcambodia.org

ដែលខ្ញុំបានបេះហើយ ពុំទាន់បានបង្ហាត់បង្ហាញនរណា ១ សោះ បើព្រឹកនេះខ្ញុំស្លាប់ហើយ វិជ្ជានេះមុខនឹងជាសូន្យសោះ ឥតមាននរណាមួយក្នុងលោកនេះ អាចបេះតទៅទៀតបានឡើយ" ។

កាលនោះមាននាយឆ្មាំពន្ធនាគារម្នាក់ បានឮចៅនោះពណ៌នាសោកស្តាយវិជ្ជាដូច្នោះ ក៏ចូលទៅសាកសួរថា "ចៅឯងព្រឹកនេះដល់ទីស្លាប់ប្រាកដហើយ ចៅយំរៀបរាប់ថាត្រង់ជីវិត រូបកាយមិនសូវស្តាយប៉ុន្មាន មកស្តាយវិជ្ជា ១ ដែលបេះមក តើវិជ្ជានោះឈ្មោះអ្វី ចៅបេះវិជ្ជាអ្វី ចូរប្រាប់យើងមើល" ។

ឯអ្នកទោសក៏ប្រាប់ថា "ខ្ញុំបានបេះវិជ្ជាស្តាប់ភាសាសត្វ វិជ្ជានេះវិសេសរបស់ខ្ញុំណាស់ ក្នុងលោកនេះគ្មាននរណាបេះសោះ តែខ្ញុំបានដល់ទីស្លាប់ហើយ វិជ្ជានេះសូន្យតែម្តង ព្រោះពុំមាននរណាបានមករៀនតទៅឡើយ" ។ នាយឆ្មាំពន្ធនាគារឮដូច្នោះ ក៏នាំសេចក្តីនុះទៅជំរាបលោកឧកញ៉ាយោមរាជសព្វប្រការ ។ ឧកញ៉ាយោមរាជក៏នឹកក្នុងចិត្តថា វិជ្ជានេះវិសេសក្រៃពេក គួរតែរៀនយក ទើបនាំនាយឆ្មាំពន្ធនាគារទៅដោះអ្នកទោសមកទុកឃុំឃាំង ហើយសួរបញ្ជាក់ថា "ពិតឬពុំពិត"? ។ អ្នកទោសក៏ឆ្លើយថា "នេះពិតប្រាកដមែន" ។ ឧកញ៉ាយោមរាជថា "បើយើងសុំរៀនពីចៅឯង តើបានឬមិនបាន? ហើយវិជ្ជានេះតម្លៃប៉ុន្មាន?" ។

www.budinst.gov.kh www.elibraryofcambodia.org

អ្នកទោសថា “ខ្ញុំបាទជួនព្រះតេជព្រះគុណបាន សូមព្រះតេជព្រះគុណរៀនតទៅចុះ តែអត់អំពីខ្ញុំប្របាទនេះហើយ វិជ្ជានេះនឹងសូន្យជាប្រាកដ តែការនឹងរៀននោះតោងទៅតាំងពិធីរៀនទៅក្នុងព្រះវិហារចំពោះព្រះភក្ត្រព្រះបដិមាករជាប្រធាន ឯគ្រឿងកំណាល់គ្រូនោះមិនមានអ្វីច្រើនទេ ត្រូវការតែទៀន ៥ ធូប ៥ លាជ ៥ ផ្កា ៥ ប៉ុណ្ណោះឯង អញ្ជើញព្រះតេជព្រះគុណរៀបរៀនឲ្យដាច់ចុះ តែព្រឹកស្អែក ខ្ញុំប្របាទលាព្រះតេជព្រះគុណទៅស្រុកខ្មោចហើយ” ។

ឧកញ៉ាយោមរាជធ្វើតាម ទើបឲ្យនាយឆ្មាំពន្ធនាគារនាំខ្លួនអ្នកទោសទៅឯវត្ត ដល់ហើយគឺនាំចូលទៅក្នុងព្រះវិហារ ឲ្យបិទទ្វារវិហារជិតគាំងឥតសល់ កុំឲ្យមនុស្សណាមួយឮឡើយ ឧកញ៉ាយោមរាជក៏តាំងរៀបទៀនធូបលាជផ្កា នៅចំពោះព្រះភក្ត្រព្រះ ហើយថាពិធីរៀននោះតើដូចម្ដេចខ្លះ ចូរទៅបង្គាប់ទៅមើល យើងនឹងធ្វើតាម អ្នកទោសបង្គាប់ឲ្យអុជទៀនធូបហើយ ឲ្យលោកយោមរាជ និងខ្លួនវា ក្រាបថ្វាយបង្គំព្រះ សូត្រនមស្ការពុទ្ធគុណ ធម្មគុណ សង្ឃគុណ ចប់ចុះ ហើយអ្នកទោសប្រណម្យដៃពោលផ្ដើមឡើងថា “ឱ! ព្រះដ៏មានបុណ្យព្រះគុណប្រកបដោយមហាករុណា តែងតែប្រោសមេត្តាសត្វ ដែលកើតមានក្ដីវិបត្តិ ចូលមកពឹងពោធិសម្ភារ ជួយដោះទុក្ខសត្វឲ្យសត្វបានក្ដីសុខសម្រាន្តទាំងលោកនេះនិងបរលោក, ព្រះពុទ្ធជាម្ចាស់អើយ! ខ្ញុំព្រះករុណានេះ ត្រូវទោសធំ

www.budinst.gov.kh www.elibraryofcambodia.org

ណាស់ ព្រឹកស្អែកនេះហើយ លោកនុកញ្ញាំយោមរាជ ទើបឲ្យនាំទៅប្រហារជីវិតខ្ញុំព្រះករុណា ៗ មានក្ដីភិតភ័យខ្លាចក្ដីស្លាប់នោះជាបំផុត ស្ដាយជីវិតក្រៃពេកណាស់ ព្រះគុណអើយ ! សូមព្រះអង្គទ្រង់ប្រោសបិណ្ឌបាតជីវិតខ្ញុំព្រះករុណា អំពីលោកនុកញ្ញាំយោមរាជនេះ ឲ្យលោកប្រោសលែងខ្ញុំ ឲ្យរួចចាកក្ដីស្លាប់ក្នុងគ្រាម្ដងនេះ” ជាហើយអ្នកទោសក៏ទៅក្រាបទៀបបាទជើងលោកយោមរាជហើយដង្ហោយថា “ឱព្រះតេជព្រះ-គុណអើយ! សូមប្រោសអត់ទោសខ្ញុំប្របាទនេះ ហេតុដែលខ្ញុំប្របាទសោក ពោលថា ស្ដាយវិជ្ជាចេះភាសាសត្វនោះ ខ្ញុំមិនចេះវិជ្ជានោះទេ គឺខ្ញុំសោកស្ដាយជីវិតពិត ៗ គិតបញ្ឆោតឲ្យព្រះតេជព្រះគុណអញ្ជើញមកកាន់ព្រះវិហារនេះឯង ដើម្បីឲ្យព្រះសម្មាសម្ពុទ្ធជាម្ចាស់ គឺព្រះពុទ្ធរូបនេះទ្រង់បិណ្ឌបាតជីវិតខ្ញុំប្របាទ អំពីព្រះតេជព្រះគុណ ឱព្រះតេជព្រះគុណអើយ ! ប្រោសថ្វាយជីវិតខ្ញុំប្របាទ ដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទៅឲ្យព្រះអង្គទ្រង់បិណ្ឌបាតហើយ ; ព្រះគុណអើយ ! ការបូជាដោយគ្រឿងអាមិសតាមឯទៀត ៗ នោះ មានផលានិសង្សពុំស្មើនឹងការបូជាជីវិតខ្ញុំប្របាទដល់ព្រះពុទ្ធជាម្ចាស់ក្នុងគ្រានេះឡើយ ផលនេះហើយជាផលយ៉ាងធំបំផុត ព្រះតេជព្រះគុណនឹងប្រាថ្នាសាងជាពុទ្ធភូមិ ឬអរហន្តភូមិក៏អាចសម្រេចដូចក្ដីប្រាថ្នាទៅអនាគតកាល ” ។ ឯលោកនុកញ្ញាំយោម-រាជ លុះឮពាក្យអ្នកទោសពោលដង្ហោយដូច្នោះ ក៏ដូចជាគេភ្ញាក់ដំណេក

www.budinst.gov.kh www.elibraryofcambodia.org

មក ទឹកឃើញថា ចាញ់កលឧបាយអ្នកទោសជាប្រាកដ ទើបនិយាយទៅកាន់នាយឆ្មាំគុកថា “ តើយើងចាញ់កលអ្នកទោសនេះហើយ ឥឡូវរកពេលពាក្យផ្ដោយសូមជីវិតរបស់ព្រះពុទ្ធរូប រាល់ព្រះពុទ្ធជាឲ្យទ្រង់ចិណ្ណបាត់ទោសរកឯងជាមុន ការនេះតែយើងមិនលែងរក ក៏ដូចជាយើងមិនគោរពដល់ព្រះពុទ្ធជាម្ចាស់ ហាក់ដូចជាយើងផ្ដាសា គុណព្រះ-ពុទ្ធសាសនា បើដូច្នេះនាយឆ្មាំឯងនិងខ្ញុំ យើងពីរនាក់ទូលសុំលើកជីវិត ថ្វាយដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ចុះ ហើយយើងពីរនាក់ទទួលកែខែជាក្រោយ នឹងយើងមិនបាំងឲ្យជិតកុំឲ្យខ្លួនក្លាយព្យបលើគេទៀតអ្នកផងឯងទៀតឡើយ ” ។

ឯនាយឆ្មាំក៏ព្រមតាម ទើបលោកយោមរាជឲ្យនាយឆ្មាំស្រាយចំណងហើយថា “ យើងលែងហើយឯងហើយ ចូរទៅរត់ទៅនៅទីណាមួយ ដែលជាទីរក្សាជីវិតឯងចុះ ហើយកុំនិយាយប្រាប់គេថា យើងដោះលែងហើយឯងហើយឯងចូរថាកាត់ប្រាកដតែពីគុកទៅចុះ តទៅមុខទៀត ហៅកុំប្រព្រឹត្តការលោភលន់យ៉ាងនេះទៀតឡើយ ” ។ ឯអ្នកទោសក៏ក្រាបថ្វាយបង្គំព្រះហើយក្រាបលាលោកយោមរាជ និងនាយឆ្មាំ ហើយក៏រត់ចេញទៅស្រុកក្រៅ លាក់ខ្លួនកុំឲ្យពួករាជការឃើញឡើយ ។

ឯឧកញ៉ាយោមរាជ ក៏នាំនាយឆ្មាំថ្វាយបង្គំលាព្រះពុទ្ធរូប ហើយវិលទៅកាន់លំនៅជាសុខសប្បាយ កំចាយតែសត្វប្រាប់គេថា អ្នកទោស

www.budinst.gov.kh www.elibraryofcambodia.org

នោះគាប់ប្រាក់រត់ចេញតាកគុកទៅបាត់ហើយ ។ លុះកន្លងកាលយូរមក រឿងនោះពុំស្ងាត់បាត់ទៅឡើយ ជាហេតុឲ្យដំណឹងឮទៅដល់ឧកញ្ញាពលទេព ។ មានចិត្តត្រេកអរដោយសមតាមគំនិត ដែលគិតរកឧកាសនឹងក្រាបទូលព្រះរាជាឲ្យដកងារឧកញ្ញាយោមរាជនេះ អាគ្មានគង់នឹងបានទីនោះ ។ សម័យថ្ងៃមួយ ជាពេលាព្រឹក ព្រះរាជាស្ដេចចេញអង្គាសភត្ត ដាក់បាត្រលោកសង្ឃ ស្ដេចកំពុងចុកបាត្រ មានហ្វូងក្អែកទាំងឡាយហើរមកស្រែកការញ្ញៀវកងរំពងទាំងផ្ទៃវាំង ក្អែកពួកខ្លះហើរស្រែកយំ ទំតាមដើមឈើ តាមដំបូលប្រាសាទ ដំបូលដំណាក់ទីទៃៗ ។

ឯព្រះបរមបក្រី លុះស្ដេចចុកបាត្រស្រេចហើយ ទ្រង់ត្រាស់ថា “ សាសត្វក្អែកសព្វនេះ មានហេតុអ្វី បានជាថ្ងៃនេះវានាំគ្នាមកស្រែកគឹកកងកោលាហលយ៉ាងនេះ ធ្វើម្ដេចទើបបានដឹងភាសាវានេះ ! ” ។

ឯឧកញ្ញាពលទេពអង្គុយគាល់នៅទីនោះ លុះបានឮព្រះបន្ទូលដូច្នោះ បានឱកាសទើបក្រាបទូលឡើងថា “ សូមទ្រង់ព្រះមេត្តាប្រោស មនុស្សយើងទាំងឡាយ ក្នុងព្រះនគរនេះ ពុំមាននរណាមួយអាចចេះភាសាសត្វឡើយ ឮថាអ្នកឧកញ្ញាយោមរាជ គេចេះភាសាសត្វ ដោយគេបានរៀនអំពីអ្នកទោសដល់ទីប្រហារជីវិតម្នាក់ ហើយបានលែងអ្នកទោសជាគ្រូគេនោះបង់ សូមទ្រង់ព្រះមេត្តាប្រោស ឲ្យហៅមកសួរគង់ទ្រង់ជ្រាប ” ។ ព្រះរាជាបានទ្រង់ព្រះសណ្ដាប់ដូច្នោះ ក៏ប្រើរាជបម្រើម្នាក់ ឲ្យទៅហៅ

www.budinst.gov.kh www.elibraryofcambodia.org

ឧកញ៉ាយោមរាជចូលមកគាល់ ។ ឧកញ៉ាយោមរាជ ឮថាទ្រង់មាន
ព្រះរាជឱង្ការឲ្យហៅទៅគាល់ដូច្នោះ ក៏នឹកពិគាល់ក្នុងចិត្តថា ទ្រង់ឲ្យរក
ខ្លួនចូលទៅនេះ មុខជាមានការប្លែកប្រាកដ ទើបសួរទៅកាន់រាជបម្រើ
នោះថា "តើអ្នកណាគាល់នៅក្នុងទីនោះខ្លះ ?" ។ រាជបម្រើជម្រាប
ថា "លោកឧកញ៉ាពលទេពគាល់នៅទីនោះ" ។ ឧកញ៉ាយោមរាជ
ឮដូច្នោះ ក៏ដឹងខ្លួនថាអាពលទេព វាគង់ក្រាបទូលពោលទោសអញជា
ប្រាកដ គិតហើយឧកញ៉ាយោមរាជរៀបគាថាមន្តទៅជាមួយនឹងរាជ
បម្រើនោះ លុះដល់ហើយក៏ចូលទៅក្រាបបង្គំអង្គុយគាល់ក្នុងទីដ៏គួរសម ។
ឯព្រះរាជាទតយល់ឧកញ៉ាយោមរាជចូលមកគាល់ហើយ ក៏ត្រាស់ថា
"អើអ្នកយោមរាជ ឥឡូវឧកញ៉ាពលទេពគេក្រាបទូលយើងថា អ្នកឯងបាន
រៀនគាថាវត្ថុអំពីអ្នកទោសម្នាក់ ហើយអ្នកឯងបានលែងអ្នកទោសនោះ
ចេញពីគុកទៅ ឥឡូវហ្នឹងសត្វក្អែកទាំងឡាយវាអកប្រកែកគ្រៀវ កង
រំពងជាកោលាហល យល់ជានឹងមានហេតុអ្វីមួយពុំខាន បើដូច្នេះអ្នកឯង
ចេះគាថាសត្វ ចូរស្តាប់វានិយាយគ្នាទៅមើល" ។ ឧកញ៉ាយោមរាជ
ក៏ទទួលព្រះឱង្ការទូលសុំទោសតាមថា "ខ្ញុំបានរៀនចេះដឹងគាថាសត្វ
ពិតប្រាកដមែន" លុះឮព្រះឱង្ការប្រើឲ្យស្តាប់សត្វក្អែកដូច្នោះ ក៏ធ្វើជា
បែរផ្ទៀងត្រចៀកស្តាប់សត្វក្អែកម្ខាង ហើយបែរទៅស្តាប់សត្វក្អែកម្ខាង
ទៀត លុះស្តាប់សត្វក្អែកបន្តិច ក៏ក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តា

www.budinst.gov.kh www.elibraryofcambodia.org

ក្រោស ហ្វូនក្អែកដែលទំលើដើមឈើនោះ ជាហ្វូនក្អែកស្រុកក្រៅ ដែលទំលើកំពូលមហាប្រាសាទនោះ ជាហ្វូនក្អែកនៅកណ្ដាលក្រុងនេះ” ។ ព្រះបាទព្រហ្មទត្ត ក៏ត្រាស់សួរទៅវិញថា “ចុះក្អែកស្រុកក្រៅហ៊ានមកយកគង់ តើកើតជាដូចម្ដេច? ក្អែកកណ្ដាលក្រុង តើកះគ្រៀវជាដូចម្ដេច?” ។ អ្នកឧកញ៉ាក្រាបទូលថា “ក្អែកស្រុកក្រៅ មានក្ដីក្ដៅក្រហាយ ដោយអ្នកស្រុកក្រៅពុំបានធ្វើបុណ្យទាន ដូចពីឆ្នាំមុនៗ គឺឆ្នាំមុនៗ ប្រជា-កសិករសម្បូណ៌ស្រូវអង្ករ គេនាំគ្នាធ្វើបុណ្យនិមន្តលោកសង្ឃពាន់ តាមកុម្ពលំនៅ ឯចំណីអាហារដែលសេសសល់នោះ គេបោះឲ្យទានក្អែក ឬសត្វឯទៀតៗផង បណ្ដាសត្វទាំងឡាយមានក្អែកជាដើម សឹងបានបរិភោគចំណីដែលសល់នោះខ្ទៅ សេចក្ដីសុខសប្បាយក៏មានគ្រប់ជំពន់ ឥឡូវឆ្នាំនេះ លោកឧកញ៉ាពលទេពជានាយកក្សេត្រ ចាត់មកនិងកាច-ហ្វូនចេញទៅកត់ស្រូវ មិនត្រូវតាមប្រពៃណី គឺយកពន្ធពីកស្ត្រលើសប្រមាណ កសិករមានស្រូវតែត្រឹម ៤-៥ ថាំងក៏កត់គ្នាឲ្យជាប់ពន្ធដែរ ឧកញ៉ាពលទេពឲ្យកត់ផលទៅស្រូវពូជ ស្រូវដំណើប ស្រូវចំការប្រាំង យកជាពន្ធទាំងអស់ មួយទៀតស្រូវគ្នាមានតែត្រឹម ៥០-៦០ ក៏ទារយកបន្ថែមដាក់ថា ៩០-១០០ កសិករគ្មានអ្វីក៏មិនបាន យកបុណ្យស័ក្តិសក្កបង្ក្រាបគ្នាទៅតាមអំពើចិត្តរៀងៗ ពួកប្រជាកស្ត្រកើតក្ដីក្រលំបាកបានក្ដីក្ដៅក្រហាយគ្រប់ៗគ្នា បានជាឆ្នាំនេះមិនមាននរណាអាចធ្វើបុណ្យ

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យតានដូចឆ្នាំមុនៗ បាន ពួកក្អែកទាំងឡាយពុំបានទទួលទានបាយសម្ល ដែលសេសអំពីការបុណ្យទាននោះឯង ទើបក៏នាំគ្នាចូលមកក្នុងក្រុង ដើម្បីថ្លែងសេចក្តីលំបាករបស់រាស្ត្រដល់ពួកក្អែក បណ្តាជាញាតិនៅក្នុងក្រុងឲ្យពួកក្អែកក្នុងក្រុងនាំសេចក្តីក្តៅក្រហាយឡើងក្រាបបង្គំទូល ព្រះករុណាជាអម្ចាស់ផែនក្រោមទ្រង់ជ្រាប ការឧកញ៉ាពលទេពប្រព្រឹត្តខុសព្រះរាជបញ្ញត្តមានសភាពយ៉ាងនេះ សូមល្អិតធូលីព្រះបាទសម្តេចទ្រង់ជ្រាប” ។

ព្រះបរមរាជា បានទ្រង់ព្រះសណ្តាប់ពាក្យឧកញ៉ាយោមរាជដូច្នោះ ក៏ត្រូវព្រះទ័យ ទើបទ្រង់ខ្ញាល់ខឹងឧកញ៉ាពលទេព ជាទោសកាចឆបោករាស្ត្រ ធ្វើឲ្យប្រជារាស្ត្រក្តៅក្រហាយ ទាំងព្រះរាជអាណាខេត្ត ស្តេចទ្រង់ឲ្យដកងារឧកញ៉ាពលទេពចេញចាកមុខងារមន្ត្រី ប្រោសប្រទានឧកញ៉ាយោមរាជឡើងទីជា សម្តេចចៅហ្វាទឡ្ហ អគ្គមហាសេនា ស្តីទីរាជការជាអធិបតី ក្រសួងនានាតទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

## ៨- រឿងដើមកំណើតរន្ទះ(១)

កាលពីព្រេងនាយ មានបិសាចមួយ ឈ្មោះរាមាសូរ និងនាង អាកាសទេវីមួយ ឈ្មោះមេខលា ។ អ្នកទាំងពីរបានទៅបំរើមហាឫសី ដើម្បីនឹងរៀនវិជ្ជាមន្តអាគមគាថា ។ បិសាចនិងនាង អាកាសទេវីបានខំរៀនប្រណាំងប្រជែងគ្នា ដើម្បីបំពេញចិត្តគ្រូរៀងខ្លួន ហើយអ្នកទាំងពីរប្រកបដោយបញ្ញាវៃក្រៃលែងដូចគ្នា ។ តាបសក៏ ស្រឡាញ់អ្នកទាំងពីរនោះស្មើគ្នា ។ កាលបើតាបសបានបង្រៀនសិស្ស លោកចប់គ្រប់មុខវិជ្ជាហើយ, លោកក៏ចង់ល្បងវិជ្ជាសិស្សមើលថា តើ នរណាពូកែប្រសប់ជាងគេ ។ ទើបលោកនិយាយទៅកាន់សិស្សថា “បើអ្នកណាមួយ យកកែវមួយមានទឹកសន្សើមពេញមកឲ្យខ្ញុំបាន នោះ ខ្ញុំនឹងធ្វើទឹកនោះ ឲ្យក្លាយទៅជាកែវមនោហរ, ហើយដោយគុណភាព

---

១- ដកស្រង់ពីសៀវភៅប្រក្រតិទិនកម្ពុជា លេខ / ម ១៤៨១ តម្កល់នៅពុទ្ធសាសន-បណ្ឌិត្យ ។ បោះពុម្ពផ្សាយដោយក្រុមសមាគម សុជាតេ ពីឆ្នាំ១៩៤៦ រៀបរៀងដោយ លោក សក់ - វាត ។ ទំព័រ ៥៩ ។

www.budinst.gov.kh www.elibraryofcambodia.org

នៃកែវវត្ថុនោះ អ្នកម្ចាស់កែវសាបប្រាថ្នាធ្វើអ្វីឬចង់បានអ្វី នេះកែបាន សម្រេចទាំងអស់ " ។

កញ្ញាស្ទូវក៏យកកែវមួយទៅត្រងទឹកសន្សើមដែលទើរ នៅលើស្លឹក ឈើ និងស្មៅផ្សេង ១ ។ ក៏បានខំព្យាយាមធ្វើដូច្នេះជាច្រើនព្រឹក ប៉ុន្តែ ឥតបានលទ្ធផលល្អសោះ ។

ចំណែកឯនាងមេខលា ដែលជាស្រីចេះគិតវែងឆ្ងាយ ក៏រើសយក បណ្តូលឈើមួយ យ៉ាងទន់ស្អាត ១ ហើយយកទៅដាក់ផ្តិតលើទឹក សន្សើមដែលដក់នៅលើស្លឹកឈើ និងនៅលើស្មៅ ទាល់តែជុំឈើនោះ ជក់ទឹកនៅពេញទាំងអស់ ។ បន្ទាប់មក, នាងសារក្ខទេវី បានយកជុំ ឈើនោះទៅប្របាច់ទឹកដាក់ទៅក្នុងកែវ ។ អាស្រ័យដោយហេតុដូច្នេះ, នាងក៏រកទឹកសន្សើមដាក់កែវបានពេញ ហើយក៏យកកែវនោះទៅជូន មហាតាបស ។ ហេតុដូច្នេះបានជានាងសារក្ខៈទេវីត្រូវបានតាបសសំគាល់ ថា ប៉ិនប្រសប់ជាងបិសាច ។

តាបសជប់ទឹកសន្សើមនោះឲ្យកើតទៅជាកែវ ហើយប្រគល់ទៅឲ្យ នាងមេខលា ដោយប្រាប់ថា " កែវនេះ មានគុណភាពខ្លាំងពូកែណាស់, បើអ្នកមានបំណងអ្វីមួយ គ្រាន់តែលើកកែវនេះគ្រវីឡើង នោះមួយរំពេច សេចក្តីប្រាថ្នារបស់អ្នកនឹងបានសម្រេចភ្លាម, មួយទៀត ដោយគុណភាព នៃកែវនេះ អ្នកអាចហោះ កាត់អាកាសកប់ពពកជ្រែកតាមចិត្តខ្លួន ទៅ កាន់កន្លែងណាក៏បានទាំងអស់ "

www.budinst.gov.kh www.elibraryofcambodia.org

នាងកាកូទេវីក៏ទទួលយកកែវនោះមក លើកគ្រវីឡើងលើ ស្រាប់តែហោះវិនទៅលើមេឃតម្រង់ទៅមហាសាគរ ។

ចំណែកឯរាមាសូរ, អាស្រ័យដោយការព្យាយាមដ៏យូរ ក៏កេចក សន្សើមដាក់បានពេញកែវ; ហើយយកទៅថ្វាយមហាឫសី ។ ពោលថា “ទៅឯង យករបស់នេះ មកយឺតយូរពេកហួសពេលគ្រូត្រូវការ ឥឡូវគ្រូបានឱ្យគេនូវក្តោះទៅនាងមេខលាទៅហើយ មន្តអាគមគាថារបស់គ្រូអាចជប់កែវបែបនេះកើតបានតែមួយដងគត់” ។

កាលបើបានឮមហាតាបសថាដូច្នេះ រាមាសូរ ក៏កើតសេចក្តីទោមនស្សក្រៃប្រមាណ ហើយក៏ស្រែកយំគណ្តឹតគណ្តក់យ៉ាងខ្លាំង ។

ដើម្បីលួងចិត្តបិសាចតាបសក៏ប្រាប់ថា “ចូរទៅកុំកើតទុក្ខខ្លាំងពេក ចាំគ្រូឱ្យពូថៅមួយ, ពូថៅនេះអ្នកអាចយកទៅឈ្លោះដណ្តើមយកកែវពីនាងកាកូទេវីមេខលាបាន; នាងមេខលានេះ ចូលចិត្តហោះហើរលេងនៅលើអាកាសដើម្បីផុតទឹកភ្លៀង នៅពេលដែលមានភ្លៀងខ្លាំងៗ ចូរអ្នកចោលពូថៅនេះទៅលើវា វានឹងប៉ះពាល់កែវដ៏មានតម្លៃនោះ, ប៉ុន្តែបើនៅពេលប្រយុទ្ធគ្នានោះ បើឯងឃើញនាងលើកកែវឡើងគ្រវី ចូរទៅឯងបិទភ្នែកភ្ជាមមុននឹងចោលពូថៅទៅលើវា” ។

កាលបើរាមាសូរបានពូថៅមកកាន់ទៅនឹងដៃហើយ វាក៏ហោះស្វែងរកនាងមេខលា ដើម្បីដណ្តើមយកកែវមនោហរ ប៉ុន្តែកាលបើបាន

www.budinst.gov.kh www.elibraryofcambodia.org

ឃើញនាងកាលណា នាងក៏យល់ឃើញក្លាមថា បិសាចនេះប្រាកដជា មានបំណងធ្វើអាក្រក់មកលើនាងពុំខាន ទើបនាងលើកដៃគ្រវីឡើង ហោះទៅលើអាកាសវេហាស៍ខ្ពស់ក្រៃលែងខ្ពស់ ។

កាលបើក្រឡេកឃើញពន្លឺចាំងនៃកែវមានសិល្បក្លាម បិសាចក៏ បិទភ្នែកកំផិត រួចគ្រវែងអាវុធកទៅ ។

អាវុធនោះ ក៏ហោះយ៉ាងលឿន ឮសូរសម្បើមក្រៃលែង ប៉ុន្តែឥត ត្រូវនាងអាក្រូទេវីទេ ។

ចាប់តាំងពីពេលនោះមក, ទើបនៅពេលមានភ្លៀងផ្គរគេឃើញ ចាំងពន្លឺកែវ ហើយឮសូរសម្លេងយ៉ាងខ្លាំងនៃអាវុធនោះ ។

អាស្រ័យហេតុនេះហើយ បានជាក្នុងភាសាខ្មែរយើងឲ្យឈ្មោះដុំ ចាំងឡូយណា ដែលឃើញគេនាំកន្ទួលដែកចូលចៅ ឬ បណ្ដាក់ក្បាលស្រួច ឬដូចកាំបិតថា “កាំរន្ទះ” ហើយសន្មតរបស់ចាំងនោះថា ជាព្រួញ របស់យក្សព្រាញ ទៅលើមេឃធ្លាក់មកដី ។

www.budinst.gov.kh www.elibraryofcambodia.org

## ៩- រឿង ប្រពៃណីនៃសត្វសុនខ(១)

លោកអ្នកធ្លាប់ឃើញ ? សត្វសុនខវាកាន់ប្រពៃណី ២ ប្រការ គឺ

១– នៃកាលណាវាជួបគ្នានៅទីណា ១ ក៏ដោយ មិនថាញីមិនថាឈ្មោលទេ វាតែងតែហិតគូទគ្នាទៅវិញទៅមក ។ កិច្ចនេះសាទៀតកាត់ វានៅតែមិនបាន ។

២– សត្វសុនខឈ្មោល កាលណាវាបន្ទោបង់បស្សាវៈ តែងតែលើកជើងម្ខាងជាដរាប ។ កិច្ចនេះក៏វាលះបង់មិនបានដូចគ្នា ។

លោកអ្នកយល់ទេ កិច្ចវត្តទាំង ២ ប្រការ ដែលសុនខតែងប្រព្រឹត្តមកមិនដែលខាននោះ កើតបណ្តាលមកពីអ្វី ? មានតាំងពីគ្រាណាមក ?

កិច្ចវត្តដែលសុនខតែងប្រព្រឹត្ត ២ ប្រការនោះគឺៈ

កិច្ចវត្តប្រការទី ១ គឺកាលពីបឋមកប្ប ដែលទើបកើតមានមនុស្ស មានបក្ស មានសាសនា (ពាក្យប្រដៅ) បន្តិចបន្តួចលើផ្ទៃផែនដីនោះ ។ មានរឿងតំណាលថា ក្នុងសម័យព្រេងនាយ មានវត្តអារាម មានអ្នកបួស

---

១– ស្រង់ពីកម្ពុជសុរិយា លេខ ៣ ឆ្នាំ ១៩៤៧ រៀបរៀងដោយអ្នកឧកញ៉ាពិស្សុរវង្ស សំ . ស៊ុង ចៅក្រមប្រឹក្សាសាលាឧទ្ធរណ៍ ។

www.budinst.gov.kh www.elibraryofcambodia.org

កាន់សីលធម៌ សុចរិតកាន់ពាក្យសច្ចៈ ប្រជុំគ្នាដោយពួកៗ នៅក្នុងវត្តនិមួយៗ ។ មានសុនខជាច្រើនជ្រកកោននៅក្នុងវត្តចាំបរិភោគអាហារដែលសេសសល់អំពីអ្នកបួស តែកាលណាលោកប្រជុំគ្នាឆាន់ចង្ហាន់នៅលើសាលា ពួកសុនខក៏ចាំគ្នាឡើងទៅក្រាបគាល់លោកចាំបរិភោគអាហារសំណល់ តែរៀងរាល់ថ្ងៃ-ខែ-ឆ្នាំពុំដែលដាច់ខាន ។ ឯភូមិផ្ទះអ្នកស្រុកឥតមានសុនខណាស្រើយនៅជួបសព្វថ្ងៃនេះទេ ។

ថ្ងៃមួយនោះ បណ្ដាពួកសុនខទាំងនោះ មានសុនខមួយចេញខ្យល់គាប៍ (ផោម) ធុំក្លិនអាក្រក់ដល់លោកមេវត្ត ដែលលោកកំពុងឆាន់ ។ លោកក៏សួរទៅពួកសុនខដែលនៅជួបផ្ទះនោះ ឲ្យឆ្លើយតាមពិតត្រង់ តែគ្មានសុនខណាមួយទទួលខុសថាផោមសោះ ។ ឯលោកគ្រូមេវត្តលោកជ្រាបច្បាស់ថា មានសុនខមួយក្នុងចំណោមនោះ ចេញផោមជាប្រាកដ ទើបលោកពោលថា "អើបើឯងនៅតែលាក់បិទបាំង មិនសំដែងទោសកំហុសរបស់ខ្លួនដូច្នេះ ចូរឯងទាំងឡាយវិនាសចាកវត្តក្នុងកាលឥឡូវនេះចុះ" ។ ដោយពាក្យសច្ចៈរបស់លោកគ្រូ ពួកសុនខក៏អន្តរធានចាកវត្តក្នុងពេលមួយរំពេច ពុំអាចទប់ទល់បានឡើយ ។

តាំងពីពេលនោះមក សុនខទាំងឡាយក៏ក្លាយទៅជាសត្វអនាថា ចេញទៅលាក់ខ្លួនពួនអាត្មាដោយព្រៃខ្លះ ដោយផ្ទះសម្បែងគេខ្លះ អត់ឃ្លានពន់ពេក កើតក្ដីសង្វេគអាណិតតែរៀងខ្លួន ។ តាំងពីថ្ងៃនោះមក

www.budinst.gov.kh www.elibraryofcambodia.org

ពួកសុនខទាំងនោះ ក៏តាំងចិត្តស្វែងរកសត្វតាងឲ្យប្រាកដថា សុនខណា វាដោម ហើយលាក់បំបាំងទុក បណ្ដាលឲ្យពួកសុនខដែលមានសុចរិតស្លូត ត្រង់ទទួលសេចក្ដីលំបាកវេទនា ។ ហេតុនេះបានជាពួកសុនខ ប្រកាន់ ខ្ជាប់ក្នុងកិច្ចវត្តនោះ តាំងពីកាលនោះរៀងៗមក តែបានជួបគ្នាវេលាណា ក៏តាំងផ្ដើមកិច្ចវត្តមួយមុនកិច្ចឯទៀតៗ គឺចូលទៅហិតគូទគ្នាទៅវិញទៅ មក ហើយបានធុំក្លិនអសោចិដូចគ្នា សុនខមួយក៏ញញេញញញ្រែញធ្មេញបញ្ចេញ សំឡេងឡើងថា រ៉ឺងៗ សុនខម្ខាងទៀត ក៏តបមកវិញថា រ៉ឺងៗ ដូចគ្នា ទើបបង្កើតទោសឡើងព្រមៗគ្នា ក៏ប្រើកម្លាំងកាយប្រយុទ្ធគ្នា ទៅវិញទៅមក ពេញទំហឹងឡើង ។

កិច្ចវត្តប្រការទី ២ គឺសុនខឈ្មោលមានប្រកាន់កិច្ចវត្តមួយបែប ទៀត គឺពេលបន្ទោបង់បស្សាវៈ តែងតែលើកជើងម្ខាងជាដរាប ។ រឿង ទី ២ នេះ ក៏កើតឡើងក្នុងសម័យជាមួយគ្នានឹងរឿងទី ១ ដែរ ។

គឺ ដូចមានសេចក្ដីដំណាលតៗគ្នាមកថា សម័យនោះ មានបុរស ស្ត្រីពីរប្រពន្ធមួយគ្រួ មានទីលំនៅមិនឆ្ងាយអំពីទីភាគយណាស់ណាទេ លុះដល់ខ្លួនកាន់តែចាស់ៗទៅ មានសេចក្ដីសង្វេគ ទើបនាំគ្នាស្វាមីភរិយា គិតពិចារណាថា "យើងចាស់ៗណាស់ហើយ ចូលក្នុងសេចក្ដីមិនទៀង តែយើងទាំងពីរនាក់ ជាអ្នកទុគ៌តក្រខ្សត់គ្មានអ្វីនឹងធ្វើបុណ្យឲ្យបានផលម្ដង សោះ យល់ថានឹងស្លាប់ទៅទទេ ឥតផលប្រយោជន៍អ្វី ឃើញថានឹង

www.budinst.gov.kh www.elibraryofcambodia.org

បង់ជាតិកំណើត ដែលបានកើតមកជាមនុស្សនេះមិនខាន" ។ ហើយ យាយតាសុំធ្វើយទៀតថា "ថ្វីត្បិតតែក្រ បើប្រឹងប្រែងរកទៅក៏គង់ធ្វើបានខ្លះមិនលែង គ្រាន់តែផុតទុគ្គតបណ្ណាការទៅចុះ" ។ តាតបថា ៖ អើអាយ! យាយឯងថាធ្វើបាន តើបានធ្វើអ្វី? ។ យាយថា "ចៅកាត់តាមខ្ញុំ ហើយធ្វើបាន" ។ ហើយយាយតំណាលថា "សព្វថ្ងៃនេះ មានស្រែគេនៅជុំវិញភូមិយើង គេទើបនឹងច្រូតដឹកនាំយកទៅ សល់គួរនឹងជ្រុះគ្រាប់ស្រូវខ្លះ បើយើងនាំគ្នាទៅរើសមួយថ្ងៃ គង់ដណ្ដាំបាយបានជាបន្ទុកខ្លួនដែរ" ។ តាថា "បើយាយថានេះហៅពេញជាត្រូវ ណ្ហើយយាយប្រញាប់ទៅ ក្រែងគេបានទៅក្រោយបន្តិច" ។ ថាហើយ យាយនិងតាក៏កាន់ល្អីម្នាក់មួយ ចេញទៅរើសស្រូវនៅក្នុងស្រែ ដែលគេទើបច្រូតកាត់ហើយ ៗ រើសមួយថ្ងៃរហូតល្ងាចបានស្រូវប្រមាណមួយត្រឡោកម្នាក់ យាយតាក៏នាំគ្នាវិលមកផ្ទះវិញ ។ លុះបរិភោគអាហាររួចហើយ ក៏បបួលគ្នាបុកគ្រាប់ស្រូវ ទាំងយាយទាំងតា គាត់យកកាំបិតស្លាកោសគ្រាប់អង្ករដែលយាយតាបុករួចហើយនោះ ឲ្យជ្រុះគន្លាក់ចេញ ហ្មោះហើយគ្រាប់អង្ករនោះ មានសម្បុរសក្ដិថ្លាដូចពងសត្វ ឥតក្ដីយាយយកអង្ករនោះទៅលាងទឹក ហើយប្រកក្នុងឆ្នាំងដណ្ដាំបាយតាមធម្មតា ។

និយាយពីលោកគ្រូ លោកមានញាណយល់ការណ៍ដាច់ច្បាស់ ដោយអំណាចលោកកាន់ធម៌សច្ចៈ លោកបានជ្រាបហេតុពីយាយនិងតា

www.budinst.gov.kh www.elibraryofcambodia.org

ប្រាថ្នាធ្វើមហាទាន ក៏លោកហៅភិក្ខុសាមណេរមកប្រជុំប្រាប់ថា "យប់នេះត្រូវនាំគ្នាបោសសំអាតវត្តដោតទង់ចងស៊ុមឲ្យរុងរឿង ព្រោះព្រឹកនេះមានមហាទានចូលមកវត្តរបស់យើង ដូច្នេះត្រូវយើងធ្វើឲ្យគួរសមនឹងទទួលមហាទាន" ។

គ្រានោះ ភិក្ខុសាមណេរទាំងឡាយ ក៏ខ្វល់ខ្វាយបោសព្រាសសំអាតវត្ត ចងស៊ុម ដូចជាការធ្វើទទួលមហាកឋិនមួយ ៗ លុះព្រឹកឡើងអរុណរះ ស្រាប់តែឃើញយាយនិងតាបណ្ដើរគ្នា ចូលទៅកុដិវត្ត ។ ឯយាយតាកាន់កណ្ដៀវល្អមួយ មានបាយមួយចានដាក់ក្នុងល្អី ដើរចូលសំដៅទៅកុដិលោកគ្រូធំ ៗ វាយរគាំងម៉ឺនៗ ប្រជុំភិក្ខុសាមណេរធ្វើភត្តានុមោទនា ។ នៅវេលាគ្រានោះ មានភិក្ខុមួយរូបក្ដៅចិត្តណាស់ ស្ទុះចេញទៅឈរចាំមើលផ្លូវ ។ លុះយាយនិងតាបណ្ដើរគ្នាចេញទៅដល់ព្រំវត្ត ភិក្ខុនោះក៏និយាយថា "នែយាយនិងតា ក្រោយ ៗ មកបង្អាន់របស់យាយនិងតាទៅវត្តឯណាទៀតទៅ កុំនាំចូលមកវត្តនេះទៀត សព្វបើបាយមួយចាន ឲ្យគេលំបាកអស់មួយយប់" ថាហើយភិក្ខុនោះគេចចេញទៅ ។

រីឯយាយនិងតា លុះបានឮសំដីភិក្ខុនោះ និយាយដូច្នោះហើយ ក៏មានសេចក្ដីតក់ក្ដិតចិត្តពន់ពេក នាំគ្នាសង្វេគក្នុងចិត្តថា "ឱកម្មអើយកម្ម! ហេតុតែយើងក្រីក្រធ្វើទានមិនដល់ថាជានាំឲ្យលោកមិនសប្បាយចិត្ត" ។ តាថា "ចុះយាយគិតយ៉ាងដូចម្ដេចទៀត?" ។ យាយថា

www.budinst.gov.kh www.elibraryofcambodia.org

"តាកុំព្រួយមិនអីទេ សព្វថ្ងៃខ្ញុំឃើញសុនខខ្លាត់ខ្លាត មកនៅក្បែរផ្ទះយើង ច្រើនណាស់ (ជាន់នោះប្រហែលជាគេសំគាល់ថា សម្លាប់សត្វយកទៅ ធ្វើបុណ្យ មិនបាប ត្រឡប់ជាបានបុណ្យច្រើនទៅវិញទេដឹង?) ។ តាថា "ឲមែនហើយយាយ! មកយាយយកបន្ទាស់ធ្នូរមួយមក" ។ ថាហើយ តាឆក់ដាវចេញពីក្រោមបណ្ដើរយាយៈចេញផុតពីផ្ទះទៅ ក៏ក្រោបតែ ប្រទះសុនខ ៤-៥ នៅហែងក្បែរព្រៃ ។ តាថា "យាយស្ទាក់ពីមុខ" ។ យាយស្ទុះដេញវាយត្រូវសុនខមួយដួល តាស្ទុះទៅត្រកងទីងដាវដាច់ក មួយទៅ ។ ស្ទាក់ចុះស្ទាក់ឡើង សម្លាប់សុនខបាន ៤-៥ ។ យាយថា "ល្មមះហើយតា! ល្មមធ្វើបង្ហាន់លោកបានមួយវត្តហើយ" ហើយយក ខ្សែចងសែងឆ្កែនយកទៅផ្ទះ យាយគាត់ចាក់កាប៉ោនច្រើនមុខ គាត់ធ្វើ ជាសាច់ប្រទូបជោតជាបន្ទាក់ៗ ឲ្យតាអាំង គាត់ហាន់ជាដុំៗ ដាក់ថ្នាំង មួយ ហើយគាត់ហាន់តូចៗ ធ្វើជាសម្លម្ជូរគ្រឿង ។ គ្នាក់ត្រីមោះ លោកគ្រូធំឈ្មោះយល់ទៀត ក៏ប្រជុំភិក្ខុសាមណេរមកប្រាប់ថា "ព្រឹក ស្អែក មានទានមកដល់វត្តយើងទៀតហើយ ប៉ុន្តែទាននោះថាធំក៏បាន ថាតូចក៏បាន មិនចាំបាច់រៀបវត្តទទួលទេ" ។ លុះព្រឹកឡើងក៏ឮប្រកាស ឃើញយាយទូលថ្នាំងមួយ តារែកតម្រែកមួយ ចូលទៅកុដិវត្ត ។ លោក គ្រូក៏វាយគាំងមុងៗ បីបទ ប្រជុំព្រះភិក្ខុសាមណេរធ្វើគត្តាទុំមោទនា រួច ហើយលោកគ្រូហាមថា "ភិក្ខុក្ដី សាមណេរក្ដី បើបានទទួលបង្ហាន់មាន

www.budinst.gov.kh www.elibraryofcambodia.org

ដុំសាច់ កុំគាលឆាន់ ត្រូវនាំយកសម្លដែលមានដុំសាច់នោះមកប្រគល់ឲ្យ ឆាន់ករុណាកុំខាន” ។ លុះធ្វើភត្តានុមោទនារួចហើយ យាយខិនតាក៏ដួស សម្លចែកលោកគ្រប់កុដិ ។ ឯភិក្ខុសាមណេរ កាលបានទទួលម្ហូបស្រេច ហើយពិចារណាមើលពុំឃើញមានត្រី មានសុទ្ធតែដុំសាច់ ក៏នាំគ្នាយកម្ហូប នោះទៅប្រគេនលោកគ្រូធំអស់ទៅ នៅសល់តែភិក្ខុមួយរូប ពុំបានយក សម្លទៅប្រគេនលោកគ្រូធំ សម្ងំទុកឆាន់តែម្នាក់ឯង ។ ឯលោកគ្រូធំស្មាន ថា អស់លោកយកមកជុំគ្នាហើយ ក៏សូត្រគាថាផ្សំធាតុ កើតឡើងជាសត្វ សុនខ ។ ឯសុនខដែលកើតដោយអំណាចគាថានោះ កើតជារូបសុនខ សុទ្ធសាធ តែមានជើងតែបី ។ ទើបលោកគ្រូធំចាត់លោកគ្រូសូត្រឲ្យដើរ មើលគ្រប់កុដិ ទៅឃើញគន្ធកុដិភិក្ខុមួយរូបនោះ មានសាច់ប្រឡូប មានទទ មានសម្លម្ជូរគ្រឿងសុទ្ធតែសាច់ ក៏បង្គាប់ឲ្យភិក្ខុនោះនាំយកទៅប្រគេន លោកគ្រូធំ ។ លុះលោកគ្រូធំបានទទួលម្ហូបថ្មីទៀត ក៏លោកសេកគាថា ផ្សំម្ដងទៀត ទើបកើតជាសុនខមានជើងគ្រប់ទាំង ៤ ដូចដើមឡើងវិញ ។

តាំងពីដើមនោះ សុនខកើតមានសេចក្ដីកតញ្ញូដល់លោកគ្រូជាប់ ជានិច្ចក្នុងចិត្ត តែកាលណាបន្ទោបង់ស្ប្រាវៈក៏នឹករឭកដល់គុណរបស់ លោកគ្រូ ថាកុំតែបានលោកគ្រូកុំអីយើងខ្វះជើងមួយ គិតហើយក៏លើក ជើងក្រោយម្ខាងឡើងនឹករំឭកគុណ នៅពេលបន្ទោបង់ស្ប្រាវៈ គឺ លើកជើងដែលលោកគ្រូបង្កើតឲ្យលើកក្រោយបង្អស់នោះឯង ។

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# ១០- រឿង សត្វឥន្ទ្រីរបស់ព្រះឥសូរ(១)

មានសត្វឥន្ទ្រី ១ ជាទីគាប់ព្រះទ័យនៃព្រះឥសូរ បើសត្វឥន្ទ្រីនោះ វាចង់បានអ្វី ១ ក្ដី ឬវាចង់ស៊ីសាច់សត្វណាក្ដី វាទូលព្រះឥសូរថា វាយល់សុបិនត្រូវស៊ីសាច់សត្វនោះ ព្រះឥសូរក៏បេះតែជឿតាម ហៅសត្វនោះមកឲ្យវាស៊ីតែរឿយ ៗ ។ សត្វទាំងឡាយ មានគោក្របីជាដើម កើតក្ដៅក្រហាយនឹងសត្វឥន្ទ្រីនោះមហិមា តែពុំហ៊ានថាអ្វី ព្រោះខ្លាចអំណាចព្រះឥសូរជាម្ចាស់លើសត្វលោកនេះ ។

ថ្ងៃ ១ សត្វឥន្ទ្រីនោះ វាចង់ស៊ីសាច់ស្ដេចដំរីស ទើបវាទូលព្រះឥសូរថា វាយល់សុបិនត្រូវស៊ីសាច់ស្ដេចដំរីស ។ ព្រះឥសូរក៏ជឿតាម ទើបឲ្យបំរើទៅប្រាប់ដំរីសម្ដាយនឹងកូនថា ឲ្យទៅលាងខ្លួនឲ្យស្អាត ហើយឲ្យចូលមកក្នុងវេលាព្រឹកនេះ ឲ្យសត្វឥន្ទ្រីវាស៊ី ត្បិតវាយល់សុបិនត្រូវគ្រង់រូបខ្លួនហើយ ។ ឯដំរីសម្ដាយនឹងកូនកាលណាបើឮថា ព្រះឥសូរឲ្យហៅខ្លួនទៅឲ្យសត្វឥន្ទ្រីស៊ីដូច្នោះ ក៏កើតភ័យខ្លាំងសេចក្ដីស្លាប់នោះមហិមា

---

១- គតិលោកភាគ ២ ខាងញាសុត្តន្តប្រើជាតក្ក រៀបរៀង ។

www.budinst.gov.kh www.elibraryofcambodia.org

ទៅ យល់សុបិនល្អណាស់ ជាសុបិនមង្គលហៅសុភនិមិត្ត" ។ ព្រះឥស្សូរក៏សួរថា "បាឯងយល់សុបិននោះដូចម្ដេច ចូរនិយាយទៅមើល!" ។ ទីទុយក៏ទូលថា "សុបិនទូលព្រះបង្គំជាខ្ញុំនេះមានសេចក្ដីប្លែកណាស់ស្ទើរតែមិនហ៊ាននិយាយ" ។ "មើលឯងនិយាយទៅមើល សុបិនឯងនោះយ៉ាងណា?" ។ សូមទានសុបិននោះឃើញថា "សម្ដេចព្រះនាងទុមាគគវតី ជាព្រះរាជមហេសីល្អងធុលីព្រះបាទនេះ ស្រឡាញ់ខ្លួនខ្ញុំព្រះករុណាវិសេស ល្អងធូលីព្រះបាទក៏ប្រោសប្រទានឲ្យមកជាភរិយាខ្ញុំ សុបិនខ្ញុំនេះទៀងពិតប្រាកដណាស់ យកជាប្រមាណបាន បើដូច្នេះសូមល្អងធូលីព្រះបាទហៅព្រះនាងទុមាគគវតីនោះព្រះរាជទានឲ្យទូលព្រះបង្គំជាខ្ញុំ ទុកជាព្រះកេរ្តិ៍របស់ព្រះករុណាវិសេស" ។ ព្រះឥស្សូរឮដូច្នោះ ក៏គួបព្រះរាជហឫទ័យ ទើបត្រាស់ថា "អាឯងយល់សុបិននេះតែផ្ដាសទេ យើងនឹងយកជាប្រមាណពុំបាន នឹងជឿស្ដាប់ពុំបានទេ អាទីទុយអើយ!" ។ ទីទុយតបថា "ការយល់សុបិនទាំងទូលព្រះបង្គំជាខ្ញុំ ព្រះអង្គថាយកជាប្រមាណពុំបាន នឹងជឿស្ដាប់ពុំបាន ចុះទាំងសត្វឥន្ទ្រីនោះម្ដេចក៏ព្រះអង្គជឿស្ដាប់យកជាប្រមាណបាន! តើបើសុបិនទូលព្រះបង្គំជាខ្ញុំមិនពិត សុបិនសត្វឥន្ទ្រីនោះក៏មិនពិតដូចគ្នា ព្រោះជាវិស័យសកុណជាតិដូចគ្នា សូមព្រះអង្គកាត់សេចក្ដីនេះឲ្យបានប្រកបដោយយុត្តិធម៌ទាំងសងខាងឲ្យទាន" ។ ព្រះឥស្សូរឮទីទុយស្ដីដូច្នោះហើយ ក៏ទញ់

www.budinst.gov.kh www.elibraryofcambodia.org

ពាល់ព្រះហឫទ័យណាស់ ទើបត្រាស់ថា អើបើដូច្នោះប្អូនឯងនាំយកដំរីស ជាមាតាឯង វិលទៅកាន់ទីលំនៅឯងវិញចុះ ការនេះយើងលើកលែងឱ្យតែប៉ុណ្ណោះ" ។

ទីទុយក្រាបថ្វាយបង្គំលានាំដំរីស ម្តាយនិងកូនទៅកាន់លំនៅវិញ ។ ដំរីសទាំងម្តាយទាំងកូនក៏បានរួចជីវិត នៅជាសុខសប្បាយតទៅ ព្រោះបានជួបនឹងទីទុយជាកល្យាណមិត្រជាអ្នកប្រាជ្ញ អាចជួយដោះទុក្ខបានដោយប្រពៃ ។

www.budinst.gov.kh www.elibraryofcambodia.org

# ១១– រឿងចចក(១)

## បទកាកគតិ

នេះបទកាកៈ គតិបវរា ចែងចងរឿងកាយ តាមពាក្យពីព្រេង គេតែងនិយាយ ដំណើរអតីតព្រាយ ពីសត្វចចក ។ យោងយកកំណើត កំណត់កាលកើត ពីតូចជ្រៀតជ្រែក ក្នុងរូងថ្មភ្នំ ធាត់ធំស្រៀតសិក សត្វថ្ងៃចចក ស្វែងរកគោធា ។ ប្រមាថ្នេរស្ទួរស្ទឹង ត្រពាំងបួបឹង ព្រោះព្រោយបត្តា លុះយប់ផ្ដល់ផ្ទង់ ចុះតាប់ផ្លូវ តែងបរិភោគា សត្វថ្ងៃប្រក្រតី ៖ រូបតាបក្រញិញ ចុះចប្អូនតឿទេញ កាចខ្ចូបអប្រិយ តែងដើរហោកលះ ស្វែងស្វះរកស៊ី ព្រួយខ្មៀយឥន្ទ្រិយ ស្គាំងស្គមគាត្រា ។ ពីកាលក្មេងនៅ មេស្ទាប់ហោលះទៅ នៅតែខនិជា នាំដើររកស៊ី ប្រែបទីផលសត លុះដំកាលណា ជាហ្វាប់បង់បាត់ ។ ចចកនោះទៅ ទលទុក្ខក្ដាត់ក្ដៅ ក្នុងថ្ងៃប្រមាត់ ឥតមេឥតបា កំព្រាព្រាតព្រាត់ ស្ងួចស្ងួតសៀមស្ងាត់ ត្រមោចម្នាក់ឯង ។ ចចកគន់គិត រំពឹងក្នុងចិត្ត រឹងរឹតចំថែង

---

១– ច្បាប់សាស្ត្រាស្លឹករឹតនៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀងដោយ សត្វម៉ុក ។ លោក ជាប-ពិន កែសម្រួលពាក្យដែលឃ្លៀងឃ្លាតខ្លះ ។ កម្ពុជសុរិយា ១១ ទំព័រ ១០៦៩ ។

www.budinst.gov.kh www.elibraryofcambodia.org

ដើររកគោជនា គោក្ដាកណ្ដាន កណ្ដោបឯកឯង ឥតមានគ្នីគ្នា ។ វេលា ចូលដេក ក្នុងទីដំណេក ត្រូវត្រៀងរងា ខ្យល់បក់ស្ងប់ស្ងួត ថ្ងើមស្ងួត គ្រាំគ្រា ក្រៀមក្រំកំព្រា កំព្រោនពេកពន់ ។ បបករិះគិត បានឃើញ គំនិត មួយនោះជាលន់ ថាគញ្ញត្រូវរក ត្រូវយកប្រពន្ធ ទើបបាន ទឹងស្រន់ ទឹងស្រាលទុក្ខា ។ គ្រាន់ជាគូរៅ ៈស្នេហាលែងនៅ ក្នុងរូង បក្សា បបកគិតហោះ ក្រោកស្មោះយាត្រា ត្រាច់ក្នុងព្រឹក្សា ស្រងួត ស្រងាត់ ។ ដើរត្រាច់តែឯង កណ្ដាបកណ្ដាន កំព្រាត្រាកព្រាត់ គ្រមោចគ្រមង់ នៅក្នុងព្រៃស្ងាត់ ប្រទះហ្វូងសត្វ គោតគោមហ៊ឹង្ក ។ ទខ្សោនទខ្សាយ ដំរីប្រើសព្រាយ ឈ្លូសក្ដាន់ស្វូកក រមាសរមាំង ខ្ទីង ខ្ទាំងខ្ទានខ្ទា ដើររកកោក្ដា សឹងសត្វយន់យ្នង ។ បបកឃើញសត្វ សាហាវផ្ដាត់ ប្រើនក្រៃកន្ទង កៀនកាល់គ្លូក ខ្សែវខ្វារអើងកង ភិតភ័យ កន្ទង ស្ទើរបាត់ស្មារតី ។ ទំដើររំលង បៀសសត្វយន់យ្នង បានដល់ នទី ស្ទឹងមួយថ្លាជ្រះ គ្របះយល់ដី បបកបាប់ត្រី បំអែតកាយា ។ ហើយហែលឆ្លាស់ឆ្លង ស្ទឹងនោះរំលង ដល់ត្រើយគង្គា ត្រាច់ក្នុងវប្បោះ ឃនោះគព្វា មានរូងគុហា ជិតជើងគិរី ។ បបកចូលជិត ប្រុងប្រាណ មូលមិត្ត មៀងមើលរកញី នុនបុះតើបតើត បំអើតះមើលទី ក្បែណនោះ មានញី បបកមួយណា ។ នៅក្នុងរូងថ្ម សិលាដ៏ល្អ ត្បាលសមកាយា បបកឈ្មោលគិត ក្នុងចិត្តថៃថា ត្រូវគញ្ញស្ងួរសា មន្តិចទើបបាន ។

www.budinst.gov.kh www.elibraryofcambodia.org

ទើបឈ្មោលហារេក ថាប្អូនពន្លក មិត្តមុំកល្យាណ នៅក្នុងរូងថ្ម ល្អះល្អ
ថ្កើងថ្កាន សត្វថៃតែមាន ប្តីជាគូគ្រង ។ ឬនៅឯកឯង ប្អូនអើយចូរថ្លែង
ប្រាយប្រាប់បងផង ឲ្យបងរសាយ ក្នុងកាយនេះហោង បើឥតគូគ្រង
បងសុំស្នេហា ។ បបកញីស្តាប់ ឆាកហើយថ្លែងប្រាប់ ថាអ្នកសោកា
ប្អូននៅសត្វថៃ អាស្រ័យគុហា មិនមាននរណា ជាគូឡើយនៃ ។
កាលដើមមានមេ ធាតបាបំពេ ទុចក្រុងសត្វថៃ ឥឡូវមេបា មរណា
ក្សិណក្សយ ប្អូននៅសត្វថៃ កំព្រាតេកតត់ ។ ឈ្មោលឮដូច្នោះ
ត្រីត្រួចតុងគោះ ហឫទ័យពោរពេញ ទើបឆ្លើយតបថា ប្អូនក្បាស្ងួនគន់
ប្អូនអើយបងគន់ បងគិតអម្ពា ។ ភាសួរប្អូនស្ងួន មាសមិត្រថ្លៃខ្លួន
កំព្រាឯកា ដូចកល់ខ្លួនបង សៅហ្មងចិត្តា សត្វថៃបងមហា ព្រួយ
ណាស់ប្អូនអើយ ។ បបកញីស្តាប់ ពាក្យឈ្មោលថ្លែងប្រាប់ ឆ្លើយថា
អ្នកអើយ ប្អូនស្តាប់ពាក្យអ្នក ជឿនជាក់ទៅហើយ ក្នុងចិត្តឥតស្បើយ
កើតទុក្ខទៀតថ្មី ។ ប្អូនចង់សួមសួរ ហៅមហាមិនគួរ ត្បិតខ្លួនជាស្រី
អ្នកថាព្រួយចិត្ត ព្រោះគិតរឿងអ្វី ប្រុសប្រាជ្ញប្រិមប្រិយ ប្រាយប្រាប់
ប្អូនកុំ ។ ឈ្មោលថាមាសមិត្រ បងព្រួយព្រោះគិត ដល់គូស្នេហា
គ្មានគ្នាជាតិរ បំរេណរអទា- គតបងហៅមហា ចច់ណាស់មាសបង ។
ញីថាប្រុសអើយ កុំថប់ក្សីឡើយ ប្អូនធាធារង វិះរកជួយគិត តាមចិត្ត
អ្នកបង គ្រន់តាមចំណង់ ចិត្តអ្នកប្រាថ្នា ។ ឈ្មោលថាមាសមិត្រ

បងចងផ្ញើចិត្ត ផ្ញើផ្តងដីកា នៅលើប្អូនសួន សូមទូនមេត្តា បងមិនប្រាថ្នា
ដទៃពីពៅ ។ ញីឆ្លើយថាអ្នក ចិត្តបងរួមរក្ស មួលមួយលំនៅ ផ្ញើផ្ទួន
ចិន្តា ស្នេហាគពៅ ឧងប្អូននេះគួរ ពេញមហាអរពេក ។ ប៉ុន្តែប្អូនយល់
ប្អូនគិតទៅដល់ ធ្លាយធ្លល់ចំរៀក ហានអ្នកឯនាយ សប្បាយអនេក
មានញីយ៉ាងឯក គួរគួរស្នេហា ។ ម្តេចអ្នកមិនខាន ចិត្តចាប់បងបាន
ជាគូដីកា ហើយប្រែណាគលះ ស្បែងស្ទះយាត្រា គងព្រៃអត្ថា មកដល់
ហានគាយ ។ ឈ្មោលស្តាប់ឆ្លើយគ្នាស់ ថាហៃប្អូនមាស មានរូបតោមុ
គាយ តោមៈតឹកៈទងនែង ហានបងឯនាយ មែនហើយសប្បាយ ដូចពាក្យ
ប្អូនថា ។ គឺមោះបងរក គូគាប់ឧនីយក ជាតិជាតខតា ឧងផ្ញើចិត្តទួន
ដូចសួនគេះណា គ្មានសោះបងមហា បត់ពេកតាងគាយ ។ ហេតុនោះ
បងស្ទះ បងស្បែងណាគលះ មកដល់ហានគាយ បងបងផ្ញើទួន លើនួន
តោមតាយ ព្រួយនឿយអត្តកាយ ម្តេច ៗ មិនគិត ។ កែនតែប្អូនស្រី
មាសមានមេត្រី មេត្តាមូលមិត្ត មូលមួយចិន្តា ស្នេហាជួបជិត ស្ងួបចាប់
ប្រព្រឹត្ត ជាគូកេសរា ។ ញីស្តាប់ឆ្លើយឆ្មៀត ឆ្លើយឆ្លងវិញទៀត
ថាប្រុសស្នេហា ពាក្យក្រៅល្អល្អះ គួរសះសង្ការ លួងលោមចិន្តា បាន
ហើយៈបោះបង់ ។ ឈ្មោលឆ្លើយថាហៃ ប្អូនមាសថ្មើមថ្ងៃ បណ្តូល
សាច់ស- ងួរសមសោភា កាយាវរវង្ស វរកាសអស់អង្គ អស់ឥត
សង្ស័យ ។ បងមហាស្រឡាញ់ ប្អូនមាសឈ្លុយគ្នាញ់ ចិត្តចាប់គាល័យ

www.budinst.gov.kh www.elibraryofcambodia.org

គាទ្រោះលើសលន់ ពេកពន់ក្រាស់ក្រៃ ពុំបានបងក្ស័យ ជីវិតជាម្តង ៗ ឈ្លោលថាតែម្ល៉េះ ចូលជិតបំពោះ ផ្អឹមផ្អាប់ហើយហោង ថើបថ្ពាល់ ឮខ្សឹក បំភឹតឆ្អឹងខ្នង ជាវៃហាមាសបង អាងគុំទេទឹង ៗ បំណាច់បងមក រកប្អូនពន្ទុក ធ្ងន់អួរធ្ងន់ស្ទឹង មិនស្តាយជីវិត ព្រោះបិត្តពឹង ទុកប្អូន ព្រលឹង ជាម្លូងស្នេហា ៗ ញ៉ាអៀនអន់អាក់ ទនមុខទុកភ័ក្ត្រ ចូលចិត្ត ចិន្តា សេពសុខកៀមកត្ត ក្នុងឋានគុហា ទើបឈ្លោលលោមថា ព្រលឹង បងណា៎ ៗ បងបង់នាំទៅ ទះទុំពេញក្តៅ ក្នុងចិត្តចិន្តា សញ្ញចង់តែមត់ សង្កត់ឲ្យល់ភឹ ឲ្យស្លាប់មរណា កុំឲ្យវេទនា ៗ ដល់គិតវែងទៅ ក្រែង កើតហ្មងសៅ កើតក្តៅខ្លួននា ជាទុបចក កំព្រកមោហា ក្សិណក្ស័យជន្មា ព្រោះញីបញ្ឆោត ៗ បើនឹងស្លាប់រស់ ឲ្យព្រួកក្តីយស គេមានកំណាត មានពាក្យសរសើរ ថាអើអញគោត បចកនេះសោត ពេញហៅហាន ក្លា ៗ គិតហើយបោលទៅ ជិតទីករណ្តៅ ថាយើនរណា បង្កើតជាក្តៅ ហ្មងសៅចិន្តា ងើយមើលមេឃថា យើក្តៅព្រោះថ្ងៃ ៗ អើអញជាតិនេះ លំបាកចាំនម្ល៉េះ ព្រោះតៀតបក្រៃ កើតជាចចក កំព្រកចង្រៃ ជាតិ ក្រោយអញខ្ពៃ អញសូមសព្វា ៗ តោះបីកបកើត យោនយកកំណើត ជាតិណាកតណា អញសូមសម្រេច សេចក្តីប្រាថ្នា កើតជាសុរិយា រុងរឿងរង្សី ៗ

កាលនោះមានយក្ស ប្រេតមួយសំណាក់ ចិតហានប្រក្រតី នៅលើ

ចត្តា ទៀបនារីថី យក្សត្រូសំដី ចចកប្រាជ្ញា ។ យក្សគិតថាៈអើ មហាលាភណាស់តើ ខ៏នបានភោជនា ត្រកាលចំណី ល្អក្រៃថ្មថ្មា ខ៏នបរិភោគ្គា នូវសាច់ចចក ។ គួរអញកាទ្យា ជាអន្តឥន្ទ្រា ប្រាថ់ភ ឲ្យយក សាច់ឈាមជាតាន ខ៏នបាននិរោគ កំណើតបានមក កើតជា សុរិយា ។ យក្សគិតដូច្នោះ កាទ្យាចំពោះ ជាអន្តឥន្ទ្រា ហិចហោះ ទ្រៀវត្រូ លើផ្ទៃវេហាស៍ ហើយមានវាចា សាកសួរមេត្រី ។ ថាហៃ ចចក អ្នកត្រាច់ដើរមក ពីណាគេអ្វី ចចកក្រឡេក ឈ្មៀងក្ហិតរំពៃ ស្មានអគ្គិកោសីយ ទើបទូលទៅថា ។ បពិត្រព្រះឥ- ន្ទ្រាទ្រង់សទ្ធិន្ទ្រ ឥស្សរសុជាតា ខ្ញុំមកស្មានស្មោះ ចំពោះប្រាជ្ញា រកបាប់មច្ចា នៅក្នុង ផលធី ។ បើបានមច្ចា ដូចចិន្តប្រាជ្ញា យកទៅឲ្យញី ក្បែតមានផ្ទៃពោះ ចិត្តស្មោះចង់ស៊ី ត្រីក្នុងផលធី ទើបឆ្ញុំញ៉ណាស់ណា ។ ហេតុនោះ ខ្ញុំមក រកកនិរោគ សមុទ្រមច្ចា ដើរដាច់ត្រួសក្ដៅ ហ្មង់សៅចិន្តា ពុរពង់ បាទា រន្ធត់អគ្គិប្រាណ ។ បែកញើសហូរហក់ ក្ដៅណាស់ប្រាកដ ពុំអាចអត់បាន ព្រោះថ្ងៃតាំងវែង សូរ្យរៃសង់ក្ដៅក្ដាន ទើបខ្ញុំប្រណិធាន អធិដ្ឋានថា ។ បើខ្ញុំនឹងកើត យកជាតិកំណើត ក្រោយខ្ញុំប្រាជ្ញា តាំង ចិត្តចង់បាន ដូចក្ដានចិន្តា កើតជាសុរិយា ប្រាកដដូចចង់ ។ បពិត្រ ឥន្ទ្រា សូមស្ដេចមេត្តា ជួយខ្លួនខ្ញុំផង ដើម្បីចនឹងបាន ដូចក្ដានចំណង ប្រេតយក្សត្រើយផ្ទង ជាធំយ៉ាណាស់ណា ។ បើទៅចង់បាន ដូចចិត្ត

www.budinst.gov.kh www.elibraryofcambodia.org

ចំណាន បំណាន់ព្រាហ្ម ចូរទៅផ្តិលផ្តាច់ សំរេចផ្នា យកសាច់ឲ្យជា
ទានយក្សបិសាច ។ ហេតុគាន់សង្ស័យ ជួយជូនទ្រទ្រង់ កើតមានអំណាច
ជាសែនសុរិយ៍ រស្មីចិញ្ចាច ចាំញាន់គ្រងរាជ ដូចចិត្តព្រាហ្ម ។ ចចក
ស្តាប់គិត ជឿជាក់ចូលចិត្ត ទើបទូលទៅថា ខ្ញុំចង់ឲ្យទាន សាច់ប្រាណ
ហើយណា ប្រេតយក្សឆ្លើយថា សាធុពីរដង ។ ប្រេតយក្សថាម៉្លោះ
និមិត្តបំពោះ ប៉ាំងបាត់ទៅហោង ចចករត់ចេញ ចោលខ្លាញ់ជាម្តង
គិតថាគញ្ញបង់ បានដូចសេចក្តី ។ ចចកគិតហ្នោះ ប៉ោលដល់ទឹកចុះ
លុយលេបបាត់ត្រី លុះបាត់ត្រីបាន ដូចក្អានសេចក្តី ព្រាហ្មពាំត្រី ឲ្យញី
រោគា ។ ញីឃើញឈ្មោលដល់ បានត្រីខ្វាយខ្វល់ ទទួលមច្ឆា បរិ-
ភោគផ្សាយផ្សេង ស្កប់ស្កល់ចិត្តា ទើបឈ្មោលប្រាប់ថា អែប្អូនពិសី ។
កាលខ្ញុំទៅយក មច្ឆានាំមក ឲ្យប្អូនប្រិមប្រិយ ហៅមហាព្រួយព្រាណ
ពុំគប្បីគណ់ស្រី ស្មើទានបានត្រី មកផ្ញើប្អូនភ្ញា ។ ប្អូនអើយថ្ងៃក្តៅ
ផើងបងឯកងនៅ រកាមកផ្គា ក្តៅដក់ក្នុងថ្លើម ផ្ដើមទទេ្ហ ដល់ជួល
ច្រើនគ្រា ស្ទើរវិលក្រោយខាន ។ បង់ទំហោលទៅ ប្អូនអើយរងក្តៅ
ខ្ទុតអត្តប្រាណ មង់ហោលហើយគិត គន្ធិម្តថាស្មាន ម្រៃហាលទាពាន
ចម្បាំងសីតមួយនោះ ។ គេជះសំណាង សំណួមសូមសាង ពីមុនមកនោះ
បានជួបផ្គ្រា យាត្រាចំពោះ ហើយស្តេចគន្ធគ្រោះ ស្មោះស្មានមេត្រី ។
ប្រសើរខ្នាន នាំផានិទាន ឲ្យឃើញសេចក្តី បុណ្យប្រាប់គួរខុស ហើយ

www.budinst.gov.kh www.elibraryofcambodia.org

ហោះចេញទ្វី បង់ចេញតាគតី រកបាប់មន្ត្រ ។ ចចកប្រាប់ញី សុសសព្វ សេចក្តី គ្មានខ្វះត្រង់ណា ហើយលោមបាបួន ខ្ញុំមខ្ញុំនស្នេហា អញបង់ បង់លា ទៅក្ស័យជីវិត ។ យកសាច់ជាទាន ប្រាជ្ញាឲ្យបាន ជាព្រះ ភាទិត្យ តើប្អូនទន់ថា ម្តេចម្តាមាសមិត្ត ញីស្តាប់ហើយគិត ធុញថៃ ថប់ថា ។ អ្នកមាសប្អូនអើយ ប្អូនថាៈម្តចឡើយ ចិត្តអ្នកប្រាជ្ញា មិន ហ៊ានទាំងឃាត់ ឲ្យក្អាត់សព្វា ក្រែងកើតទោសា ជាប់ដិតដល់ប្រាណ ។ គឺមោះប្អូនទៅ ក្រោយអ្នកប្រុសទៅ ពោះចង់ពោលហ៊ាន ប្អូនកើតទុក្ខព្រួយ ពីព្រួតពុំក្សាន្ត ទុក្ខមួយព្រោះមាន ទម្ងន់ពេញពោះ ។ ទុក្ខមួយព្រោះ ព្រាត់ ព្រោះប្រាសស្វាមីស្មាត់ សូន្យស្ងៀមក្រៀមក្រោះ ក្រៀមក្រំក្ទុន ចិត្ត ផ្តែតផ្តិតភាឡោះ- ភាល័យស្រណោះ អ្នកប្រុសប្រាសទៅ ។ សព្វថ្ងៃពីធ អ្នកមាសព្រលឹង ស្មានថាអ្នកនៅ នៃបងិត្យទុក ស្នេហា តទៅ ប្អូនឥតញាតិផៅ សង្ឃឹមតែអ្នក ។ ជាគូស្នេហា ទុកស្មើបិតា មាតាភ្ញូវក្ស រួមរសស្នេហ៍ស្នូធ ប្អូនបង់ទុកដាក់ ផ្ញើខ្លួនលើអ្នក លុះអស់ ជន្មា ។ ហេតុនោះប្អូនស្ទះ ប្អូនស្ទែងលាគលះ ពោលទីគុហា ជិតដោយ តាមអ្នក វរល័ក្ខណ៍សោភា ម្តេចឡើយឃាតឃ្មា ពីព្រួន្ទប្អូនទៅ ។ ញីថាតែម្ញោះ ទុខមុខទុកចុះ ទុកឈ្លួលក្តៅ ហាក់ដូចគគ្គី ឆេះពីពោះទៅ ទល់ទុក្ខហ៊ានសៅ ដោរផលខេត្រា ។ ស្ងៀមស្ងួតស្ងាត់ស្ងប់ ពុំចេញ សាសព្ទ សាសង់កថា រឹងក្តៅកន្ទេម ផន្ទឹមទុក ទេថាឈ្មោលលោមថា

សំឡាញ់បងអើយ ៗ កុំទាន់គាឡោះ គាល័យសោកសោះ សោយសោកឥតត្រើយ បើបងបានកើត កំណើតនោះហើយ បងមិនពោះតើយ ទីទៃពាលពៅ ៗ សឹមបងមកយក ប្អូនស្ងួនពន្លក បីបមថ្នមពៅ ដាក់លើពិមាន ទិព្វឋានផ្អូនផ្អៅ មូលមួយលំនៅ នៃបទិត្យស្នេហា ៗ ប្ដូរប្អូនស្រីស្រួល ស្រីស្រស់ទទួល អនុមោទនា ព្រមព្រះនឹងបង ដូចបីងប្រាថ្នា កុំទាន់រួញរា បើកបងតាមចិត្ត ៗ ញីស្ដាប់ឈ្មោលថា បាក់ដួងទុក សោកសៀយស្អិត បន្ទោទុក្ខស្រាល ស្រយាលក្នុងចិត្ត ទើបឆ្លើយប្រឹត ថាតាមចិន្ដា ៗ អ្នកនឹងផ្ដិលផ្ដាច់ ជីវិតយកសាច់ ជាទានប្រាថ្នា យោនយកកំណើត កើតជាសុរិយា ប្អូនសោកជ្រះថ្លា សាធុនឹងអ្នក ៗ

ដំណើរបបក នោះហោកំព្រក ឈប់ស្មោះជៀងជាក់ នេះនឹងតាប់នី-ទានពីព្រេតយក្ស បិតឋានសំណាក់ នៅលើបព្វតា ៗ យក្សនិម្មិតមក លបមើលបបក យក្សស្ដាប់ឮថា បបកផ្ដិលផ្ដាច់ សម្រេចជន្មា យក្សគេរ ហើយថា បរមលាភពេក ៗ ហើយយក្សនិម្មិត បញ្ចូលក្នុងចិត្ត បបកឲ្យត្រេក កាត់ចិត្តឲ្យទាន សាច់ខ្លួនសល់អែក ហើយប្រេតយក្សប្រែក សាធុការ ៗ បបកឈ្មោលញី លុះឮសំដី ប្រេតយក្សឲ្យសា- ធុការដូចនោះ ប្រមូលស្រះចិន្ដា លង់លុះសុរិយា អ័ព្ភសន្ធិគ ៗ នាំញីចូលដេក ក្នុងរូងដំណេក ដូចដើមកំណាត់ ទីនៃថ្ងៃឯព្រៃ ចាំក្រែប្រាកដ

ប្របឆ្នេរសមុទ្រ គាប់កាលនោះណា ។ មានយក្ខិណី ស្រែកប្រាសផត
ប្ដី នៅក្នុងព្រឹក្សា យក្សក្រោចរកប្ដី ឃ្លាតខ្មីយាត្រា បានដល់បព្វតា
ដែលយក្សប្រុសនៅ ។ យក្សស្រីឃើញម្ហូប ក្រផាក់ចូលឈប់ បន្តិច
បាត់ក្ដៅ យក្សស្រីថាគញ ឃ្លាតឃ្លាញ់ចេញក្រៅ ដើរហាលថ្ងៃក្ដៅ
សៅហ្មងកក្រ្ដា ។ យក្សស្រីគិតឆ្ងោះ ដើររកទឹកស្រោះ ចុះមើលមុខា
ឃើញហើយផ្អៀងផ្អង ឈ្មៀងឈ្មងនេត្រា យក្សសើចហើយថា នៅ
ល្អដែរទេ ។ អញខ្ពុកទឹកលាប លាងក្អែលផ្អេះផ្អាប ឲ្យត្រាច់ជាងគេ
ថាស្រេចយក្សស្រី ឃ្លាតខ្មីឆាគរេ រកស្រោះឆ្ងួតថៃ ផុះសព្វកាយា ។
ហើយយក្សឡើងយក សំពត់បានមក ស្លៀកហើយយាត្រា ដើរទៅ
ហើយគិត ក្នុងចិត្តយក្សថា បន់ព្រៀងសិនពី ឲ្យបានស្បើយទុក្ខ ។
យក្សស្រីគិតឆ្ងោះ ចាប់ក្បិចបង់ចុះ រេក្បាលងើមមុខ គន់មើលរូបកង
ដូចពានព្រហត់ ម៉ោះទំញុំគញ្ញក់ ញាំញីដើរលេង ។ រេករែកកំ
បាតទន្ទាំ ទន្ទើរទន្ទ្រង់ អង្គុយភ្ញាមចុះ ផើងគោះផាភ្លង់ ចះដៃច្រៀង
លេង តើងថោកសរសោ ។ ក្រឡេកស្ដាំឆ្វេង ស្ដាប់គេសំឡេង
ដូចហ៊ុនសោកា គាគ្រងតកត្រាត រអាក់ញ្ញាក់ញា ព្រួសល់យក្សា ប្រែក
ម៉ឹតលើកំ ។ យក្សថាសំឡេង នរណាច្រៀងលេង លោកញុំផ្ទារនិ ថា
ហើយយក្សស្រែក បះរុះផើងភ្ញុំ ធ្វើយយក្សមិនឆំ លបមល្មបមើលមៀង ។
មើលមិញស្កាស់ជាក់ ថាអះទុយក្ស ស្រីទៅស្រេតច្រៀង យក្សប្រុស

www.budinst.gov.kh www.elibraryofcambodia.org

ចង់ស្និទ្ធ បៀតជិតមញ្ញៀន ផ្ទឹមផ្ទាប់ផ្ទាល់ផ្ទៀន សាកសួរទៅថា ៗ នាងស្រីក្រមុំ រូបភង់ឧត្តម នាងមកពីណា យក្សស្រីថាខ្ញុំ ខិតខំយាត្រា ចេញពីព្រឹក្សា ដើររកចំណី ៗ យក្សប្រុសថាអើ លាភលន់លុះលើ ចំណង់សេចក្ដី ប្រាថ្នាអញចង់ បង់បង់មេត្រី នឹងនាងប្អូនស្រី ជាគូស្នេហា ៗ យក្សស្រីថាកុំ លេងសុិនតេកខំ ហៅម៉ែអញភាំ យើងមិនជាស្រី អប្រិយវេទណា យើងមានមេបា គួជពង្សគ្រាន់បើ ៗ យក្សប្រុសថាទេ អញចង់តែរក៍ ពុំទ្វារទេតើ ខរណាធ្វើអ្វី ប្អូនស្រីគ្រាន់បើ យក្សស្រីថាអើ គ្មានធ្វើអ្វីទេ ៗ ប៉ុន្តែមាក់ងាយ ហាមហានិយាយ ស្រដីចង់ទេ ទាលេងពាក្យព្រៀវ អញទៅប្រាប់ម៉ែ យក្សស្រីគិតកែការកើតបំពាន ៗ ប្រុសថាម៉ែអញ គ្រោះចង់ស្រឡាញ់ ទើបបងហ៊ានលេង បុរសស្ត្រី សេចក្ដីបេះឯង ពាសម៉ត្តមិនល្មើង សង្ឃារសោះថ្ង ៗ យក្សស្រីថាស្អប់ ពាក្យប្រុសប្រសប់ ស្រដីពោលលើ ថ្មោងថ្មីស្រឡាញ់ អស់អញឥតស្មើ បានហើយធ្វើបង្វើ តើយកោះបោះបង់ ៗ ឯយក្សប្រុសនោះ បានឮជួបោះ សោមនស្សរីសស់អង្គ អរឯកស្រួលស៊េប សំណើចចំណង់ ថាប្អូនវារីវង្ស កែកុំសង្ស័យ ៗ បិត្តបងស្រឡាញ់ពិត ៗ ពេកពេញ. ចិត្តជួបពិសម័យ បងធ្វើរូបខ្លួន លើខ្លួនថ្មើមថ្ងៃ លង់លុះក្សណក្ស័យ មរណ៍ម៉ួយមូលម៉ិត្ត ៗ ហើយយក្សប្រុសនោះ បរចូលជិតចុះ កៀកករួតរឹត ផែផល់ថយា ឃ្លូរយាទទំមជិត យក្សស្រីកាំង

www.budinst.gov.kh www.elibraryofcambodia.org

ភិត គៀនទេនភ័ក្ត្រា ។ ព្រឺព្រួញប្របប្រាណ រួមរសោស្មោះស្មាន ជិត ដើមបត្តា អស្ចារ្យគន់ ក្រាប់គ្រន់ត្រឹបផ្កា រសាយបុប្ផា កេសរកេរុះ ។ ត្បូរសៀង្សក ពិរុណរំលា ស្រក់ស្រោបចម្រុះ នាគរាជពេនពន់ ក្រួញ អន្តត្រដុះ ទេនក្បាលល្ហួនចុះ ចូលរូងមត្តា ។ ព្រួសពិសអន់អាច សំដែងអំណាច ឥតខ្លាចនរណា ក្បូរពិសពោរពាស ទិសពាស ក្រៀបក្រោ ពេញរូងបត្តា ហើយសម្ងំជ្រក ។.

ស្មេះរៀងយក្សខុក ថ្ងៃឥតទៅមុខ អំពីបបក ដេកក្នុងគុហា ដូច ពណ៌នាមក ភ្ញាក់ឡើងរិះរក គិតក្នុងចិត្តា ។ បើអញជាសញ្ញី ក្រោយ ប្រាប់អំពី ដំណើរអញណា ក្រែងញីឃាត់ប្រាណ រំខានអាត្មា នាំស្មុគ យាត្រា មិនដូចបំណង ។ គួរអញលបរត់ ចេញចាកប្រាកដ សោះ កើតសៅហ្មង បបកគិតហ្នោះ លបស្ទុះចេញហោង ដើរស្រូតរំលង ផល់ជ្រុងបត្តា ។ ឃើញយក្ខិណី ប្រែប្រាណឥន្ទ្រិយ ជាខ្មោចមាយា គិតញីរង់ប្រាប់ ស្ងៃងស្ងប់កោមា បបកម្ពុជា ឡើងលើថ្នា ។ ឈ្មោលក្អែក លោតចុះ ធ្លាក់ក្នុងបាតជ្រោះ បាក់កអាត្មា ក្សិណក្ស័យជីវី យក្សស្រី នោះណា ឃើញហើយជ្រះថ្លា ក្រោកឈរឡើងរាំ ។

នេះបនព្រហ្មគីតិ ពិតពិនិត្យពិន័យនាំ សេចក្តីកែពាក្យពាំ ពាក្យពិតកាលបបកនោះ ។ ក្សិណក្ស័យជីពផង យក្សម្ចាស់ភ្នាលោតចុះ រើសខ្មោចបបកនោះ នាំប្រគល់ទូបរភោគ្គា ។ ស៊ីសាច់ហែកហុតឈាម

www.budinst.gov.kh www.elibraryofcambodia.org

ហូររអាមពេញមុខា ឈាមស្រក់ទៅគ្រប់ណា យក្សទុខលំទូឥតមាន សល់ ។ ឆ្អឹងឆ្អែងយក្សទំពា គ្រប់រលាក្បាលសំណល់ បរិភោគឆ្អែត ស្កប់ស្កល់ តាំប្រុតន្ទូវិលហានបិត ។ រីឯខ្មោចបបក ស្លាប់ទៅយកជាតិ ផ្ចប់ចិត្ត កើតជាព្រះអាទិត្យ រុងរឿងរះត្រចះថ្លា ។ ទុំទែងចងប្រាលផ្កា ភ្លឺសន្ធៅតាំងលោកា ស័ក្តិសិទ្ធិទ្វេបេស្តា បរិវារហោមសម្រាប់បុណ្យ ។ ហេតុផលបបកបាន សាប់ឲ្យតានមកពីមុន ជួយជូនកើតដោយគុណ បុណ្យចិត្តកាត់ឥតសង្កា ។ សុរិយាបបកគិត អរកុសិចិត្តឥតឧបមា ថាទក្តិប្រាថ្នា អង្គអញអើយធាប់ធុតក្រៃ ។ ម្ល៉េះហើយគ្មានខណា ផ្ទុំមបេស្តា មានគេជាដៃ រុងរឿងថ្កើងជោគជ័យ នៃអង្គអញពេញក្បៀវក្លា ។

រីឯមេអំណើររេះ ឌីងឈប់ស្មេះតុំខរពា បបកសែងសុរិយា ទំណូកានទុកពុំស្រដី ។ ទើបឌីងនិគនពី បបកញាក់ក្បាក់ឡើងទ្វា ឈ្មោលបាត់អង្គិគ្គី ញរកេរកតក្កមា ។ ស្រង់កុំនរកតាមផ្លូវ ដល់គ្រោះគ្រៅឃើញ សរិរសា សំណល់យក្សភោគ្គា ញប្រេះប្រាណជួលសង្វេច ។ ភានភាំង តាំងស្មារតី អស់ឥន្ទ្រិយញីចំប្រប់ ផង្អើមហូតប្រសប់ ប្រវេញខ្សល់ សល់សែនខ្ញុំ ។ ហើយហៀបហាក់ឌឹងក្ស័យ ក្សិណប្រល័យជនឆ្លីវ សូន្យស្កុងស្កុងនៅទី គ្រោះដែលឈ្មោលក្ស័យនោះណា ។ លុះបាន ដឹងស្មារតី ភ្ញាក់ឥន្ទ្រិយខ្ជួញទៅថា ឱអ្នកប្រុសស្នេហា ម្តេចអ្នកមក ក្ស័យបង់បាត់ ។ តាកហោលប្អូនអា នៅកំព្រាសៀមស្ងប់ស្ងាត់ ខិតស

www.budinst.gov.kh www.elibraryofcambodia.org

ប្រាសព្រោកព្រាត ផុតពីទ្រូងប្អូនទៅហើយ ។ តាំងពីថ្ងៃនេះទៅ សម
ប្អូននៅឯកឯកត្រើយ អ្នកប្រុសថ្លៃប្អូនអើយ ប្អូនទៅរកអ្នកឯណា ។ ឲ្យ
ដូចប្រុសវរមិត្ត មិត្តរួមចិត្តឥតសង្កា ប្អូនបំរើផ្ញើវាចា ជូនជីវិតនឹងអ្នកថ្លៃ ។
ម្ដេចអ្នកចោលប្អូនទៅ ឲ្យប្អូននៅកំព្រាក្រៃ ឥតពឹងឥតអាស្រ័យ ពោះ
ចង់ផុតស្លាត់ទៅហោង ។ សូវក្ស័យជីវិតទៅ ជាជាងនៅកើតសៅហ្មង
ទល់ទុក្ខៗចំបង រងលំបាកលុះអស់កាល ។ ធ្លាប់ដឹកធ្លាប់គោក្ដា
ធ្លាប់បរទាធ្លាប់ស្និទ្ធស្នាល ធ្លាប់នៃបធ្លាប់ត្រអាល ធ្លាប់រួមសេរួមមណ្ឌល ។
ឥឡូវអ្នកប្រុសប្រាស ប្រាសនិរាសពិតពុំយល់ អ្នកអើយសមប្អូនទល់
ទុក្ខកណ្ដាលកណ្ដាលព្រៃ ។ តាំងខ្ញូញពីព្រលប់ លុះយប់ចប់ចូលដល់ថ្ងៃ
រៀងរះច្បាស់ព្រឹកព្រៃ ព្រឹកព្រាងស្ងាត់សែនសុរិយា ។ បបកឃើញ
ថ្ងៃជាក់ ជាទុអ្នកប្រុសស្នេហា អ្នកធ្លាប់នាសុរិយា រង់រៀនរះក្រចះខ្មៅ ។
អ្នកយកប្អូនទៅផង ស្និទ្ធស្នេហ៍ស្នងនៃបនិត្យនៅ លើឋានទេព្យសន្ធៅ
នោះហ្មងសៅសែនទុក្ខា ។ បបកញីខ្ញូញទៀត ពឹងចង្អៀតក្នុងទុក
ប្រះក្រុណាសែនសោកា សែនអាទ្យោះអាល័យលង់ ។ ពីព្រឹកលុះ
ដល់ត្រង់ សោកសូខ្យស៊ុនទល់ទុក្ខធ្ងន់ លុះថ្ងៃទេរទើបចង់ តាមទៅ
ទៀបចុងព្រឹក្សព្រៃ ។ ក្អួចផឹកក្អួចគោក្ដា អត់គោផងទាស្ដមសន្ទ
សន្ទឹកនឹកអាល័យ ទៀងខ្ញូញទៀតជួលប្រះប្រាណ ។ ជាទុព្រះសុរិយោ
ស្នួនស្នេហាមិត្តកល្យាណ ជ្រៀនជ្រៃបែះបៀតបាន បៀតទៅទៀបចូល

www.budinst.gov.kh www.elibraryofcambodia.org

សន្ធិយា ៗ អ្នកអើយប្អូនក្តៅក្តាត់ ថ្ងៃត្រូវខាត់ឈើទួលផ្កា ដូចអ្នកយក ទាន់ថ្ងៃ កាប់កាត់ប្អូនសស់ពុំពោះ ។ ចចកញីសន្ទប់ ញាំចំប្រប់ ស្អូត្យស្គន់សោះ ដួលដេករទាំទៅនោះ លុះព្រលប់ចូលសន្ធិយា ។ សនៀវធ្លាក់ចុះត្រង់ ជ្រាបរ៉េកកន្តសព្វកេខា ត្រជាក់សសំអង្គ ក្ដាក់ ឡើងខ្លួនភ្ញាក់សែនសប្បាយ ។ ខ្លួនតាំងពីព្រលប់ លុះចូលបប់ចូលអធ្រាត្រ កាករះព្រាងព្រាត ក្នុងគុបរះពេញមេឃា ៗ ចចកមៀនមើលផ្កាយ ពុំសព្វបាយខៃខ្មុទ្ទា ថាផ្កាយនេះណា ដាវរក់អ្នកប្រុសគន់ ។ ប្អូន ឃើញតែបរិកា ជាត់សន្ធ្យាប្រុសល្ហាសល្អន់ អ្នកអើយប្អូនគយគន់ រក មៀនមើលមិនឃើញអ្នក ។ ចចកខ្លួនភ្ញូចប់ទុក្ខ គ្មានសាន្តសុខស្អូល អនកាក់ លុះព្រឹកព្រាងស្វាងផាក់ ទៀនខ្លួនទៀតសព្វវេលា ។ មួយថ្ងៃ ខ្លួនបីដង រំងរំគរងទុក្ខវេទនា មួយយប់ខ្លួនបីគ្រា គាំមិនគ្គររៀងទៅ ។ ពុំផឹកពុំបរិភោគ សុមថោកថោកជាំមោ កម្លាំងថយតិចទៅ ទ្រាយ តាមទន់តន់ប្រមាណ ។ ដើរដួលតាំងតំហារ ទំនេរគ្រាំឈរដេកពុំបាន ក្សិណក្សយតាកតោះលេហាន ចាំងទម្ងន់គោរពេញពោះ ។

ដំណើរចចកញី ក្សយជីវិតត្រូវគ្រានោះ ឈប់ស្មុះនៅនេះចុះ ខឹង និតានឯសុរិយា ។ រុងរឿងរំចួរឆ្ស៊ី ស្វាងស្ម៉ីក្រលោកា ដួចដួចប្អូន មាសា មានពពកមកបាំងបិទ ។ ចាំងថែងសែងសុរិយ៍ ចំបូរស្អាងជុំ ផុកផិត ជាក់វង់គ្រះតាចិត្ត ពេញមណ្ឌល ទល់មេឃា ។ ក្សិណនោះ

www.budinst.gov.kh www.elibraryofcambodia.org

អង្គសុរិយា បបកណាទ្រង់ក្រោធា ថាហើយលើកហត្ថា ស្ទុះក្រោកចាក ពិមាន ។

នេះបទពំនោលឆិនាង ដំណើរជាយជាន ឯអង្គបបកសុ-
រិយា ។ ក្រេវក្រោធលោភលោតស្ទុះស្ទា គប់ទះហត្ថា ក្រឡេតក្រឡៀ ប្រឹងប្រាណ ។ ថាយើងណាហៅហាន ប៉ុនមុខអញបាន ទទឹង ទទែងមីរមក ។ មើលផាក់ហាក់ហើតពក ហាក់ជាសពាសមក តបគតបះ ទឹងអញ ។ អើយើងមិនញុំមបុះតាញ់ គយុទ្ធវិលវិញ ឲ្យដឹងតេជ ដៃឥឡូវ ។ សុរិយាប្រឹងចែងហាំងទៅ ពតកទឹងទៅ ពុំមានកក្រើក ទៅណា ។ ប៉ុនចិចជុំជិតសុរិយា រឹងក្រេវក្រោធា ថាអះអង្គអញ សព្វថ្ងៃ ។ មិនមាននរណាមួយក្រែ ផ្ទឹមស្មើគេដៃ ប្រឡងអំណាច ១ះថែង ។ មានតែអង្គអញឯកឯង ជាធំចំពោង បញ្ចោបឥតគូផ្ទឹមបាន ។ ឥឡូវពតកសាមាន្យ ហ៊ាំងសែងស្ទូវ្យគាន ជុំជិតទឹងឥតមេឃា ។ អះអញ សែងជាតិសុរិយា ហើយសូមប្រាថ្នា កើតជាពតកទុកតាប ។ ជេរជាស ពេញពាសខ្ទាំខ្ទាប់ សុរិយាអង់គាប់ ផងឹតផងលំណាស់ណា ។ ពតក បបកកាឡា អវងឹងមហិមា ស្រួលសើចសំណើចក្អាកក្អាយ ។ ថាអើ នេះហៅសប្បាយ លើសលែងសត្វសាយ ស័ក្ដិសិទ្ធិរឹងរឹទ្ធិចេស្ដា ។ អង្គអញលើសលែងលោកា ម៉េះគ្មាននរណា ជាគូតបតវៀនរឹទ្ធិ ។ អញ ប៉ុនស្ទូវ្យសែនព្រះអាទិត្យ ជេរជាសងឹត គ្មានរឹទ្ធិស្មើអញឡើយណា ។

www.budinst.gov.kh www.elibraryofcambodia.org

កាលនោះរដូវវស្សា មានព្យុះពេញ្យាមា សន្ធឹកសន្ធាប់ខ្លាំងក្រៃ ៗ បក់បោក
រលកជលស័យ បាក់បែកឈើព្រៃ រលំរលើងគ្រៀចគ្រា ៗ ផាត់ផាយ
ផុយផង់ពសុធា ផ្សែងផ្សព្វមហិមា ផង្គោលផង្គុំមីរមក ៗ បក់ផល់សុរិយា
ពពក ផាត់ផាយបាចបោក បាត់ជង់តុងផង់ពុំនល្អង ៗ សុរិយាពពកនោះ
ហោង ក្រោបក្រៃកន្ទង ថាឃើញគ្គអញសព្វថ្ងៃ ៗ មិនមាននរណាតថៃ
ឥឡូវនេះក្រៃ មានខ្យល់ដ៏ខ្លាំងបក់ផាត់ ៗ កើតជាពពកខ្សោយក្លាត់
អញបង់គិតគាត់ ជាតិជាពពកខោលខេញ ៗ ប្រាថ្នាកើតជាខ្យល់វិញ
ខ្យល់នេះគ្មានពាញ់ គ្មានភ្នំបំណាចនរណា ៗ កាលនោះពពក
សុរិយា តាំងចិត្តប្រាថ្នា កើតជាវាយោផាត់ផាយ ៗ ផាត់ផង់ធូលី
ភ្នាត់ភ្នាយ ព្រឹក្សាឥន្ទ្រាយ រលើងរលំគ្មានសល់ ៗ ញាប់ញ័រប្រឹថពី
មណ្ឌល បោកបក់ទៅផល់ ដំបូកដំស្គកខ្ពស់ខ្ពង់ ៗ ខ្យល់បក់គាប់គក់
ត្រូវត្រង់ ដំបូកនៅគង់ ដំហរដំហើមទប់ទល់ ៗ នៅនឹងបទ្រមឹង
ដូចដល់ ឥតមានអំពល់ កក្រើករំពើកឡើយណា ៗ វាយោពពកគិតថា
ឃើញមាននរណា មកទល់អង្គអញជាខ្យល់ ៗ អញបក់ព្រឹក្សព្រៃគ្មានសល់
ប្រឹថពីមណ្ឌល ញាប់ញ័ររន្ធត់ណាស់ណា ៗ ទោះទឹកសមុទ្រគង្គា
អញទង់បែកជា រលករលាយគ្មានសល់ ៗ កាលនោះវាយោគិតឆ្ងល់
ក្នុងចិត្តភ្ញាយខ្វល់ ថាអះដំបូកស្គកស្គឹង ៗ ដំហាមគ្រមាមបទ្រមឹង
ទ្រមឹកស្តឹកស្តឹង រឹងរឹងមិនបាញ់នរណា ៗ ឈ្នះអញដាមហាកា

www.budinst.gov.kh www.elibraryofcambodia.org

ហោះអញប្រាថ្នា កើតជាដំបូកវិញចុះ ។ វាហោពពកគិតហោះ លែង ជាតិខ្យល់នោះ កើតជាដំបូកស្កុកស្កឹង ។ ព្រងើយទ្រមើយទ្រមឹង ខ្យល់ បក់ទៅទិស មិនមានគំរើកដល់តិច ។ ទោះបីខ្យល់ព្យុះមេឃ ៗ បក់ បោកខ្លាំងតិច ដំបូកក៏នៅនឹងថ្កល់ ។ ដំបូកបបកឥតធ្លុល ជាមេះត្រូវ គល់ ចិត្តអញប្រាថ្នាមួនមាំ ។ ខ្យល់ព្យុះបក់ចុះតគ្រាំ ភ្លៀងទេរជោកជាំ អញទ្រាំអញទ្រទ្រង់បាន ។ កាលនោះមានសត្វតិរច្ឆាន ក្តាន់គ្រោស មួយមាន ហ្វូងក្តាន់ដើរតាមគ្រៀបគ្រា ។ ក្តាន់ដល់ដំបូកនោះណា ចូលលិទ្ធកោក្តា ខ្លះវែខ្លះជល់តោមផុះ ។ ខ្លះកាយរលាយរលុះ ដំបូក ធំនោះ ពុំអាចទ្រាំទ្រនៅបាន ។ ដីជ្រោយធ្លុះធ្លាយបេញថាន ក្តាន់លែង ជាលាន រលំដំបូកនោះទៅ ។ បបកដំបូកនោះគួរ ទេទឹងក្រញូវ ក្រញែង កន្ត្រែងសិរសា ។ ដំបូកបបកគិតថា អញបង់ប្រាថ្នា ទៅកើតជាក្តាន់ នោះវិញ ។ គិតហើយប្រែប្រាណចាកចេញ ពីដំបូកមិញ ទៅកើតជា ក្តាន់ដូចចិត្ត ។ ក្តាន់ដើររកស៊ីឆ្ងាយជិត ឥតមានកំរេកិត គង់ចិត្ត ត្រេកអរគិតថា ។ អញបានដូចចិត្តប្រាថ្នា ម៉េះគ្មាននរណា ជាពីរទទឹង អញទៀតទេ ។ ប្រទះក្តាន់គ្រោសធ្លាង ព្រៃផល់ពាស់តៃ ចាលចាញ់ រត់ខ្លាញ់មូលព្រៃ ។ ដំណើរក្តាន់គ្រោសនោះនៃ ឈប់ស្ទះរលៃ ពុំមាននិទានឡើយណា ។

នេះជាឯប្រែបធ - កាកាតិកំណត់ កំណាព្យបទ គិតគាល

នោះមាន ព្រានព្រៃមួយណា ត្រាច់ត្រង់យាត្រា រុករកបរបាញ់ ។ រូបរាងកំប៉េះ កំប៉ោងក្រញេះ ក្រញេញក្រញាញ់ ក្រញូវក្រញើក ភ្នែកស្មើតសក់ព្រាញ់ ក្បួចតាក់កណ្ដាញ់ កណ្ដួចពកពាស ។ ព្រានដើរតម្រុក ព្រៃស្បាតពានរុក រកបាញ់រមាស រមាំងប្រើសក្ដាន់ កាប់កាន់បេញពាស រតស៊ីដើរដាស ក្រហមពាំងព្រៃ ។ រីក្ដាន់ដំបូក រូបរាងធំស្គុក ការហ្មងរំពៃ មានក្ដាន់ទៀងឯក ចូលមកដែវៃ ក្ដាន់ដេញកិតភ័យ ចូលជិតពុំបាន ។ រីឯព្រានព្រៃ ឃើញក្ដាន់ធំក្រៃ អរពន់ប្រមាណ ធំឡើងស្មាក្រើត ក្រអឹតច្រើនប្រាណ លុកជន្សឈរឈាន ដើរតាមតិចទៅ ។ លូនវារចូលជិត ភ្នែកម្ខាងព្រានបិទ ម្ខាងបើកក្រឡៅ ក្រឡេកមិនមៀវ ស្រវៀវសំដៅ សម្រុកត្រង់ទៅ សោះកៃស្មាភ្លាំ ។ ត្រូវត្រង់ជាន់ឡើង ក្ដាន់ជួលបះជើង ស្ទុះក្រោកឡើងថ្ពាត់ ឈើតៀបផ្ទាយផ្កា ទាក្តៅក្ដាត់ ជ័រឆេះកាត់ ថ្មើមគុះធ្លាះចេញ ។ ឈាមហូរប្រោះមប្រោះ ខ្ទីខ្ទង់រន្ធាល ឆោះដនពាសពេញ ប្រឹងព្រៃបែរបោល ផ្ទួលផ្ដោលបុះវិញ ជន្ទ្រមព្រៃដេញ ញាក់ញ័រអន្ធា ។ ក្ដាន់គិតរំពឹង ថាអញនេះនឹង ក្ស័យរោបរូបា បើអញនឹងក្ស័យ ប្រល័យផង់ណា សូមទាប់ជាតិជា ចង់ព្រោះស្មាវិញ ។ ក្ដាន់គិតតែម៉្លោះ ក្សិណក្ស័យសូន្យសោះ ក្រឡាប់ជាតិចេញ ពីក្ដាន់ចចក ផ្ទោះផ្ទុកវិលវិញ វិលវិនមកមិញ កើតជាព្រៃគ្រឹស្មា ។ រីឯព្រានព្រៃ ឃើញក្ដាន់ក្សិណក្ស័យ ព្រានចូលម៉្ន

www.budinst.gov.kh www.elibraryofcambodia.org

ពនុះឃាតសាច់ សម្រេចភោជនា ផ្អឹងផ្អែងរហៃ ក្បាលព្រានពោលចេញ ។ រួចហើយព្រានទៅ ផ្ទះទីល័នៅ ព្រានជួបដើមវិញ មានកាលមួយថ្ងៃ ព្រានព្រៃចរចេញ ទៅដេកបរបាញ់ សត្វដូចសព្វគ្រា ។ ពុំបានសត្វសោះ វិលមកពីនោះ ព្រាននឹកគិតថា អញដើរបរចេញ រកបាញ់ម្រឹគា សត្វ ថ្ងៃហាក់ផង មានជ័យមានលាភ ។ អះឥឡូវអញស្តាយ កាលអញស៊ីបាយ ភ្លេចថ្វាយបាយាច ហេតុនោះអញស្វែង រកខ្នែងឥតលាភ ល្ហើយចុះ បាយាច ថ្ងៃក្រោយសឹមថ្វាយ ។ ហើយទើបព្រានព្រៃ នៀនភ្នែករំពៃ ព្រឹក្សាតាំងឡាយ មានមែកសាខា បុប្ផារីករាយ ភ្នកនឹកសប្បាយ ក្នុងចិត្ត គិតថា ។ ខុសស្ការផង ក្រអួចកន្ទួង សប្បាយណាស់ណា អញបង់ ជ្រៀតជ្រែង បានមួងទៅក៏ ហើយព្រានប្រៀតថា ចំនុកស្និទ្ធស្នេហ៍ ។ ជ្រែងអើយនាងជ្រែង ចងចេញបាញ់មួង ត្រកាលជាងគេ រកខ្នែងអប្រិយ បានអ្វីផ្ញើមេ វិលវិញទទេ សិទ្ធិផែះដើងគ្រាន ។ ស្រែកប្រៀតបណ្តើរ អក្បាលងើងើ រមិលខ្នងប្រាណ មុខស្ងួញមាត់ស្ងើញ សម្ញេញដូចតាន ព្រានប្រៀតកំសាន្ត ដើរដោយមាត់ ។ លុះបានដល់ម្ចប់ ព្រៃមួយ ចូលឈប់ ចូលចតនិន្ទ្រា នៅក្រោមម្ចប់ព្រៃ ព្រានព្រៃផ្តេកស្លា ប្រែប គល់ព្រឹក្សា ដេកលង់លក់ទៅ ។ មែនមានចចក កំព្រេយកំព្រាក កំព្រឹង ហ្វូងសៅ ចេញពីព្រឹក្សា ម្ជាចូលទៅ ត្រង់ព្រានដេកនៅ ក្រោមម្ចប់ ព្រៃនោះ ។ ចចកថាព្រាន រាបាញ់មិនបាន សត្វមួយដល់សោះ អញ

www.budinst.gov.kh www.elibraryofcambodia.org

ចាំកោត្ត ដោយសារព្រាននោះ ថ្ងៃនេះនែងសោះ គ្មានស៊ីកោត្ត ។ បបកមើលទៅ ឃើញស្នាផ្អែកនៅ គល់ជ្រៃសាខា បបកជាទុ លាកោ លាកា អញទៅចំពា បន្ទោះស្នានោះ ។ សង្កៀមស៊ីលេង កុំឲ្យរាប់ផ្នែង រាល់ថ្ងៃដើរសោះ បបកចំពា ត្រីត្រស្នាក្រៀមក្រោះ ពាល់ព្រោយជាបស្នោះ ស៊ីផាកោផនា ។ ឯគ្គាន់ធំនោះ ព្រហ្មថាបំពោះ កើតជាត្រីត្រស្នា លុះដល់ បបក កំព្រកនោះហា ចំពាត្រីត្រស្នា ដាច់ទៅដូចោះ ។ រីឯរីឯគ្នាន់គ្នាញ់ គិតថាអន្ទអញ កើតជាបន្ទោះ ស្នានេះមានរិទ្ធិ ស័ក្តិសិទ្ធិបំពោះ ឥតគេ សេ៊ុស្នោះ ស្ទឹមនឹងអញបាន ។ ឥឡូវបបក នេះកើតមក ពីណាហៅ ហិន ចូលឥតចំពា ត្រីត្រស្នាដាច់បាន បបកនេះមាន គំណាបផានា ។ បើនោះនូវអញ ព្រហ្មរឹលវិញ ឃោនឃេនជាតិយ៉ា បបកទើបបាន មែន មានបុត្រ គិតស្រេចកាឡា គ្រឡាប់ជាតិទៅ ។ កើតជាបបក កំព្រយ កំព្រក កំព្រើលហ្មាន់សៅ ដូចដើមផែលវិញ តៀវចេញទើបទៅ ព្រោះ លោភកំឡៅ កំឡាំងនោះហា ។ លោភបេទ់លើសលែង ហេតុកម្ម នោះឯង នាំឲ្យព្រហ្មថា កើតជាបបក កំព្រកនោះណា ឥតគេស្នេហា ជាមិត្តនិត្យនៅ ។ ហេតុនោះពាក្យព្រេង ព្រឹទ្ធប្រាជ្ញទុកតែង ទូន្មាន កូនចៅ ឲ្យប្រែលះលោភ ចេញចាកចោលទៅ កូនអើយនេះហៅ គំនិត ផ្កាតៀ ។ ទុកតជាច្បាប់ ទៅមុខគ្រាន់គ្រាប់ គ្រាន់គ្រង់កុំធ្វើ កុំឲ្យ ចូលចិត្ត គំនិតផ្កាតៀ ត្រូវចាំត្រូវជៀ ត្រូវចៀសឲ្យឆ្ងាយ ។ កុំព្រាប់បបក

www.budinst.gov.kh www.elibraryofcambodia.org

មោហាក់ព្រេក កំព្រើលអន្តរាយ សេកក្រៅគន្លង អ្នកផងចាំផ្សាយ
លោកលុះអន្តរាយ ជាតិជួនប្រិយ ។

នេះបទព្រហ្មគីតិ ចប់ជុំដំកជូនសេចក្តី ល្បិចល្បើកលើកជាថ្មី
ពីដំណើរសត្វបក ។ តែចប់ស្រេចចាន ពីបុរាណមានទៀនមក
និយាយកយកចរក ជាតិណាតទៅមុខ ។ លើកគ្រាន់មើលកំសាន្ត
គ្រាន់មិនបានកែអក្សរ ជាកើតតទៅមុខ មានប្រការដូចេះស្រាច់ ។
ព្រះគ្រូ(១)សកកជគ្រាន់ គ្រប់ពីរភាគជូនយោកប់ វស្សាឆ្នាំឯកសក
ខែកត្តិកដប់មាសា ។ ថ្ងៃចាននៃក្តីប្រាក់ គ្រប់ឆ្នាំមមេរកា ហោមគូវផ្ទុំជា
ខែផល្គុនការឯទៀត ។ នាថ្ងៃព្រហស្បតិ៍ វេលាទីដប់ពីរកើត ពាក្យ
ពេចន៍ពោលពុំនេត ខុសភាគជូនផងមិនសម ។ នាមខ្ញុំឈ្មោះសោត
សិន អ្នកផងដីដមិនប្រចាំ អក្សរក្មេងចិ ដើនបុកក្រោមដាក់កមុខ ។
ហើយ គួស លើពីរ(២)ផង តាមទំនងអ្នកប្រាជ្ញទុក ខ្សែរៀនជាទំនុក
បិត្តសំគាល់គួរអត្ថ ។ បើលោកណាមើលមៀន កុំគួរជៀនៗជៀលនិន្ទា
ផ្តាំគ្គងពាក្យគ្រងណា ជួយតម្រង់ផងឲ្យបាន ។ សុំរឿងចររិយាយ
ជានិយាយពីបុរាណ ទៀនមកមាននិទាន ប្រការផ្សេងឯងហោង ។

១- ព.ស. ២៤១៧ គ.ស. ១៨៧៤ ។ ២- ម៉ុក ។

## ១២- រឿង បុរសថ្លង់បួននាក់(១)

កាលពីព្រេងនាយ នៅភូមិមួយ មានបុរសថ្លង់ ៤ នាក់ ឈ្មោះ យុគ១ ស៊ុម១ គង់១ សុខ១ ។ បុរសថ្លង់ ៤ នាក់នេះ ជាមនុស្សកំសត់ទុគ៌តណាស់ ក្មេងៗនិងអ្នកស្រុកអ្នកភូមិ តែងស្រែកហៅគាត់ថា “តាចុំ តាតែក ! តាចុំ តាតែក!” ជារាល់ពេល ។

ថ្ងៃមួយ បុរសថ្លង់ទាំងបួននាក់ បានជំនុំស្រុះស្រួលមូលមតិគ្នាថា “យើងទាំងអស់គ្នា ពុំគាប់រស់នៅក្នុងកន្លែងនេះយូរទៅទៀតបានទេ ខ្មាសអ្នកនគរខ្លាំងណាស់ ព្រោះអ្នកផង គេមើលងាយយើងពន់ប្រមាណ ដូច្នេះត្រូវយើងចេញទៅរកគ្រូមើលជម្ងឺ ដើម្បីធ្វើឲ្យសក់ក្បាលយើង ដុះឡើងល្អដូចផងឯទៀត” ។ ជនតាថ្លង់ ៤ នាក់ ក៏ស្រុះស្រួលព្រមព្រៀងគ្នា ប្រុងប្រៀបរៀបចំគ្រឿងប្រដាប់ប្រដាធ្វើដំណើរ រួចក៏ធ្វើដំណើរចេញទៅ

---

១- ដកស្រង់ពីសាស្ត្រាស្លឹករឹតលេខ ៦១៣ និង ៦៤៧ នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ជាពាក្យកាព្យ ។ រៀបរៀងជាពាក្យរាយ ដោយលោក សក់-ខាត់ ដែលមានចុះផ្សាយក្នុងសៀវភៅប្រក្រតិទិនកម្ពុជា លេខ ម/១៤៨១ បោះពុម្ពផ្សាយដោយ សមាគម សុជាតស ពីឆ្នាំ ១៩៤៦ ទំព័រ ១៥៥ ។ មានតំកល់នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ។

www.budinst.gov.kh www.elibraryofcambodia.org

កាត់ស្រុកធំតូច កាត់ភូមិកាត់ស្រែ ស្វែងរកពេទ្យហ្មាមេមត់ជំនិញប្រសប់ ដែលអាចធ្វើឲ្យក្បាលខ្លួន ផុះសក់ឡើងវិញបាន ប៉ុន្តែ បុរសទំពែក ៤ នាក់ ឥតបានជួបនឹងជនដែលមានវិជ្ជាសំណាបដូច្នោះសោះ ។

ជនទំពែក ៤ នាក់ក៏ធ្វើដំណើរតទៅទៀត លេចកាលចូលព្រៃ លេចព្រៃចូលកាល លុះត្រាតែទៅដល់ព្រៃហេមពាន្ត ដែលជាកន្លែងមហាឫសីមួយ ។ បុរសទំពែក ៤ នាក់ក៏ចូលទៅក្នុងអាស្រមតាបសនោះ ទទកាយថ្វាយបង្គំដោយសេចក្តីគួរសម ។ តាបសីសួរថា "តើអ្នកទាំង ៤ នាក់ អញ្ជើញមកពីប្រទេសណា ? មានការអ្វី ?" ។ បុរសទំពែក ៤ នាក់ក៏ឆ្លើយប្រាប់តាបសីថា "ជំរាបលោកតា យើងខ្ញុំទាំងអស់គ្នា មកពីប្រទេសឆ្ងាយណាស់ ដោយហេតុតែយើងខ្ញុំទំពែក ទាំងអស់គ្នា ពួកអ្នកស្រុកទាំងឆ្ងាយ ចេះតែសើចចំអកឲ្យគ្រឿយ ឲ្យជារាល់ពេលកាលវេលា ហើយយើងខ្ញុំអត់ទ្រាំពុំបាន ចេញមកស្វែងរកគ្រូពេទ្យ ដែលចេះធ្វើក្បាលយើងខ្ញុំឲ្យផុះសក់ ដូចជាជនឯទៀតឡើង ប៉ុន្តែ យើងខ្ញុំឥតបានជួបប្រទះគ្រូពេទ្យណាមួយសោះ អាស្រ័យហេតុនេះ បានជាយើងខ្ញុំ ខំធ្វើដំណើរទាល់តែមកដល់អាស្រមលោកតានេះ សូមលោកតាករុណាអាសូរយើងខ្ញុំ ជួយធ្វើយើងខ្ញុំឲ្យបានផុះសក់ដូចគេឯទៀតឡើង" ។

តាបសក៏ឆ្លើយថា "ចុះមានលំបាកអ្វី ទៅទាំងឆ្ងាយកើយ ! នៅទីនេះមានត្រពាំងទឹកស័ក្តិសិទ្ធិមួយ ចូរអ្នកទាំងឡាយទៅមុជទឹក ក្នុង

www.budinst.gov.kh www.elibraryofcambodia.org

ត្រពាំងនោះចុះ ប៉ុន្តែ ត្រូវតែគង់តាំងអស់គ្នា មុជតែម្តងបានហើយ កុំមុជច្រើនដងឲ្យសោះ" ។

កាលបើបានឮតាបស ប្រាប់ដូច្នេះហើយ បុរសថ្ពក ៤ នាក់ក៏កើតសេចក្តីរីករាយ ជាក្រៃលែង ហើយចុះទៅមុជទឹក ក្នុងត្រពាំងនោះតាំងអស់គ្នា ។ មួយសន្ទុះក្រោយមក បុរស ៤ នាក់ក៏ងើប ចេញពីត្រពាំងទឹកឡើង ហើយនៅលើក្បាលរៀងខ្លួន ក៏មានដុះសក់យ៉ាងក្រាស់ខ្មៅរលោង ។ លោកតាថ្ពកយើង ៤ នាក់ ក៏ទំសំឡឹងមើលក្បាលគ្នា ទៅវិញទៅមក ហើយលាន់មាត់ សរសើរតែរៀងខ្លួន ។

នៅខណៈនោះ បុរសថ្ពក ៤ នាក់ ក៏កើតមានចិត្តលោភលន់ប្រមាណ ទើបនាំគ្នាថា "យើងតាំងអស់គ្នាបានមុជទឹកនេះ ត្រឹមតែម្តងប៉ុណ្ណោះ ឃើញថាបានល្អប៉ុណ្ណោះហើយ ចុះទំរាំតែយើងមុជច្រើនដងទៅទៀត តើយើងនឹងល្អយ៉ាងណាទៅ តាបសប្រហែលជាមិនចង់ឲ្យយើងល្អណាស់ទេ មើលទៅ បានជាបង្គាប់ឲ្យយើងមុជទឹកតែម្តងទាក់ដូច្នេះ គួរតែយើងទៅមុជទឹក ឲ្យបានម្តងម្នាក់ទៀត" ។

បន្ទាប់មក, បុរសថ្ពក ៤ នាក់ ក៏ស្រុះស្រួលគ្នា ហើយបបួលគ្នាទៅមុជទឹក សាជាថ្មីទៀត ប៉ុន្តែ ម្តងនេះកាលបើងើបឡើងពីទឹកភ្លាម បុរសក៏សត់ឃើញ ជ្រុះបាត់សក់អស់ នៅសល់តែក្បាលថ្ពក រលីងពិញដូចកាលពីដើមវិញ អាស្រ័យហេតុនេះ បុរសថ្ពក ៤ នាក់ ក៏កើតសេចក្តី

www.budinst.gov.kh www.elibraryofcambodia.org

ឈើចាក់ ព្រួយចិត្តជាក្រៃលែង ហើយក៏បបួលគ្នាមុជទឹកម្ដងទៀត ប៉ុន្តែ លុះងើបឡើង ក្បាលនោះ រឹតតែថ្លុករលីងជាងមុនៈទៅទៀត, ថ្ងាសក៏កាន់តែរលោងឡើង ៗ កាលពីពេលមុន, បុរសថ្លុក ៤ នាក់ គ្រាន់មានសក់ពីរ-បីសរសៃ ដុះនៅលើក្បាល ប៉ុន្តែ កាលបើមុជទឹក អស់ចំនួនបីលើកដូច្នេះហើយ ក្បាលបុរសថ្លុកទាំង ៤ នាក់ ឡើងរលោងស្រិល ដូចជាក្បាលសត្វត្រដក់ ។

បុរសថ្លុក ៤ នាក់ អស់សង្ឃឹមក៏ដើរចេញពីទីនោះ យំត្អូញត្អែរថា "ការនេះ បណ្ដាលមកពីយើង មិនប្រតិបត្តិតាមដំបូន្មានតាបស ដូច្នេះ ត្រូវតែយើងត្រឡប់ទៅជួបតាបសវិញ ហើយអង្វរលោកគ្រូ សូមឲ្យគាត់ជួយធ្វើក្បាលយើង ទោះមិនបានពេញជាល្អទេ គ្រាន់តែនៅប្រហែលពីដើមវិញចុះ កុំឲ្យរលីង រលោងស្រិលដូចក្បាលត្រដក់ដូច្នេះ អាក្រក់ណាស់" ។

លុះនិយាយគ្នាដូច្នេះហើយ បុរសថ្លុកទាំងឡាយក៏ធ្វើដំណើរ ត្រឡប់ទៅកាន់សំណាក់តាបសវិញ ។ តាបសសួរថា "តើមានការអ្វី ទៅទាំងឡាយ ?" ។ ទៅថ្លុកក៏ឆ្លើយថា "លោកតាជាទីគោរព, យើងខ្ញុំសូមអង្វរលោកតា សូមលោកតាមេត្តាប្រណីទោស ដល់យើងខ្ញុំផង ដ្បិតយើងខ្ញុំ កុំបានធ្វើតាមបង្គាប់លោកតា បានជាក្បាលយើងខ្ញុំ រឹតតែរលីង ជាងថ្ងាសទៅទៀត យើងខ្ញុំសូមអង្វរលោកតា ឲ្យជួយធ្វើយ៉ាងណា ឲ្យក្បាលយើងខ្ញុំទាំងអស់គ្នា បើមិនបានល្អ ក៏សូមឲ្យតែនៅ

www.budinst.gov.kh www.elibraryofcambodia.org

ប្រហែលពីដើមវិញ ក៏បានដែរ" ។

តាបសឆ្លើយតបវិញថា "ទុះបើទាំងឡាយហើយ អាត្មាពុំអាចញ៉ាំង ខ្លួនអ្នក ឲ្យទៅជាយ៉ាងម៉េចបានទៀតទេ កំហុសរបស់អ្នកជាភស្តុតាង បង្ហាញឲ្យដឹងថា អ្នកទាំងឡាយ ពុំតាមប្រតិបត្តិតាម ដំបូន្មានពីបាកៗ បានទេ, តែចូរអ្នកពិចារណាផ្លូវនេះ ថា "សេចក្តីប្រាថ្នាហួសប្រមាណ បណ្តាលឲ្យហិនហោច" ។ ណ្ហើយ ! ចូរអ្នកត្រឡប់ទៅស្រុកអ្នក វិញទៅ គ្មានមធ្យោបាយអ្វី តាបសផ្លាស់ប្តូររូបអ្នកបានតទៅទៀតទេ" ។

បុរសផ្ដែកទាំង ៤ នាក់ក៏ត្រឡប់ទៅស្រុកវិញ ហើយម្តងនេះ អ្នក ស្រុករឹតតែពោលចំអកឡកឡឺយឲ្យ ជាងមុនទៅទៀត ។

បុរសផ្ដែកទាំង ៤ នាក់ ក៏រឹតតែខ្មាសគេខ្លាំងលើសដើម ហើយរក មេមត់យ៉ាងគួរកៗ ល្បីល្បាញឲ្យឃើញប្រេង ក្រមួន ទឹកថ្នាំត្រាំស្លៅ ឬឈើ ដែលមានគុណភាពយ៉ាងប្រសើរៗ មកលាប មករឹត ប្រហាក់ លើសាប ក្បាលរបស់ខ្លួន ព្រមទាំងសូត្រមន្តអាគមនានា ផ្សំជាមួយផង តែទោះបី ទំរើយ៉ាងណា ក៏ក្បាលនៅតែគ្មានដុះសក់ដដែល រលោងស្រិល ដូចជា គ្រាប់ត្រសក់សមុទ្រ ។ នេះគឺជាផលកម្មពិតប្រាកដ ដោយគាត់បានប្រព្រឹត្ត អំពើកំហុស អំពីជាតិមុន ឬមួយកាលពីជាតិមុន គាត់ប្រកបរបរគេស្រ កាត់សក់ ហើយបំពេញការងារកិច្ចរបស់ខ្លួន ពុំបានត្រឹមត្រូវ ។

ទោះបីមានវត្តភាព គួរឲ្យគាប់ចិត្តដូចពោះហើយក៏ដោយ ក៏ប្រុស

ថ្ពែក ៤ នាក់នោះ មានចិត្តដូចជាផងឯទៀតដែរ គឺគាត់មានចិត្តប្រាថ្នាជាខ្លាំង ចង់យកក្បាលគាត់ ទៅកើយលើភ្លៅនារីជាទីសប្បាយ ប៉ុន្តែគ្មានស្រីណាម្នាក់ ព្រមស្រឡាញ់បុរសថ្ពែក ទាំង ៤ នាក់នោះសោះ ដោយហេតុតែគាត់មានលលាដ៍ក្បាល រលីងរលោងដូចគ្រឡោក ដែលគេខាត់ដើម្បីទុកដួសទឹកផឹក ។

ហេតុនេះហើយ បានជាគេឃើញបុរសថ្ពែកមានវ័យចាស់ៗណាស់ហើយ ប៉ុន្តែ ពុំទាន់មានប្រពន្ធនៅឡើយ ហើយទោះបី គាត់មានអាយុចាស់ប៉ុនណាក៏ដោយ គាត់នៅតែខំស្វែងរកប្រពន្ធ ឥតឈប់ឈរ ។ ប៉ុន្តែ ម្តងនេះបុរសថ្ពែក ៤ នាក់ ចេញស្វែងរកប្រពន្ធ ដោយចិត្តងប់ល្ងប់តែម្តង គេពុំដឹងថា តើមានហេតុយ៉ាងណាទេ គេគ្រាន់តែដឹងថានេះ គឺជាវត្ថុបំណងរបស់គាត់ យូរណាស់មកហើយ ហើយការនេះ ក៏ទៅជាទម្លាប់មួយ របស់ពួកគាត់ ។

ព្រេងវាសនាបាននាំគាត់ទាំង ៤ នាក់ឲ្យមកជួបគ្នាហើយ ស្រឡាញ់គ្នាណាស់ បានស្បថស្បែគ្នាថា មិនត្រូវរស់នៅបែកគ្នាឡើយ ។ បើមួយទៅណា អ្នកឯទៀត ក៏ត្រូវទៅតាមដែរ ។ ហេតុនេះហើយ បានជាគេឥតដែលឃើញលេចបុរសថ្ពែកមួយ ចេញពីច្រកបង្អៀត ដោយឥតបានឃើញថ្ពែកបីនាក់ទៀតមកតាមក្រោយផងឡើយ ។

គេតែងឃើញឈ្មោះ យុគ ដែលមានកន្ត្រស់ស្គម សៀកទោទ្វី

www.budinst.gov.kh www.elibraryofcambodia.org

ដើរមុខ ហើយគេរៀនជាប់ចិត្តគាត់ទាំងអស់ ទោះបីគាត់ទំប្រយ័ត្ន កុំឲ្យដើរលឿនពេលគេកំដោយ ។ បន្ទាប់មក គេឃើញឈ្មោះស៊ុម ដែលមានមាឌតូចជាក់ ទំដើរទីងទាំងៗ ដូចសត្វអណ្ដើក តាមយុគ ។ បន្ទាប់មកទៀត គេឃើញនំ ខិង ស៊ុមដើរទន្ទឹមគ្នា ។ ពីរនាក់ក្រោយនេះជាមនុស្សដែលខ្លួនខ្លាជាក់គ្រវៀកគ្នាទៅវិញទៅមក ព្រោះគាត់គ្រវៀកពុំសូវបាន ។

ថ្ងៃមួយ យុគនិយាយទៅកាន់សំឡាញ់ខ្លួនថា "យើងពុំអាចរកប្រពន្ធ នៅក្នុងស្រុកនេះបានទេ ទោះចាស់ក្ដី ក្មេងក្ដី ស្រីៗ នៅក្នុងស្រុកនេះ គេមាក់ងាយមាក់ងោកយើងទាំងអស់ ដោយហេតុតែក្បាលយើងត្នាមផុះសក់ ប៉ុន្តែ បើយើងទៅកាន់ដំបន់មួយទៀត ប្រហែលជាយើងមានសំណាងជាងនេះ ហើយបើមាននរណាថាយើងចាស់ យើងអាចឆ្លើយទៅវិញថា សក់យើងជ្រុះ ព្រោះជាធម្មតារបស់ជន ដែលមានអាយុច្រើន និងមានការព្យាយាមគិតគូរច្រើន, កាលបើដូច្នេះ អ្នកស្រុកមុខជាយល់ថា យើងជាអ្នកមានការសិក្សាច្រើន ហើយជឿថា យើងជាអ្នកប្រាជ្ញផង" ។

នៅពេលនោះ បុរសថ្ពក ៤ នាក់ក៏ពិភាក្សាគ្នា អស់រយៈពេលយ៉ាងយូរ ហើយព្រមព្រៀងគ្នាថា "យើងកុំនឹកស្ដាយថា ក្រែងស្រីនៅស្រុកឯទៀតមិនស្អាត ដូចជាស្រីនៅក្នុងស្រុកកំណើតរបស់យើង" ។

ស៊ឹមខ្វាចអស់កំឡាំង ដោយញើសហូរស្រោច បានខំឃាត់អន្ទះឃុត កុំឲ្យដើរលឿនពេក ។ ស៊ុខបានរំលឹកយ៉ាងម៉ឺងម៉ាត់ នូវពាក្យសម្បថថា "យើងមិនត្រូវបែកគ្នាឲ្យសោះ មិនត្រូវមានប្រពន្ធពោលគ្នា ម្ដងត្រូវតែមានប្រពន្ធតាំងអស់គ្នា នៅក្នុងស្រុកណាមួយ ជាមួយគ្នា" ។

អាស្រ័យហេតុនេះ វេលាព្រឹកមួយ ពេលមុនថ្ងៃរះពេញពន្លឺ គេឃើញបុរសថ្លុក ៤ នាក់ មានដៃកាន់ដំបងនិងស្ពាយថង់មួយ ៗ នាក់ ស្លៀកសំពត់ថ្មីៗ ដើរចេញពីភូមិទៅកាន់ផ្លូវ ប្រឹងមាត់ទន្លេ ឆ្ពោះដំណើរតម្រង់ទៅទិសខាងជើង ។ ម្ដងនេះ គេឃើញបុរសតំពែកដើរមួយៗ ដើម្បីគេចគ្រោះដល់ស៊ឹម ឲ្យគាត់ដើរទាន់ផង ។ បុរសតំពែកមានខ្លួនកោង ហើយដើរចប់ខ្លួននឹងឈើច្រត់ ប៉ុន្តែគាត់នៅមានចិត្តបង់សប្បាយពន់ប្រមាណ ។ ហើយជាធម្មតា គេតែងឃើញឃុតដើរលឿន ពេលគេតាំងអស់ រួចមួយសន្ទុះក្រោយមក ទើបលេចឃើញស៊ឹមទំដើរភ្លាស់ៗ ស្រែកហៅឃុតឲ្យបន្ថយជំហាន ។

មិនយូរប៉ុន្មានបុរសតំពែក ៤ នាក់ ក៏បានដើរទៅដល់ភូមិមួយ ចូលគ្នាចូលទៅក្នុងភូមិនោះ ។ ជាទសកាលអ្វី ក្នុងថ្ងៃនោះ នៅក្នុងភូមិនោះ មានកើតរឿងហេតុមួយយ៉ាងធំ គឺស្រីមេម៉ាយម្នាក់ ចាប់បានបុរសម្នាក់ កំពុងដេកជាមួយនឹងកូនក្រមុំគាត់ ហើយគាត់ក៏ប្ដឹង ពុំសុខចិត្តនឹងបុរសនោះ ។ ដើម្បីនឹងសម្រាលកំហុសរបស់ខ្លួនបន្តិច បុរសចិល បានឆ្លើយ

ដោះសារទៅនឹងចៅក្រមថា " តាំងក្រមុំនេះជាសហាយរបស់ខ្លួន យូរណាស់មកហើយ ប៉ុន្តែ នាងនោះបានឆ្លើយបដិសេធ ជាដាច់អហង្ការថា" ខ្ញុំឥតបានស្គាល់តាមនុស្សពាលនេះទេ វានេះ ជាមនុស្សកុហកឥតខ្មាស វាបានលួចលបចូលមកក្នុងបន្ទប់ខ្ញុំ ដូចជាចោរនៅពេលខ្ញុំកំពុងដេកលក់ ហើយបានប្រើកំឡាំងបាយ បង្ខំខ្ញុំឲ្យព្រមធ្វើតាមចំណង់វា តែះបើខ្ញុំនិយាយអង្វរយ៉ាងណា វាក៏ពុំព្រមស្តាប់សោះឡើយ ។

ឮដូច្នោះ ចៅក្រមក៏មានចិត្តអល់អែក ពុំអាចរកសេចក្តីពិតបាន ។ ប៉ុន្តែនៅខណៈនោះ ស្រាប់តែលេចឃុត, គំ, ស៊ុម, សុខ ដើរចូលមកយ៉ាងមួយៗ ហើយបែបសង្រួមខ្លួន ដូចជាព្រះសង្ឃនិមន្តប្រោសសត្វ ហើយមហាជនដែលឈរនៅជុំវិញរោងជំនុំ ក៏បើកផ្លូវយ៉ាងធំ ឲ្យបុរសទំពែកចូល ព្រមទាំងសំដែងសេចក្តីគួរសម ដល់បុរសទំពែកទាំងនោះផង ព្រោះគេយល់ថា បុរសទំពែកនេះ ជាបេសកជនរបស់ព្រះពុទ្ធ ហើយជាចៅក្រមធំបំផុត ។

កាលបើគេសំឡឹងមើលសាច់ឈាម និងក្បាលទំពែកសព្វគ្រប់ទៅ គេក៏ជឿថា បុរសទំពែក ជាមនុស្សចេះដឹងយ៉ាងជ្រៅជ្រះ ទើបចៅក្រមប្រគល់កន្លែងខ្លួនឲ្យគាត់អង្គុយវិញ ។

កាលបានអង្គុយស្រួលបួល ហើយបានដឹងកិច្ចការនោះសព្វគ្រប់

www.budinst.gov.kh www.elibraryofcambodia.org

បុរសកំពែកទាំង ៤ នាក់ក៏អង្គុយនៅស្ងៀម សញ្ជឹងគិតមួយសន្ទុះ រួច ឃុតក៏ចាប់និយាយមុនគេឡើង ថា៖

– ទំពក់ទៅ ទើបញោកមក ។

បន្ទាប់មក តំ និយាយ ថា៖

– មានប្រឡាយ ទើបទឹកហូរ ។

បន្ទាប់មកទៀត សុម និយាយថា៖

– តែកន្លែងណា មានផុះត្រឡាច ក៏មានផុះឃ្លោក ។

នៅទីបំផុត សុខ និយាយថា៖

– កន្លែងណា ផ្កាបុក្កុទទឹកឆោម, ក៏លើកជើង ។

កាលបើពោលពាក្យមួយម្នាក់ ដោយពុំមានអត្ថន័យដូច្នេះរួច ហើយ បុរសកំពែក ក៏បង្គាប់ឱ្យរៀបការ បុរសស្ត្រីពីរនាក់នោះទៅ ។ នៅពេលនោះ អ្នកស្រុកទាំងចៅក្រមទាំងឡាយ ក៏សើចសរសើរ នូវគតិបណ្ឌិតនិងការឈ្លាសវៃ នៃចៅក្រមកំពែកជាច្រើន ហើយក៏បបួលគ្នាជូនវត្ថុ ជារង្វាន់ ដល់គាត់ទាំងអស់គ្នាជាច្រើន ។ ឯម្ដាយនៃស្ដ្រី មាននៀង ក៏ពេញចិត្តនឹងការកាត់សេចក្ដីនេះ ហើយក៏ចូលទៅសំពះ សំដែងអំណរគុណដល់បុរសកំពែកទាំង ៤ ។

ប៉ុន្តែ ទោះបីមានល្បីឈ្មោះដូច្នេះ ក៏នៅតែស្រី ៗ ពុំព្រមស្រឡាញ់ បុរសកំពែកទៀត ។ ទើបបុរសកំពែកទាំងអស់គ្នា ទឹកឃើញផល់ស្រី

www.budinst.gov.kh www.elibraryofcambodia.org

មេម៉ាយ ដែលខ្លួនបានកាត់ក្តីឲ្យពីថ្ងៃមុន ហើយឃុតក៏ផ្តើមនិយាយថា ៖

គឺជាស្រីមានចរិយាសមរម្យណាស់ ។

តំបន្តថា :

- ជាស្រីមានការអប់រំ ប្រកបដោយបែបបទល្អ ។

សុខចន្ទ្រមថា :

- ពិតមែនតែស្គមបន្តិច ប៉ុន្តែមានសម្រស់ ។

ស៊ុមបញ្ញាថា :

- ពុំដឹងជាហេតុអ្វី កាលបើឃើញគាត់ ខ្ញុំបែរតែនឹកដល់ម្តាយខ្ញុំ ដែលជាការគាបឲ្យខ្ញុំតាមថា គាត់ជាស្រីប្រសប់ ចាត់ចែងកិច្ចការក្នុងផ្ទះ មានចិត្តសន្តោស ហើយមានសំដីទន់ផ្អែម បេះដូងក៏ថ្មមបមបំពេផង ។

បន្ទាប់ពីមានយោបល់រៀងខ្លួនដូច្នេះហើយ តំណែងទាំង ៤ ក៏សម្រេចចិត្តថា ត្រូវទៅដណ្តឹងស្រីមេម៉ាយនោះ ធ្វើជាប្រពន្ធ ។ ស្រីមេម៉ាយនោះ ឈ្មោះយាយគៀន ៖ គាត់ចាស់ណាស់ទៅហើយ ធ្មេញក៏បាក់ សាច់ក៏ឡើងជ្រីវជ្រួញ យុរយារ សម្បុរស្រអាប់ មើលទៅ ឃើញដូចសំបកមឈ្លូសស្ងួត ។

និយាយពីយាយគៀនមេម៉ាយ កាលបានឮដំណឹងដូច្នេះ គាត់ក៏នឹកក្នុងចិត្តថា :

អញនេះ ជាស្រីដ៏ចំបងបង្អស់ក្នុងប្រទេសខ្មែរ ដែលត្រូវបានដូច

ការសប្បាយអស្ចារ្យផ្ទះ ។ ពីដើមអញស្មានថា អញនេះជាមនុស្ស ចាស់រោគ ហើយអាក្រក់ក្រៃលែង អស់មាននរណាមកស្នេហាអញ ហើយ ព្រោះមានតែផ្ទះទេ ដែលនៅដេញតាមព្រះអញ បើចំណែកឯ ក្មេងអនាថាវិញ កាលណាវាឃើញអញ វាបបួលគ្នារត់ចេញឆ្ងាយ ហើយវាស្រែកថា អញជាយាយចាស់កំណាច ឥឡូវ ស្រាប់តែឮដំណឹង ថា បុរសតំណែក ៤ នាក់ចូលមកដណ្តឹងអញរៀបការ គឺដណ្តឹងទាំង ៤ នាក់ ព្រមគ្នាតែម្តង ឮដូច្នេះ អញសប្បាយចិត្តណាស់ ប៉ុន្តែ ចាស់តែពុំដាច់ ប្រាកដ តើអញត្រូវរើសយកនរណានេះ ? បើម្នាក់ណាល្អជាងអ្នក ណានោះ” គឺ

— ជនទីមួយមានមាឌធំ ប៉ុន្តែស្គម ដូចជាសំបកសណ្តែកស្ងួក ;

— ជនទីពីរធាត់ ប៉ុន្តែជើងខ្លីៗ ដូចជាសត្វទុង ។

ចំណែកពីរនាក់ទៀត មានរាងសមសួនបន្តិច ប៉ុន្តែចាស់ មើលតែ គល់ឈើ ម្យ៉ាងទៀត បើអញទទួលយកមួយធ្វើប្តី មុខជាអ្នកឯទៀត ខឹងសម្បានឹងអញពុំខាន អញមិនចង់ធ្វើឲ្យគេណាអន់ចិត្តនឹងអញសោះ ដូច្នេះ អញត្រូវតែទទួលយកទាំង ៤ នាក់ ។

ទើបគាត់នឹកទៀតថា :

មួយនាក់សម្រាប់ដងទឹកឲ្យអញ មួយនាក់ទៀតសម្រាប់ពុះអុស ជនទីបីសម្រាប់ទៅរកផ្សារដំឡូងនិងបន្លែ ជនទីបួនសម្រាប់បង្កាត់ភ្លើងដាំបាយ

www.budinst.gov.kh www.elibraryofcambodia.org

ចំណែកអញ ៗ អន្ទុយនៅស្ងៀម ធ្វើការតែខ្លួនឯង ។

ដូច្នេះ យុគដែលមានជើងវែង ១ យាយអៀនត្រូវឲ្យរែកទឹក ពីទន្លេមកដាក់ពាង ស៊ឹមដែលមានទំនង់ជាអ្នកល្មោភ ត្រូវឲ្យធ្វើបាយ ។ ចំណែកឯតំ និង សុខ ជាអ្នកមានគ្រែបៀកជួន ហើយដែលយាយអៀនយល់ថា ជាមនុស្សធ្វើឲ្យគាត់ខឿយហត់កំឡាំង ព្រោះត្រូវនិយាយខ្លាំងៗ ទើបស្តាប់បាន គាត់បានត្រូវឲ្យទៅព្រៃ រកសសរសេវល្មី ទីងជីកដំឡូង ។

នោះបើតាត់ការដូច្នេះហើយក៏ដោយ ក៏គេទៅតែឮគាត់យាយអៀនស្រែកសន្ធាប់ដេរប្តីគាត់តាំង៤ តាំងពីព្រលឹមដល់ព្រលប់ គាត់បន្ទោសថាធ្វើការល្មើយ ១ ទីមតាម ១ ហើយគាត់ដកដង្ហើមធំឥតឈប់ឈរសោះ ។

គាត់ពោលថា កាលគាត់នៅពីក្មេង មនុស្សប្រុសស្រឡាញ់គាត់ច្រើនណាស់ ហើយគេជាមនុស្សកុំព្រួសប់គ្រប់យ៉ាងផង ។

តាចាស់ ១ តាំង ៤ នាក់ ឥតស្គាល់ពេលសម្រាកសោះ ។ យាយអៀន តែងរះរករឿងប្រើបុរសខ្ទួកឥតមានឈប់ ។ គាស្រ័យហេតុនេះហើយ បានជាយុគះទៅងងឹក នៅអន្ទុយក្រែតក្រែត ១ ឯតាតំខ្ញូ ចំណែកតំ និងសុខ នោះទៅគិតអកនាំអែកនព្រៃ ។ អ្នកដែលអភ័ព្វជាងគេគឺស៊ឹម ព្រោះស៊ឹមនៅផ្ទះជានិច្ច ។ យាយអៀន ស្តីបន្ទោសព្រោសផ្ទះឲ្យគាត់ តាំងពីព្រលឹមរាល់ព្រលប់ ឥតឈប់ឈរ ហេតុនេះ ស៊ឹមក៏ទៅជាមនុស្ស គេមើលលែងស្គាល់ ខ្លួនឡើងស្គម ស្លាប់ស្បែក ខ្ញុំ ឡើង

www.budinst.gov.kh www.elibraryofcambodia.org

ស្អុតក្រៀម ដោយសារតែដៅភ្លើង ហើយទោះជាកើតជម្ងឺហើត ដោយទាំ ផ្ទុំភ្លើងឲ្យឆេះឥតឈប់ឈរ ភ្នែកឡើងក្រហមដោយសារផ្សែងធ្វូល ស្ទើរតែមើលអ្វីពុំឃើញ ៖ ទុក្ខព្រួតលើទុក្ខ តែកូនរបស់គាត់ ក៏កើតសេចក្ដីប្រណែនខឹងគាត់ដែរ ព្រោះគាត់នៅផ្ទះកល់ថ្ងៃ ជាមួយនិងប្រពន្ធ ។ កូនគាត់ បានព្រួតគ្នាប្រឆាំងនឹងគាត់ ហើយតាមព្យាបាទគាត់ឥតឈប់ឈរ ។ កាលណាស៊ីមតាកបែរមុខចេញទៅឯណា កូនគាត់ក៏លបបង់អំបិល មួយក្ដាប់តំទៅក្នុងឆ្នាំង ហើយបបួលគ្នាលបសើច ព្រោះដឹងថា ដល់ពេលបាយ យាយគៀងនឹងជេរមនុស្សគ្មានទោសនេះពុំខាន ។ ដោយគំណាបចិត្តខឹង គំនិងសុខបបួលគ្នារកកាប់តែឈើស្រស់ៗ ហើយមានជ័រផង យកមកឲ្យស៊ីមដុតដាំបាយ ។ លុះដុតៗសនោះទៅ ផ្សែងក៏ហុយពេញក្នុងផ្ទះ យាយគៀងស្ទុះចេញទៅមាត់ទ្វារ ហើយស្រែកជេរចុងភៅគំសក់ពីបម្ពាយ កប់ពុំឈ្នះ ។

ការហត់នឿយនិងការលំបាកគ្រប់យ៉ាង ហើយជម្រុលទៅរកតែសេចក្ដីស្លាប់ បានធ្វើឲ្យបុរសទាំង ៤ រឹតតែធាប់ចាស់គ្រាំគ្រាទៅទៀត គាត់ពុំអាចទ្រាំទ្រនឹងយាយគៀង ដូច្នេះតទៅទៀតបានទេ ។ ថ្ងៃមួយ នៅពេលដែលយាយគៀងទៅផ្សារ យកស្លាយដែលខ្លួនបេះបានទៅលក់ បុរសទាំង ៤ នាក់ក៏ប្រជុំជុំគ្នា រួចសម្រេចចិត្តថា នឹងចេញពីទីនេះទៅទាំងអស់គ្នា ស្វែងរកខ្ញុំកំដរឲ្យមកបំរើប្រពន្ធ ជំនួសខ្លួនរៀងខ្លួន ។

www.budinst.gov.kh www.elibraryofcambodia.org

ឃុតក៏បាននិយាយថា :

– យើងទាំងអស់គ្នាកាន់តែចាស់ ហើយកាន់តែខ្សោយមួយថ្ងៃបន្តិចៗ យើងមុខជានឹងស្លាប់បង់អាហារ បើយើងឥតបានសម្រាកសោះដូច្នេះ ។

គិតដូច្នោះហើយ បុរសថ្លក ៤ នាក់ ក៏ធ្វើដំណើរចេញ ដោយឥតចាំឲ្យយាយអៀង ត្រឡប់មកពីផ្សារវិញទាន់ឡើយ ។ ហើយទៅថ្ងៃជាមួយគ្នានោះ, គំនិតចង់បានខ្ញុំបម្រើក៏កើតមានទៅក្នុងសន្តានចិត្តនៃចៅតាក់ស្លុតម្នាក់ដែរ ។ ចៅតាក់ស្លុតនោះ ជាអ្នកប៉ិនប្រសប់ណាស់ខាងធ្វើស្ករ ធ្វើកន្ត្រកអំពីក្បាលត្នោត ។ ដូច្នេះ គាត់ក៏ឡើងទៅលើចុងត្នោតមួយខ្ពស់ ហើយនឹកក្នុងចិត្តថា : “ អញមិនត្រូវចុះទៅធ្វើស្ករនេះឯដីទេ ព្រោះខ្លាចគេលបមើល ស្គាល់ចំណេះអញ ដូច្នេះ ត្រូវតែអញនៅធ្វើស្ករ នៅលើចុងត្នោតនេះ កាលបើអញធ្វើបានច្រើនហើយ អញនឹងចុះពីចុងត្នោតយកស្ករទៅលក់ ហើយអញនឹងទិញមនុស្សបម្រើម្នាក់មកប្រើ ។

នៅពេលដែលកំពុងប្រៀកស្លឹកត្នោតនោះ គាត់ក៏នឹកដូច្នេះទៀតថា “ បើមនុស្សបម្រើនោះត្រូវធ្វើការធ្ងន់ បើប្រសិនជាពួកបម្រើអញ មិនសូវគាប់ប្រសើរទេ នោះប្រយ័ត្នត្រូវនឹងកែងជើងអញ ” ។ កំពុងតែគិតដូច្នេះ បុរសក៏លើកជើងធាក់ហើយក៏រអិលខ្លួនធ្លាក់ពីដើមត្នោត ប៉ុន្តែសំណាងល្អ នៅពេលធ្លាក់នោះ បុរសមានស្មារតី បានចាប់ចុងស្លឹកត្នោតជាប់ នៅ

www.budinst.gov.kh www.elibraryofcambodia.org

ះយានតែលះគោល ៗ កណ្តាលវាល មើលទៅដូចជាសត្វច្រើន ។

នៅពេលនោះ មានព្រានចាប់ដំរីម្នាក់ ជិះដំរីកាត់តាមនោះ ទៅហាក់ស្ត្រក្រឡេកទៅឃើញ ក៏ស្រែកហៅយ៉ាងខ្លាំងថា "លោកបងព្រានចាប់ដំរី ! បើប្រសិនជាបងអាចជួយដាក់ខ្ញុំពីលើចុងត្នោតនេះបាន ខ្ញុំនឹងទៅបម្រើលោកអស់មួយជីវិត" ។

កាលបើឮដូច្នេះ បុរសព្រានចាប់ដំរីក៏មានចិត្តត្រេកអរជាខ្លាំង ៗ គាត់ ទំបរដំរីគាត់យ៉ាងលឿន ចូលទៅក្រោមដើមត្នោត ហើយបញ្ឈរដំរីនៅក្រោមនោះ រួចគាត់ក៏ឡើងឈរនៅខ្នងដំរី ខំប្រឹងចាប់តោងជើងទៅហាក់ស្ត្រ ប៉ុន្តែ នៅពេលដែលគាត់ក្រោកឈរនោះ គាត់ខំប្រឹងចប់ខ្លួនឡើងភ្លាត្រង់សរសៃ ហាក់ដូចជាសញ្ញាគោះជង្គង់គាត់ ឲ្យដើរទៅមុខទៀត ។ ដំរីយល់ដូច្នោះក៏ដើរទៅមុខទៀត ចោលព្រានចាប់ ដែលកំពុងកោងតោងទៅហាក់ស្ត្រជាប់ ។

បុរស ២ នាក់ក៏នៅតោងស៊ុកត្នោតនោះជាប់ មើលទៅឃើញហាក់ដូចជាផ្លែឈើពីរយ៉ាងធំវែង ។ សត្វក្អែកពាំងឡាយ ភ្ញាក់ផ្អើលនឹងទស្សនីយភាពយ៉ាងចំឡែកនោះ ក៏ហើរក្រឡឹងពាច ហើយស្រែកលាន់ឮទ្រហឹងអឹងកង ។

ហាក់ស្ត្រកាន់តែធ្ងន់ខ្លួនខ្លាំងឡើងទៅទៀត ហើយខំប្រឹងតោងស៊ុកត្នោត លុះត្រាតែក្បាលវាមុតចូលទៅក្នុងសាច់ ស្រក់ឈាមមកលើមុខ

បុរសទ្រមាក់ជ័រ ជាហេតុធ្វើឲ្យបុរសខាងក្រោយនេះរឹតតែភ័យញាប់ញ័រទៅទៀត ។

យល់ឃើញថាខ្លួនពុំអាចទប់ប្រឹងតោងជាប់គោលបានទៀតទេ ចៅចាក់ស្មុគ្រក៏អង្វរករទៅទ្រមាក់ជ័រដូច្នេះថា បូរអ្នកលែងជើងខ្ញុំទៅ ខ្ញុំអស់កំឡាំងណាស់ហើយ ! ចូរលែងជើងខ្ញុំទៅ បើមិនដូច្នេះទេ យើងនឹងធ្លាក់ទៅដីស្លាប់ទាំងអស់គ្នា ” ។

មិនតែប៉ុណ្ណោះ ចៅចាក់ស្មុគ្របានស្រែកដេរ ហើយស្ទុះទាត់ជាក់ក្បាលទ្រមាក់ជ័រច្រើនទៀតផង ប៉ុន្តែចៅទ្រមាក់ជ័រត្រឡប់ជាស្រែកអង្វរករទៅចៅចាក់ស្មុគ្រវិញថា “ ឱលោកបងអើយ ! សូមលោកកុំលែងដៃឲ្យសោះ ។ បើប្រសិនជាលោកម្ចាស់ព្រំតោងលុះត្រាតែមានជនណា គេមកជួយដាក់យើងឲ្យរួចពីចុងគោល នោះខ្ញុំនឹងធ្វើជាខ្ញុំបម្រើលោកវិញលុះត្រាតែក្ស័យជីវិត ។

នៅពេលនោះ ស្រាប់លេចបុរសគំតែករយើង ៤ នាក់ ដែលស្វែងរកទាសៈសម្រាប់បម្រើប្រពន្ធខ្លួនទៅដល់ បុរសអស់សង្ឃឹមទាំងពីរនាក់ស្រែកហៅបុរសគំតែកទាំងឡាយឲ្យចូលមក ហើយនិយាយថា “ ឱលោកផុតកទាំងឡាយ សូមលោកផុតកជួយយកអាសាខ្ញុំផង ខ្ញុំនឹងទៅនៅធ្វើជាខ្ញុំបម្រើលោក លុះត្រាអស់ ១ ជីវិត ។

បានឮដូច្នោះ បុរសគំតែក ៤ នាក់គឺត្រេកអរជាខ្លាំង ទើបយុត

www.budinst.gov.kh www.elibraryofcambodia.org

និយាយទៅកាន់គ្នាឯងថា "យើងពុំដឹងមានមធ្យោបាយអី នឹងរកមនុស្សបម្រើឲ្យបាន ឥឡូវយើងបានជួបពីរនាក់នេះហើយ ។ ចូរយើងសន្ទឹងសំពត់ឡើង ហើយម្នាក់ៗ កាន់មួយជ្រុង ឈរពីក្រោមមនុស្សយោលពោងនេះ ។ លុះធ្វើដូច្នេះហើយ បុរសគំតែក ៤ នាក់ក៏ស្រែកហៅឲ្យបុរសពីរនាក់ទម្លាក់ខ្លួនចុះមក ប៉ុន្តែ បុរសទាំងក្រោយនេះ ពុំទាន់ដាច់ចិត្តហ៊ានទម្លាក់ខ្លួនមក ហើយស្រែកប្រាប់មកទៅគំតែកដូច្នេះថា "ឱលោកឪពុកក្អែក! តើលោកឪពុកមានកំឡាំងគ្រប់គ្រាន់ទេ? លោកឪពុកសន្ទឹងសំពត់ស្រួលហើយឬ?. . ប្រាកដហើយឬ?

ដើម្បីជាការប្រយ័ត្នលើប្រយ័ត្នទៅទៀត គាត់តែក ៤ នាក់ ក៏យកជ្រុងសំពត់ចងជាប់ទៅនឹងករៀង ១ ខ្លួន រួចទំប្រឹងទប់ខ្លួនទាញសំពត់យ៉ាងអស់ទំហឹង រួចស្រែកទៅកាន់បុរសតែងពោងពីរនាក់នោះថា "ម្តងនេះត្រៀមស្រួលបួលហើយ ចូរទៅទម្លាក់ខ្លួនមកចុះ!

ទៅតាក់ស្ត្រគនឹងទៅទ្រមាក់ដ៏រ ក៏ទម្លាក់ខ្លួនមកចំកណ្តាលសំពត់ ប៉ុន្តែ អនិច្ចាអើយ ទម្ងន់មនុស្សពីរនាក់នោះ បានកន្ត្រាក់ទាញក្បាលគំតែក ៤ នាក់ឲ្យមកទង្គិចគ្នាលាន់សូរតែផូស ៗ

សេចក្តីហេតុនេះ ឃុត គំ សុម. ឌឹង សុខ ក៏ក្ស័យជីវិត នៅពេលជាមួយគ្នានោះអស់ទៅ ។ ៚

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ពស់ថ្លាន់ថ្លាន់ | ពស់ថ្លាន់ | ១៥ | ៧ |
| បិនធ្លូប | មិនធ្លូប | ១៧ | ២ |
| កពេក្រៃ | ពេកក្រៃ | ៣២ | ១២ |
| បណើនេះជា | បំណើនេះជា | ៤១ | ១៣ |
| មរណ៍ថ្វាត់ | មរណ់ថ្វាត | ៤៣ | ១៦ |
| ពេជឃាដ | ពេជ្ឈឃាដ | ៤៦ | ៦ |
| នៃមហាសេដ្ឋី | នៃមហាសេដ្ឋី ។ | ៤៩ | ៣ |
| ពំសោះទៀយណា | ពុំណោះឡើយណា | -ដ- | ៤ |
| ក្សត្រាមានបុណ្យ | ក្សត្រមានបុណ្យ | ៥៥ | ១៤ |
| ច្បាប់ដើមខ្វះ | ច្បាប់ដើមខ្លះ | ៦៧ | ១៣ |
| នគរនះ | នគរនេះ | ៦៨ | ១៣ |
| យុពណោិតា | យំពណោិតា | ៧៣ | ១០ |
| តាងអំពីដើម | តាំងអំពីដើម | ៩៦ | ៧ |
| ញអៀន | ញើអៀន | ១០៥ | ៥ |
| យេនរណា | យើនរណា | -ដ- | ១២ |
| នងឋា | និងឋា | ១០៨ | ៤ |
| ជិតផល់ | និតផល់ | — | ២ |
| ទកស្មើ | ទុកស្មើ | — | ១២ |
| តបតតបះ | តបតតប៉ះ | ១១៦ | ២ |
| ដំទំគ្នា | ដំគុំគ្នា | ១២៥ | ១០ |
| ដណើរ | ដំណើរ | ១៣០ | ១ |
| ជាក់ស្នុក | ជាក់ស្នុគ្រ | ១៣៧ | ៧ |

www.budinst.gov.kh www.elibraryofcambodia.org

រោងពុម្ពវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

www.budinst.gov.kh www.elibraryofcambodia.org